សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# តួនាទី និងភារកិច្ចរបស់នគរបាលយុត្តិធម៌ នៃកងរាជអាវុធហត្ថលើផ្ទៃប្រទេស

ស្រាវជ្រាវពីថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៩ ដល់ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៩

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ: **លោក ស៊ូ ដុងហ័រ**
**លោក ប៉ុក ស៊ីវចនា**

សាស្ត្រាចារ្យណែនាំ
លោក **ហ៊ាង ឡេង**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ១៩

ឆ្នាំចូលសិក្សា ២០១៥
ឆ្នាំសរសេរសារណា ២០១៩

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទ **ស៊ុំ ដុងហ៊ា** និងខ្ញុំបាទ **ប៉ុក ស៊ីវចនា** ជានិស្សិត ផ្នែកនីតិសាស្ត្រក្រុម $L_4A_4$ ជំនាន់ទី ១៩ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមថ្លែងអំណរគុណ និងសូមសម្តែងនូវការគោរពដោយកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុត៖

-ចំពោះ **លោកឪពុក-អ្នកម្តាយ** ដែលបានផ្តល់កំណើតដល់រូបយើងខ្ញុំ និងចិញ្ចឹមបីបាច់ថែរក្សា ព្រមទាំងផ្តល់កម្លាំងចិត្ត ដំបូន្មានល្អៗដល់កូនដែលប្រកបដោយព្រហ្មវិហារធម៌ និងធ្វើពលីកម្មគ្រប់បែបយ៉ាងទាំងកម្លាំងកាយ កម្លាំងចិត្ត ថែមទាំងចំណាយទ្រព្យសម្បត្តិដើម្បីឲ្យរូបកូន បានសិក្សារៀនសូត្រទទួលបាននូវចំណេះវិជ្ជា និងទទួលបាននូវជោគជ័យដូចបំណង។

-ចំពោះ **ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ថ្នាក់ដឹកនាំមន្ត្រីរាជការ លោក លោកស្រីសាស្ត្រាចារ្យ បុគ្គលិកទាំងអស់**នៃសាលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលខិតខំប្រឹងប្រែងអស់កម្លាំងកាយចិត្តក្នុងការដឹកនាំបង្រៀន គ្រប់គ្រងចាត់ចែងបម្រើការងារទូទៅប្រកបដោយគតិបណ្ឌិតខ្ពស់ ក្នុងន័យចែករំលែកចំណេះដឹងដ៏ថ្លៃថ្លាដល់រូបយើងខ្ញុំទាំងពីរ ព្រមទាំងនិស្សិតគ្រប់ជំនាន់។

-ចំពោះលោកសាស្ត្រាចារ្យ **ហ៊ាង ឡេង** មិនត្រឹមតែជួយបង្ហាត់បង្រៀន យើងខ្ញុំទាំងពីរប៉ុណ្ណោះទេ ថែមទាំងចំណាយពេលយ៉ាងច្រើនសន្ធឹកសន្ធាប់ក្នុងការដឹកនាំសិក្សាស្រាវជ្រាវចងក្រងសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ និងជួយផ្តល់នូវឯកសារផ្សេងៗ ព្រមទាំងទស្សនៈយោបល់ដំបូន្មានល្អៗក្នុងការសរសេរចងក្រងសារណានេះឡើង។

ខ្ញុំបាទ សូមជូនពរ និងប្រសិទ្ធិបរជ័យមង្គល សិរីមហាប្រសើរ ចំពោះ**លោកអ្នកមានគុណទាំងបួន សម្តេច ឯកឧត្តម លោក លោកស្រី សាស្ត្រាចារ្យ ព្រមទាំងបុគ្គលិកទាំងអស់** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងសូមប្រកបនូវពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀនឃ្លាតឡើយ៕

# អារម្ភកថា

ប្រធានបទ " **តួនាទី និង ភារកិច្ចរបស់កងរាជអាវុធហត្ថលើផ្ទៃប្រទេស** " ដែលយើងខ្ញុំទាំងពីរបានលើកយកមកសិក្សាស្រាវជ្រាវដើម្បីចងក្រងជាសារណានេះឡើង គឺក្នុងគោលបំណងបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រអស់រយៈពេល ៤ឆ្នាំ ផ្នែកនីតិសាស្ត្រនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ចាប់ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៩ ព្រមទាំងឈរលើចំណេះដឹងដែលខ្ញុំបាទបានទទួលអំពីលោក លោកស្រីជាសាស្ត្រាចារ្យទាំងឡាយដែលបានបង្ហាត់បង្រៀនដល់រូបយើងខ្ញុំផង។

គោលបំណងដែលខ្ញុំបាទ លើកយកប្រធានបទនេះមកសិក្សាស្រាវជ្រាវចងក្រងជាសារណាដោយសារតែនាយទាហាននៃកងរាជអាវុធហត្ថនៃព្រះរាជាណាចក្រកម្ពុជា ក៏មានតួនាទីយ៉ាងសំខាន់មួយក្នុងការត្រួតពិនិត្យបទល្មើសឧក្រិដ្ឋ មជ្ឈិម និងលហុ កំណត់អត្តសញ្ញាណនិងចាប់ជនល្មើសព្រមទាំងប្រមូលភស្តុតាងដើម្បីថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សង្គមឲ្យមានរបៀបរៀបរយនោះ ថាតើត្រូវអនុវត្តនីតិវិធីច្បាប់បែបណា? ម្យ៉ាងវិញទៀតដើម្បីនឹងសាកល្បងនូវចំណេះដឹងដែលសិក្សាកន្លងមកផង និងទុកជាឯកសារសម្រាប់អ្នកសិក្សាជំនាន់ក្រោយផង។

យើងខ្ញុំទាំងពីរ ជឿជាក់ថាការសរសេរចងក្រងនេះ ពិតជាមិនបានគ្រប់ជ្រុងជ្រោយទេ ប្រាកដជាមានកំហុសឆ្គង និងកង្វះខាតពុំខាន។ រាល់កំហុសឆ្គង និងកង្វះខាតទាំងនេះ យើងខ្ញុំសង្ឃឹមជឿជាក់ថា នឹងមានការយោគយល់ពីសំណាក់អស់លោកដោយចិត្តសប្បុរស។

ជាទីបញ្ចប់នេះ យើងខ្ញុំសូមឧទ្ទិសស្នាដៃនេះដល់ ព្រះវិញ្ញាណក្ខន្ធអតីតព្រះមហាក្សត្រព្រះមហាក្សត្រយានី វីរៈបុរស វីរៈនារី ស្នេហាជាតិទាំងអស់ ដែលបានលះបង់ជីវិតក្នុងការពារទឹកដីនៃព្រះរាជានាចក្រកម្ពុជា ឲ្យបានគង់វង់ រហូតដល់សព្វថ្ងៃនេះ និងសូមឲ្យព្រះរាជាណាចក្រកម្ពុជាប្រកបដោយសុខសន្តិភាពរៀងរហូត៕

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ........ ១

## ជំពូកទី១
## ប្រវត្តិ និងការបង្កើតកងរាជអាវុធហត្ថលើផ្ទៃប្រទេស

**ផ្នែកទី១៖ ការបង្កើតប្រព័ន្ធកងរាជអាវុធហត្ថ** ........ ៣

**១. ប្រព័ន្ធកងរាជអាវុធកម្ពុជា** ........ ៣

**២. កងរាជអាវុធកម្ពុជាជាមុខងាររបស់រដ្ឋ** ........ ៤

**៣. ទំនើបកម្មនៃកងរាជអាវុធកម្ពុជានៅសម័យសង្គមរាស្ត្រនិយម** ........ ៤

**ផ្នែកទី២៖ ប្រវត្តិកងរាជអាវុធហត្ថ** ........ ៥

**១. របបសង្គមរាស្ត្រនិយម** (**ព្រះរាជាណាចក្រកម្ពុជាទី១**) ........ ៥

**២. របបសាធារណៈរដ្ឋខ្មែរ** (**លន់ នល់**) ........ ៦

**៣. របបកម្ពុជាប្រជាធិបតេយ្យ** (**ខ្មែរក្រហម**) ........ ៦

**៤. របបសាធារណៈរដ្ឋប្រជាមានិតកម្ពុជា** (**រដ្ឋកម្ពុជា**) ........ ៦

**៥. ព្រះរាជាណាចក្រកម្ពុជាទី២** ........ ៧

## ជំពូកទី២
## រចនាសម្ព័ន្ធចាត់តាំងបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

**ផ្នែកទី១៖ រចនាសម្ព័ន្ធ និងតួនាទី ភារកិច្ចកងរាជអាវុធហត្ថលើផ្ទៃប្រទេស** ........ ៩

**១-សមិទ្ធិផលការងាររបស់កងរាជអាវុធហត្ថ** ........ ៩

**២-ភារកិច្ចរបស់កងរាជអាវុធហត្ថលើផ្ទៃប្រទេស** ........ ៩

២.១ រ៉ាប់រងសកម្មភាពខាងប៉ូលីសរដ្ឋបាល ........ ៩

២.២ រ៉ាប់រងសកម្មភាពខាងប៉ូលីសតុលាការ ........ ១០

២.៣ បំពេញបេសសកម្មដែលមានលក្ខណៈពិសេសខាងយោធា ........ ១១

២.៤ បេសសកម្មផ្នែកប៉ូលីសពិសេស ........ ១២

២.៥ ផ្តល់កម្លាំងទៅជួយក្រសួងនានា ដែលបានស្នើសុំតាមសេចក្តីត្រូវការចាំបាច់ ........ ១២

ក. បេសសកម្មទប់ស្កាត់ និងបង្ក្រាប ........ ១២

ខ. បេសសកម្មក្រៅប្រទេស ........ ១៣

គ.ការទទួលខុសត្រូវចំពោះសង្គម ........ ១៥

**៣-តួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងស្ថាប័នចំណុះបញ្ជាការដ្ឋានកងរាជអាវុធហត្ថ . ១៦**
៣.១ ខុទ្ទកាល័យ ........ ១៧
៣.២ សេនាធិការដ្ឋាន ........ ១៨
៣.៣ ស្នងការដ្ឋានរដ្ឋបាលហិរញ្ញវត្ថុ ........ ២០
៣.៤ ស្នងការដ្ឋានយុត្តិធម៌ ........ ២១
៣.៥ ស្នងការដ្ឋានភស្តុភារ ........ ២២
៣.៦ ស្នងការដ្ឋានប្រភពកម្លាំង ........ ២២
៣.៧ ស្នងការដ្ឋានបច្ចេកទេសសន្តិសុខ ........ ២៤
៣.៨ បញ្ជាការដ្ឋានរដ្ឋបាល ........ ២៤
៣.៩ ស្នងការដ្ឋានសម្ភារៈបច្ចេកទេស ........ ២៥
**ផ្នែកទី២៖ រចនាសម្ព័ន្ធ តួនាទី ភារកិច្ចកងរាជអាវុធហត្ថសាលាកំបូល និងមជ្ឈមណ្ឌលហ្វឹកហ្វឺនភ្នំជំរាយ ........ ២៧**
**១. សាលាកំបូល ........ ២៧**
**២. មជ្ឈមណ្ឌលហ្វឹកហ្វឺនភ្នំជំរាយ ........ ២៨**
**ផ្នែកទី៣៖ សមាសភាពនគរបាលយុត្តិធម៌នៃកងរាជអាវុធហត្ថលើផ្ទៃប្រទេស ........ ២៩**
**១. មន្ត្រីនគរបាលយុត្តិធម៌នៃកងរាជអាវុធហត្ថលើផ្ទៃប្រទេស ........ ៣០**
១.១ ការទទួលបានគុណសម្បត្តិតាមរយៈការប្រឡង ........ ៣០
១.២ ការទទួលបានគុណសម្បត្តិតាមរយៈឋានន្តរស័ក្តិ និងមុខងារ ........ ៣០
១.៣ សម្បថ ........ ៣១
១.៤ កំហុសពេលអនុវត្តការងារ ........ ៣១
១.៤.១ នីតិវិធីដាក់វិន័យ ........ ៣១
១.៤.២ ទណ្ឌកម្ម ........ ៣៣
១.៥ សមត្ថកិច្ចដែនដី និងការកំនត់សមត្ថកិច្ច ........ ៣៣
១.៥.១ សមត្ថកិច្ចដែនដី ........ ៣៣
១.៥.២ ការកំនត់សមត្ថកិច្ច ........ ៣៤
១.៥.៣ ការពន្លាតសមត្ថកិច្ច ........ ៣៤
**២. ភ្នាក់ងារនគរបាលយុត្តិធម៌នៃកងរាជអាវុធហត្ថលើផ្ទៃប្រទេស ........ ៣៤**
២.១ ការទទូបានគុណសម្បត្តិជាភ្នាក់ងារនគរបាលយុត្តិធម៌ ........ ៣៤

២.២ សម្បថ ............ ៣៥
២.៣ កំហុសពេលអនុវត្តការងារ ............ ៣៥
២.៣.១ នីតិវិធិដាក់ពិន័យ ............ ៣៥
២.៣.២ ទណ្ឌកម្ម ............ ៣៥
២.៤ សមត្ថកិច្ចដែន និងការកំណត់សមត្ថកិច្ច ............ ៣៦
២.៤.១ សមត្ថកិច្ចដែនដី ............ ៣៦
២.៤.២ ការកំណត់សមត្ថកិច្ច ............ ៣៦

## ជំពូកទី៣

## បេសសកម្មនគរបាលយុត្តិធម៌នៃកងរាជអាវុធហត្ថ

**ផ្នែកទី១៖ បេសសកម្មរបស់មន្ត្រីនគរបាលយុត្តិធម៌** ............ ៣៧
**១. ការពិនិត្យបទល្មើស** ............ ៣៧
**២. ការទទួលពាក្យបណ្តឹង** ............ ៣៧
២.១ បណ្តឹងទាមទារ ............ ៣៧
២.២ បណ្តឹងបរិហារ ............ ៣៧
២.៣ ចំណាត់ការលើពាក្យបណ្តឹង ............ ៣៨
**៣. ការស៊ើបអង្កេត** ............ ៣៩
៣.១ ការស៊ើបអង្កេតជាក់ស្តែង ............ ៣៩
៣.២ ការស៊ើបអង្កេតបឋម ............ ៤៧
៣.៣ ការបញ្ជូននីតិវិធី ............ ៤៨
៣.៤ តម្លៃគតិយុត្តនៃកំណត់ហេតុ ............ ៤៨
**៤. ការអនុវត្តសេចក្តីសម្រេចរបស់តុលាការ** ............ ៤៨
៤.១ ការអនុវត្តដីកាកោះ ............ ៤៩
៤.២ ការអនុវត្តដីកាបញ្ជាឲ្យចូលខ្លួន ............ ៤៩
៤.៣ ការអនុវត្តដីកាបង្គាប់ឲ្យចូលខ្លួន ............ ៤៩
៤.៤ ការអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួន ............ ៤៩
៤.៥ ការអនុវត្តដីកាបង្គាប់ឲ្យចាប់ខ្លួន ............ ៥០
៤.៦ ការអនុវត្តដីកាបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្ន ............ ៥០

៤.៧ ការអនុវត្តដីកាបង្គាប់ឲ្យស៊ើបសួរជំនួស ........................................................................ ៥០
**៥. ឋានុក្រមក្នុងពេលបំពេញបេសសកម្ម** ........................................................................ ៥២
**៦. ទម្រង់នៃការបមពេញកិច្ចការរបស់មន្ត្រីនគរបាលយុត្តិធម៌** ........................................................ ៥៣
**៧. កិច្ចដែលមន្ត្រីនគរបាលយុត្តិធម៌ត្រូវជៀសវាង** ........................................................................ ៥៤
**ផ្នែកទី២៖ បេសសកម្មរបស់ភ្នាក់ងារនគរបាលយុត្តិធម៌** ........................................................... ៥៤
**១. ឋានុក្រមក្នុងការបំពេញបេសសកម្ម** ........................................................................ ៥៤
**២. ទម្រង់នៃការបំពេញកិច្ចការរបស់ភ្នាក់ងារនគរបាលយុត្តិធម៌** ................................................ ៥៥
**សេចក្តីសន្និដ្ឋាន និងអនុសាសន៍** ........................................................................ ៥៦
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

ប្រទេសកម្ពុជាធ្លាប់ទទួលបាននូវភាពល្បីរន្ទឺពាសពេញសកលលោក គឺនៅអំឡុងសតវត្សទី៩ ដល់ទី១៤ ជាសម័យមហានគរ។ ប៉ុន្តែជាអកុសលដោយសារការរំលោភបំពានពីសំណាក់ប្រទេសជិតខាង និងជម្លោះផ្ទៃក្នុងផងនោះបានធ្វើឲ្យប្រទេសកម្ពុជាចុះអន់ថយជាបន្តបន្ទាប់ដល់ចំណុចសូន្យពោលគឺ របបប្រល័យពូជសាសន៍ផ្តាច់ការ "កម្ពុជាប្រជាធិបតេយ្យ" រយៈពេល ៣ឆ្នាំ ៨ខែ និង ២០ថ្ងៃ ។

នៅថ្ងៃទី ៧ មករា ១៩៧៩ ជាថ្ងៃរំដោះជាតិពីរបបប្រល័យពូជសាសន៍ ដោយកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបានធ្វើឲ្យប្រទេសកម្ពុជាប្រែមុខមាត់សារជាថ្មីឡើងវិញ។ ចាប់តាំងពីឆ្នាំ ១៩៧៩ ដល់បច្ចុប្បន្នប្រទេសកម្ពុជាមានភាពរីកចម្រើនយ៉ាងឆាប់រហ័សគួរជាទីមោទនៈក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

បច្ចុប្បន្ននេះកម្ពុជាបានងាកមករកលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស តាមរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ រីឯភាពរីកចម្រើនមានគ្រប់វិស័យ ទាំងការគ្រប់គ្រង ការងារយុត្តិធម៌ សង្គមកិច្ចសុខាភិបាល អប់រំ។ ទោះបីជាសង្គមមួយមានភាពរីកចម្រើន ប្រកបដោយសុខសន្តិភាពក៏ពិតមែន តែគង់មានអសន្តិសុខខ្លះមិនខាន ដូចជា ចោរលួច ឆក់ ប្លន់ ចាប់ជំរិត និងការជួញដូរគ្រឿងញៀនជាដើម......។

ចំណុចទាំងនេះ គឺមន្ត្រីនគរបាលយុត្តិធម៌របស់កងរាជអាវុធហត្ថដែលជាផ្នែកមួយនៃកងយោធពលខេមរភូមិន្ទ ត្រូវរួមចំណែកក្នុងការបញ្ចេញសកម្មភាពទប់ស្កាត់ បង្ក្រាបរាល់បទល្មើសដែលកើតមានឡើង។

ដើម្បីឲ្យសង្គមមួយប្រកបដោយសុខសន្តិភាព យុត្តិធម៌ និងធានាការគោរពសិទ្ធិមនុស្សធានាការគោរពច្បាប់ ការគោរពវិន័យយោធា ក្នុងនោះត្រូវមាននគរបាលយុត្តិធម៌របស់កងរាជអាវុធហត្ថដែលជាផ្នែកមួយមិនអាចខ្វះបានក្នុងការអនុវត្តកិច្ចការទាំងនេះ។ ដូច្នេះខ្លឹមសារនៅក្នុងសារណានេះចង់បង្ហាញអំពីនគរបាលយុត្តិធម៌របស់កងរាជអាវុធហត្ថ ដែលត្រូវអនុវត្តតាមនីតិវិធីបែបណាខ្លះ? ដើម្បីឲ្យការងារប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់ដោយយោងលើគោលការណ៍ច្បាប់នៅពេលមានបទល្មើសណាមួយកើតឡើងដែលធ្វើឲ្យប៉ះពាល់ដល់ សណ្តាប់ធ្នាប់សាធារណៈសន្តិសុខសង្គម។

មូលហេតុដែលពួកយើង ជ្រើសរើសប្រធានបទនេះ ដោយសារតែចង់យល់ឲ្យបានកាន់តែច្បាស់ អំពីសិទ្ធិអំណាច កាតព្វកិច្ច និងតួនាទីរបស់នគរបាលយុត្តិធម៌នៃកងរាជអាវុធហត្ថលើផ្ទៃប្រទេស ព្រមទាំងចង់លើកស្ទួយធនធានមនុស្ស ក្នុងគោលបំណងឲ្យការបំពេញភារកិច្ច

របស់ នគរបាលយុត្តិធម៌នៃកងរាជអាវុធហត្ថលើផ្ទៃប្រទេសប្រកបដោយប្រសិទ្ធិភាព និងគុណភាពខ្ពស់។

នៅក្នុងការសិក្សាស្រាវជ្រាវចងក្រងជាសារណានេះឡើង យើងខ្ញុំបានបែងចែកជាបីជំពូកដើម្បីលើកយកមកបង្ហាញ។ ជំពូកទី១៖ ប្រវត្តិ និង ការបង្កើតកងរាជអាវុធហត្ថលើផ្ទៃប្រទេស ផ្នែកទី១៖ការបង្កើតកងរាជអាវុធហត្ថលើផ្ទៃប្រទេស ផ្នែកទី២៖ ប្រវត្តិនៃកងរាជអាវុធហត្ថលើផ្ទៃប្រទេស។ ជំពូកទី២៖ រចនាសម្ព័ន្ធចាត់តាំងបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស ផ្នែកទី១៖ រចនាសម្ព័ន្ធកងរាជអាវុធហត្ថលើផ្ទៃប្រទេស ផ្នែកទី២៖ រចនាសម្ព័ន្ធវិទ្យាស្ថានកងរាជអាវុធហត្ថ (កំបូល) និង រចនាសម្ព័ន្ធមជ្ឈមណ្ឌលហ្វឹកហ្វឺនកងរាជអាវុធហត្ថ (ភ្នំជំរាយ) ផ្នែកទី៣៖ សមាសភាពនគរបាលយុត្តិធម៌នៃកងរាជអាវុធហត្ថលើផ្ទៃប្រទេស។ ជំពូកទី៣៖ បេសកកម្មនគរបាលយុត្តិធម៌នៃកងរាជអាវុធហត្ថ ផ្នែកទី១៖ បេសកកម្មរបស់មន្ត្រីនគរបាលយុត្តិធម៌ ផ្នែកទី២៖ បេសកកម្មរបស់ភ្នាក់ងារនគរបាលយុត្តិធម៌។

# ជំពូកទី ១

## ប្រវត្តិ និង ការបង្កើតកងរាជអាវុធហត្ថលើផ្ទៃប្រទេស

# ជំពូកទី១

# ប្រវត្តិ និង ការបង្កើតកងរាជអាវុធហត្ថលើផ្ទៃប្រទេស

## ផ្នែកទី១៖ ការបង្កើតប្រព័ន្ធកងរាជអាវុធហត្ថ

ការសិក្សាប្រៀបធៀប នៃការបង្កើតកងរាជអាវុធហត្ថជាតិបារាំង-ខ្មែរ អាចឲ្យយល់ពីលក្ខណៈពិសេសរបស់វា។ បច្ចុប្បន្នភាព និងទាញបាននូវលក្ខណៈរួម និងលក្ខណៈពិសេសថ្នាក់ជាតិ។ តាមសៀវភៅកងរាជអាវុធហត្ថជាតិបារាំងភាគ១ និងភាគ២ កងរាជអាវុធហត្ថ គឺជាកំលាំងមួយបង្កើតឡើងដើម្បីតាមដានមើលសន្តិសុខសាធារណៈ និងធានាសណ្តាប់ធ្នាប់សាធារណៈ និងការអនុវត្តច្បាប់លើវិសាលភាពនៃទឹកដីជាទីតាំងមូលដ្ឋាន ដូចកំលាំងយោធាដែរ។[1]

### ១. ប្រព័ន្ធកងរាជអាវុធហត្ថកម្ពុជា

កំណើតកងរាជអាវុធហត្ថកម្ពុជា ដែលជាអង្គការសាធាណៈមួយឯកទេស និងវិជ្ជាជីវៈមានកាលបរិច្ឆេទទទួលបានឯករាជ្យ ឆ្នាំ១៩៥៣។ ការបង្កើតកងរាជអាវុធហត្ថ គឺក្នុងគោលដៅពង្រឹងគុណភាពរបស់កងយុទ្ធពលខេមរភូមិន្ទ។ ឆ្នាំ១៩៥៤ កងរាជអាវុធហត្ថត្រូវបានចាប់បដិសន្ធិឡើង ហើយត្រូវបានបង្កើតឡើងជាផ្លូវការដោយព្រះរាជក្រឹត្យលេខ៤៩៦នស និង៤៩៧នស ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៥៧។ ចាប់ពីការបង្កើតកំលាំងនេះមក ប្រវត្តិរបស់កងរាជអាវុធហត្ថត្រូវបានធ្វើកំណែទម្រង់ជាច្រើន។ ត្រូវរៀបតាមលំដាប់លំដោយតាមប្រវត្តិសាស្រ្តដ៏រំជើបរំជួលនេះ ដើម្បីរកឲ្យឃើញនូវធាតុនៃការកាត់ផ្តាច់ និង ឯកភាពដែលបញ្ជាក់ពីស្ថាប័នកងរាជអាវុធហត្ថ។

ការកំណត់មិនបាននៃទស្សនៈរបស់កងរាជអាវុធហត្ថ និងការប្រើប្រាស់ន័យជាហូរហែរនៃសញ្ញាណនេះ ចាប់តាំងពីសតវត្សទី១២ មក ក៏ជាកត្តាឯកភាពស្មុគស្មាញដែរ។ តាមប្រវត្តិសាស្រ្តកងរាជអាវុធហត្ថ ត្រូវបានបង្កើតដោយមានទំនាក់ទំនងយ៉ាងស្អិតរមួតជាមួយនឹងការបង្កើតរដ្ឋ។ ភាពឡូសិករដ្ឋបាលតម្រូវឲ្យមានការរៀបចំស្ថាប័នមជ្ឈការ និងឯកទេសក្នុងការថែរក្សាសណ្តាប់ធ្នាប់ផ្ទៃក្នុង។ ប៉ុន្តែចលនានេះមិនជាប់លាប់ទេ ហើយក៏មិនឥតខ្ចោះដែរ ដោយសារតែការប្រមូលផ្តុំឡូសិកផ្សេងៗគ្នាធ្វើឲ្យសំខាន់ដល់ការវិភាគនៃការវិវត្តរបស់ស្ថាប័ន។

កងរាជអាវុធហត្ថកម្ពុជា បញ្ជាក់ផងដែរពីចំណងរបស់ខ្លួនជាមួយនឹងអំណាច។ វាស្ថិតនៅចំណុចកណ្តាលនៃជំលោះនយោបាយ និងសង្គមជាតិដែលឆ្លងកាត់សង្គមខ្មែរ។ ប្រវត្តិនៃកំណែទម្រង់របស់កងរាជអាវុធហត្ថមិនអាចកាត់ផ្តាច់ចេញពីរយៈពេលសុពលភាពនៃជំលោះនោះទេទោះបីជា

[1] សៀវភៅកងរាជអាវុធហត្ថជាតិបារាំង ភាគ១ និងភាគ២ ខែមេសា ឆ្នាំ បកប្រែជាភាសាខ្មែរដោយសារលោកវរសេនីយ៍ត្រី ម៉ាង ណាសជាត

ស្ថាប័ននេះគេចផុតដោយឡែកពីការកាត់ផ្តាច់នៃរបបនយោបាយក៏ដោយ។ ស្ថាប័នកងរាជអាវុធហត្ថស្ថិតនៅជាចំណុចដ៏សំខាន់នៃការជជែកគ្នាផ្នែកនយោបាយ ហើយជាពិសេសជាចំណុចសំខាន់នៃមនោគមវិជ្ជាសេរី។ ប៉ុន្តែអស្ថេរភាពនយោបាយ និងសង្គមដែលបញ្ជាក់បានពីព្រោះព្រះរាជា-ណាចក្រកម្ពុជា ពន្យល់អំពីការផ្សះផ្សារដ៏លំបាករវាងសេរីភាព និងភាពចាំបាច់នៃសណ្តាប់ធ្នាប់សាធារណៈ។ កងរាជអាវុធហត្ថកម្ពុជា កើតចេញពីរដ្ឋមិនមែនពីសង្គមទេ។ ដូច្នេះកងរាជអាវុធហត្ថ នៅព្រះរាជាណាចក្រកម្ពុជារៀបចំជារដ្ឋបាលដោយមានទំនាក់ទំនងយ៉ាងស្អិតរមួតជាមួយនឹងការបង្កើតរដ្ឋទំនើប។ ប៉ុន្តែប្រវត្តិរដ្ឋបាលនេះមិនមានលក្ខណៈគ្រប់គ្រាន់ទេ ដើម្បីពណ៌នាកងរាជអាវុធហត្ថកម្ពុជា។ ដូច្នេះត្រូវបំពេញទៅលើប្រវត្តិរដ្ឋបាល ប្រវត្តិនយោបាយមួយដែលអាចឲ្យយល់បានពីលក្ខណៈពិសេសនៃកងរាជអាវុធហត្ថនយោបាយ និងតួនាទីរបស់កងរាជអាវុធហត្ថ របៀបដូចជាកំលាំងរាំងផ្នែកនយោបាយ។[២]

## ២. កងរាជអាវុធហត្ថកម្ពុជាជាមុខងាររបស់រដ្ឋ

រដ្ឋមានមុខងារធំៗពីរគឺមុខងារក្នុងការបម្រើសេវាសាធារណៈ និងមុខងារក្នុងការរក្សាសណ្តាប់ធ្នាប់សាធារណៈ។ ចាប់តាំងពីការបង្កើតកងរាជអាវុធហត្ថត្រូវចាត់ទុកជាមុខងាររបស់រដ្ឋ។ ដូច្នេះកងរាជអាវុធហត្ថត្រូវដើរតួនាទីយ៉ាងសំខាន់ ហើយកងរាជអាវុធហត្ថលាយចូលគ្នាក្នុងការរៀបចំទូទៅនៃរដ្ឋបាល។ ប៉ុន្តែដោយរក្សានូវលក្ខណៈពិសេសរបស់ខ្លួន។

កងរាជអាវុធហត្ថ ត្រូវរៀបចំទៅតាមភាពខុសគ្នានៃទីកន្លែងទៅតាមរាជធានី-ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ-សង្កាត់។

## ៣. ទំនើបកម្មនៃកងរាជអាវុធហត្ថនៅសម័យសង្គមរាស្ត្រនិយម

សញ្ញាណនៃកងរាជអាវុធហត្ថត្រូវបានចំលងចេញទាំងស្រុងពីសញ្ញាណនៃកងរាជអាវុធហត្ថបារាំង មុនបារាំងចូលមកដាក់អាណាព្យាបាល និងអាណានិគមនិយមឥណ្ឌូចិន កំលាំងនេះគ្មានទេ។ ជាមួយនឹង អាណានិគមនិយម អាណាព្យាបាលរបស់ខ្លួន បារាំងបាននាំមកនូវកំលាំងពិសេសនេះ។ ក្នុងសម័យកាលនោះ កងរាជអាវុធហត្ថធានានូវបេសកកម្មនៃតម្រួតយោធា (តម្រួតទាហានខ្មែរ) ប៉ុន្តែយ៉ាងឆាប់រហ័សក៏ត្រូវគិតគូរពីបេសកកម្មនៃសន្តិសុខសាធារណៈដែរ។[៣]

នោះគឺក្នុងករណីនៅឥណ្ឌូចិន គឺចាប់តាំងពីឆ្នាំ១៩៤៥ មកទើបកងរាជអាវុធហត្ថត្រូវបានចាប់ផ្តើមធ្វើទំនើបកម្ម។ ការផ្លាស់ប្តូរនេះត្រូវបានធ្វើឡើងក្នុងបរិបទឯករាជ្យរបស់កម្ពុជា។ ជាច្រើន

[២] អនុក្រឹត្យស្តីពីឯកសណ្ឋាន និង ស្លាកសញ្ញាកងរាជអាវុធហត្ថ

[៣] http://www.orange.fr/eugene.bigottehistorique.html

ឆ្នាំនៃការដាក់អាណានិគមនិយម និងអាណាព្យាបាល សាសនា សង្គម និងឧក្រិដ្ឋកម្ម។[៤] ចលនាបោះបោរនៅក្នុងប្រទេសដែលបារាំងត្រួតត្រាក្នុងនោះក៏មានកម្ពុជាផងដែរ នោះបានធ្វើឲ្យជីវភាពសាធារណៈបាត់បង់សណ្តាប់ធ្នាប់ និងបង្កើតនូវការគម្រាមកំហែងមួយចំពោះអំណាចបារាំង។

នៅកម្ពុជា La Gable Indochine បានក្លាយជា La Card Nationale ក្រោយពីកម្ពុជាទទួលបានឯករាជ្យ នាឆ្នាំ១៩៥៥។ កំណែទម្រង់នេះបានកាត់ផ្តាច់ទាំងស្រុងជាមួយនឹងការរៀបចំមុនៗ ហើយបានប្រកាសនូវគោលការណ៍កងរាជអាវុធហត្ថទំនើបឡើង។ មុនឆ្នាំ១៩៥៥ កងរាជអាវុធហត្ថបានបង្កើតឡើងនូវប្រព័ន្ធសមត្ថកិច្ចដ៏ស្មុគ្រស្មាញ សង្កត់ធ្ងន់ដោយចាប់ផ្តើមចេញពីអំណាចរបស់អាណានិគមនិយមបារាំង ប៉ុន្តែតាមការជាក់ស្តែងវិញបំណែកវាងអាជ្ញាធរនៃប្រទេសនីមួយៗនៃឥណ្ឌូចិន។ សន្តិសុខផ្អែកលើមួយផ្នែកធំនៃប្រជាជនដែលខ្លួនត្រួតត្រា។ ប្រព័ន្ធដែលផ្អែកលើប្រពៃណីបារាំង និងលើអំណាចបារាំងគ្មានប្រសិទ្ធភាពទេ។

ជាមួយនឹងកំណែទម្រង់ឆ្នាំ១៩៥៦ កងរាជអាវុធហត្ថស្ថិតនៅក្រោមកណ្តាប់ដៃរបស់យោធា។ La Garde Nationale មាន១៥កងពលតូច។[៥] ១៤ កងពលតូចស្មើនឹង១៤ខេត្ត នៃព្រះរាជាណាចក្រកម្ពុជាបន្ថែមកងពលតូចទី១៥ មានបេសកកម្មឃ្លាំមើល និងការការពារការនេសាទ និងបឹងនានា។ កងពលតូចនីមួយៗមានផ្នែកអន្តរាគមន៍ចល័តមួយ។ កងពលតូចនីមួយៗមានបេសកកម្មធានាសន្តិសុខនៅក្នុងខេត្តរបស់ខ្លួន ហើយការិយាល័យកណ្តាលស្ថិតនៅភ្នំពេញ។ ក្នុងឆ្នាំ១៩៥៧ ចំនួនកងរាជអាវុធហត្ថមានប្រហែល ៣០០០នាក់។ រហូតដល់ឆ្នាំ១៩៥៩ មួយផ្នែកនៃកងរាជអាវុធហត្ថត្រូវធានាដោយបារាំង និងចាប់តាំងពីឆ្នាំ១៩៥៩ ទើបបារាំងប្រគល់កងរាជអាវុធហត្ថមកឲ្យខ្មែរទាំងស្រុង។

## ផ្នែកទី២៖ ប្រវត្តិកងរាជអាវុធហត្ថ

### ១. របបសង្គមរាស្ត្រនិយម (ព្រះរាជាណាចក្រកម្ពុជាទី១ )

ព្រះរាជាណាចក្រកម្ពុជាបានទទួលឯករាជ្យពេញបរិបូរណ៍នៅថ្ងៃទី ០៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ ដោយចលនាតស៊ូរបស់កងទ័ពប្រជារាស្ត្រគ្រប់ស្រទាប់ជាន់ថ្នាក់ ក្រោមរាជបូជនីយកិច្ចដឹកនាំរបស់ ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ ។ ពេលនោះ គឺជាការចាប់ផ្តើមកំនើតពិតប្រាកដនៃកងយោធពលខេមរភូមិន្ទ ។

កងរាជអាវុធហត្ថបានចាប់បដិសន្ធិនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៥៤ ក្នុងដំណាក់កាលពង្រឹងគុណភាពរបស់កងយោធពលខេមរភូមិន្ទ ព្រមជាមួយនឹងការរៀបចំឡើងវិញតាមរយៈការបង្កើតសាលា

[៤] http://www.rrd.org/org/eu/fr/dn/genarmerie/index/html

[៥] http://fr.wikipedia.widi/genarmerie nationale_(france)

បណ្ឌិតសភាយោធា មជ្ឈមណ្ឌលហ្វឹកហ្វឺន មូលដ្ឋានទ័ពអាកាស មានក្រុមអាកាសចរចំនួន៣ក្រុម និងមូលដ្ឋានបណ្តុះបណ្តាលកងទ័ពជើងទឹក ផ្នែកទន្លេ និងផ្នែកសមុទ្រ មានក្រុមកម្មង់ដូរម៉ារីនចំនួន១ក្រុម ព្រមទាំងមានកងរាជអាវុធហត្ថផងដែរ។ ក្រោយមកកងរាជអាវុធហត្ថត្រូវបានបង្កើតជាផ្លូវការតាមព្រះរាជក្រឹត្យលេខ៤៤៦នស និង៤៤៧នស ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៥៧ ដោយត្រូវប្តូរឈ្មោះពីកងតម្រួតទាហានខ្មែរមកជា កងរាជអាវុធហត្ថខ្មែរ (GENDARMERIE ROYALE KHMERE)។[៦] តួនាទី និងភារកិច្ចរបស់កងរាជអាវុធហត្ថ គឺជាប៉ូលិសទាហាន (Police Military=Military Police), ប៉ូលីសរដ្ឋបាល និងប៉ូលិសតុលាការ។ តួនាទី និងភារកិច្ចនេះដូចគ្នានឹងកងរាជអាវុធហត្ថបារាំងដែរ ព្រោះកងរាជអាវុធហត្ថខ្មែរត្រូវបានបង្កើតឡើងតាមលំនាំបារាំង ហើយចាប់ពីពេលនោះមករហូតដល់ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ក្នុងសម័យសង្គមរាស្ត្រនិយមកងយោពលខេមរភូមិន្ទ ដែលក្នុងនោះមានកងរាជអាវុធហត្ថផងដែរ ដែលបានសម្រេចភារកិច្ចការពារជាតិមាតុភូមិ និងការពារសេចក្តីសុខជូនប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព និងនាំឲ្យព្រះរាជាណាចក្រកម្ពុជាមានកិត្យានុភាព ដែលមានឈ្មោះថាជាកោះសន្តិភាពនៅជ្រោយឥណ្ឌូចិន ។

**២. របបសាធារណៈរដ្ឋខ្មែរ ( លន់ ណុល )**

ក្រោយថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ នៅក្នុងសម័យរបបសាធារណរដ្ឋខ្មែរ **លន់ នល់** កងរាជអាវុធហត្ថត្រូវបានផ្លាស់ប្តូរឈ្មោះមកជា កងរាជអាវុធហត្ថជាតិ(GENDARMERIE NATION) តាមក្រឹត្យ ៥៧៤/៧១CE ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៧១ ហើយស្ថិតនៅក្រោមអំណាចរបស់អគ្គបញ្ជាការនៃកងទ័ពជាតិខ្មែរ។ តួនាទី និងភារកិច្ចរបស់កងរាជអាវុធហត្ថជាតិ នេះគឺជាប៉ូលិសទាហាន (Police Military=Military Police), ប៉ូលិសរដ្ឋបាល និងប៉ូលិសតុលាការ ក៏ដូចកងរាជអាវុធហត្ថខ្មែរក្នុងរបបសង្គមរាស្ត្រនិងយមដែរ។

**៣. របបកម្ពុជាប្រជាធិតេយ្យ ( ខ្មែរក្រហម )**

នៅក្នុងរបបកម្ពុជាប្រជាធិតេយ្យពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ កម្លាំងកងរាជអាវុធហត្ថត្រូវបានរំលាយចោលដូចបណ្តាលស្ថាប័នដទៃទៀតដែរ គឺពុំមានកងរាជអាវុធហត្ថទេ ។

**៤. របបសាធារណៈរដ្ឋប្រជាមានិតកម្ពុជា (រដ្ឋកម្ពុជា)**

ក្រោយថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ រហូតមកដល់កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩៣ ក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា គ្មានកម្លាំងកងរាជអាវុធ

---

[៦] ព្រះរាជក្រឹត្យលេខ ៤៤៦នស និង៤៤៧នស

ហាត្ថទេ គឺមានតែកម្លាំងតម្រួតយោធាដែលធ្វើកិច្ចការខាងត្រួតត្រាលើបទបញ្ជា និងការត្រួតពិនិត្យវិន័យយោធាតែប៉ុណ្ណោះ។

### ៥. ព្រះរាជាណាចក្រកម្ពុជាទី២

ក្រោយពីមានកិច្ចចរចាស្វែងរកសន្តិភាពជាច្រើនលើកច្រើនសាររវាង សម្តេចហ៊ុន សែន និងព្រះបាទព្រះករុណាសម្តេចព្រះនរោត្តម សីហនុ ដើម្បីបង្រួបបង្រួមផ្សះផ្សារជាតិ ក្នុងគោលបំណងបញ្ចប់សង្គ្រាមនៅកម្ពុជា ដោយមានការអន្តរាគមន៍យ៉ាងពេញទំហឹងពីសំណាក់អង្គការសហប្រជាជាតិ និងសហគមន៍អន្តរជាតិបានឈានទៅដល់ការចុះកិច្ចព្រមព្រៀងសន្តិភាពនៅទីក្រុងប៉ារីស នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១។ បន្ទាប់មកកម្លាំងកងរាជអាវុធហត្ថនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានបង្កើតសាជាថ្មីក្រោមព្រះរាជតម្រិះរបស់ ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ដែលបានសំណូមពរដល់រាជរដ្ឋាភិបាលបារាំងឲ្យជួយឧបត្ថម្ភ។ រដ្ឋាភិបាលបារាំងបានយល់ព្រមតាមព្រះរាជសំណើ ហើយបានចាត់ទុកកងរាជអាវុធហត្ថជាប្អូនស្រីបង្កើតរបស់ខ្លួនទៀតផង។ ក្រោយពីការបោះឆ្នោតសកលឆ្នាំ១៩៩៣ នៅក្នុងរបបព្រះរាជាណាចក្រកម្ពុជា កងរាជអាវុធហត្ថត្រូវបានបង្កើតសាជាថ្មីឡើងវិញតាមក្រឹត្យចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៩៣ រួមជាមួយការបង្កើតអគ្គសេនាធិការនៃកងទ័ពជាតិកម្ពុជា ឡាយព្រះហត្ថលេខាដោយសម្តេចព្រះ នរោត្តម សីហនុ។

អគ្គសេនាធិការនៃកងយោពលខេមរភូមិន្ទបានចាប់ផ្តើមរៀបចំកងរាជអាវុធហត្ថ ដោយបានធ្វើពិធីប្រកាសផ្លូវការនៅ ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៣។ នៅគ្រាដំបូង កងរាជអាវុធហត្ថមានកម្លាំងចំនួន ២៤៧នាក់ ដែលដឹកនាំបញ្ជាដោយលោក ឧត្តមសេនីយ៍ទោ កែវ សាមួន។

វគ្គបណ្តុះបណ្តាលកងរាជអាវុធហត្ថជំនាន់ទី១ ត្រូវបានចាប់ផ្តើមឡើងនៅថ្ងៃទី០៩ ខែសីហា ឆ្នាំ១៩៩៣ ហើយបញ្ចប់នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៩៣ ដែលមានសិក្ខាកាមចំនួន១២៤រូប ដោយមានការគាំទ្រ និងជួយឧបត្ថម្ភពីអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា (អ៊ុនតាក់) ដែលក្នុងនោះមានបណ្តាប្រទេសជាច្រើនផងដែរ។

ចំណែកកងឯកភាពកងរាជអាវុធហត្ថត្រូវបានប្រកាសជាផ្លូវការនៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ហើយរាជរដ្ឋាភិបាលបានចេញនូវអនុក្រឹត្យលេខ២៥ អ.ន.ក្រ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩៤ និងក្រោយមកទៀតចេញនូវអនុក្រឹត្យលេខ៧៧ អ.ន.ក្រ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៩៤ ស្តីពីភារកិច្ច និងរចនាសម្ព័ន្ធទូទៅនៃកងរាជអាវុធហត្ថ ក្នុងគោលបំណងផ្តល់សិទ្ធិអំណាច និងកំណត់ដែនសមត្ថកិច្ចព្រមទាំងការទទួលខុសត្រូវ ដោយត្រូវស្ថិតនៅក្នុងក្របខ័ណ្ឌច្បាស់លាស់។ បច្ចុប្បន្នកងរាជអាវុធហត្ថ

បានពង្រាយកម្លាំង និងបង្កើតទីបញ្ជាការដ្ឋានរបស់ខ្លួនទូទាំងប្រទេស គ្រប់ខេត្ត/រាជធានី/ស្រុក/ក្រុង/ខណ្ឌ និងក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

ទន្ទឹមនឹងនោះដែរមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេសត្រូវបានផ្លាស់ប្តូរដូចតទៅ៖

-លោក ឧត្តមសេនីយ៍ទោ កែវ សាមួន ត្រូវបានទទួលមុខតំណែងជាមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេសចាប់ពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ដល់ថ្ងៃទី២៤ ខែឧសភា ឆ្នាំ១៩៩៤។

-លោក ឧត្តមសេនីយ៍ទោ គៀង សាវុធ ត្រូវបានទទួលមុខតំណែងជាមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេសចាប់ពីថ្ងៃ២៤ ខែឧសភា ឆ្នាំ១៩៩៤ ដល់ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៩៩។

-លោក ឧត្តមសេនីយ៍ត្រី សៅ សុខា ជាមេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស ត្រូវបានតែងតាំងជាមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស និងដំឡើងឋានន្តរស័ក្តិថ្នាក់ឧត្តមសេនីយ៍ទោ នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ១៩៩៩។

# ជំពូកទី ២

## រចនាសម្ព័ន្ធចាត់តាំងបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

# ជំពូកទី ២

# រចនាសម្ព័ន្ធចាត់តាំងបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

## ផ្នែកទី១ ៖ រចនាសម្ព័ន្ធ និងតួនាទី ភារកិច្ច កងរាជអាវុធហត្ថលើផ្ទៃប្រទេស

### ១.សមិទ្ធិផលការងាររបស់កងរាជអាវុធហត្ថ

ដោយកងរាជអាវុធហត្ថជាកំលាំងអព្យាក្រឹត្យ មានកាតព្វកិច្ចការពារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ធានាសុខសាន្តជូនប្រជាពលរដ្ឋ និងរាជរដ្ឋាភិបាល ដោយប្រឆាំងដាច់ខាតគ្រប់ចំពោះទង្វើណាមួយដែលបង្កអស្ថេរភាពដល់សង្គម ប៉ះពាល់ដល់សន្តិសុខជាតិ។ កងរាជអាវុធហត្ថគឺជាអ្នកបម្រើការងារជូនប្រជារាស្ត្រ និងស្ថាប័នទាំងឡាយនៃព្រះរាជាណាចក្រកម្ពុជា ប្រកបដោយសក្តានុភាព និងតម្លាភាព។ ឆ្លងកាត់ការអប់រំ បណ្តុះបណ្តាល ហ្វឹកហ្វឺនជំនាញឯកទេស និងវិជ្ជាជីវៈជាមូលដ្ឋាននោះ កងរាជអាវុធហត្ថបង្កើតបាននូវសមត្ថភាព ចំណេះដឹង ពិតប្រាកដជាមួយនឹងវិស័យច្បាប់ ព្រមទាំងនីតិវិធីទាំងឡាយដោយទទួលបាននូវនីតិសម្បទាន និងលក្ខណៈសម្បត្តិគ្រប់គ្រាន់ ឆ្លើយតបតាមតម្រូវការ។

នាយករដ្ឋមន្ត្រីជាអ្នកបញ្ជាផ្ទាល់លើកំលាំងកងរាជអាវុធហត្ថ ហើយស្ថិតនៅក្រោមការគ្រប់គ្រងដឹកនាំរបស់ក្រសួងការពារជាតិ និងអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ។ ជាពិសេសដោយមានការគ្រប់គ្រងដឹកនាំបញ្ជាផ្ទាល់ប្រកបដោយទេពកោសល្យដ៏ប៉ិនប្រសប់ និងមានភាពឈ្លាសវៃ របស់មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស កងរាជអាវុធហត្ថក្លាយជាកំលាំងមួយជោគជ័យ ស្ទិតស្ទាញដោយបានបំពេញនូវតួនាទី និងភារកិច្ចរបស់ខ្លួន ផ្អែកលើគោលការណ៍ច្បាប់ និងវិធានការណ៍ទាំងឡាយដែលបានកំណត់ កងរាជអាវុធហត្ថបានរួមចំណែកយ៉ាងសកម្មបំផុត ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងភារកិច្ចការពារ កសាង និងអភិវឌ្ឍន៍ប្រទេសជាតិ ដោយទប់ស្កាត់បង្ក្រាបនូវបទល្មើសទាំងឡាយដែលប្រឆាំងនឹងសង្គម។[៧] លទ្ធផលលេចធ្លោជាក់ស្តែង គឺការរក្សាបានស្ថេរភាពនយោបាយ ការពារសន្តិភាព សណ្តាប់ធ្នាប់សាធារណៈសង្គម ផ្តល់នូវភាពសុខដុមរមនា ជូនប្រជាពលរដ្ឋ ជូនជាតិមាតុភូមិ ដោយសម្រេចបានជោគជ័យ និងទទួលបានសមិទ្ធិផលស្នាដៃយ៉ាងច្រើនគួរជាទីមោទនៈ។

### ២.ភារកិច្ចរបស់កងរាជអាវុធហត្ថលើផ្ទៃប្រទេស

#### ២.១ រ៉ាប់រងសកម្មភាពខាងប៉ូលីសរដ្ឋបាល

ក្នុងនាមជាអ្នករក្សាការពារ និងបម្រើផលប្រយោជន៍លើវិស័យរដ្ឋបាលទូទៅ

[៧] មាត្រា១ អនុក្រឹត្យលេខ៧៧ អនក្រ.បក ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៩៤ ស្តីពីភារកិច្ច និងរចនាសម្ព័ន្ធទូទៅនៃកងរាជអាវុធហត្ថ

បេសកកម្មនេះ គឺត្រូវធ្វើការត្រួតពិនិត្យជាអចិន្ត្រៃយ៍នៅតំបន់ដែលកងរាជអាវុធហត្ថបោះទីតាំង ដើម្បីថែរក្សាសុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈនៅក្នុងផ្នែកផ្សេងៗនៃជីវភាពសង្គម។ ជួនកាលកងរាជអាវុធហត្ថបានធ្វើសកម្មភាពបង្ការនូវភាពរំខានដល់សណ្តាប់ធ្នាប់សាធារណៈ និងបញ្ចប់ភាពរំខាននោះដោយប្រតិបត្តិការរបស់ខ្លួន ភារកិច្ចជាប៉ូលិសរដ្ឋបាល គឺចូលរួមយ៉ាងសកម្មក្នុងការរៀបចំថែរក្សា របៀបរៀបរយ សណ្តាប់ធ្នាប់សាធារណៈ ធ្វើឲ្យសន្តិសុខសណ្តាប់ធ្នាប់សង្គមត្រូវបានពង្រឹង និងជួយសង្គ្រោះប្រជាពលរដ្ឋគ្រប់ពេលវេលា កងរាជអាវុធហត្ថរ៉ាប់រងឲ្យមានការគោរពច្បាប់ និងបទបញ្ជាទាំងឡាយ ធ្វើឲ្យមានស្ថេរភាពល្អប្រសើរជាបន្តបន្ទាប់ លទ្ធផលលេចធ្លោមានដូចជាការការពារដំណើរការបោះឆ្នោតសកលជ្រើសរើសតំណាងរាស្ត្រ ការបោះឆ្នោតជ្រើសរើសមេឃុំចៅសង្កាត់ ឲ្យប្រព្រឹត្តទៅយ៉ាងរលូន និងជោគជ័យប្រកបដោយតម្លាភាព ប្រជាធិបតេយ្យសេរី យុត្តិធម៌ និងគ្មានអំពើហិង្សា។ ជាមួយគ្នានេះក៏បានចូលរួមការពារពិធីបុណ្យជាតិ និងអន្តរជាតិ ពិធីតាំងពិពណ៌មហោស្រពធំៗកម្រិតជាតិ និងអន្តរជាតិ។ ជាពិសេសការពារកិច្ចប្រជុំកំពូលធំៗថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ ទីតាំងក្នុងរាជធានី ក៏ដូចជាខេត្តមួយចំនួន ព្រមទាំងជួយសម្រាលចរាចរណ៍ និង ការពារដំណើរចេញចូលនៃគណៈប្រតិភូជាតិ និងអន្តរជាតិ ដោយទទួលបានលទ្ធផលល្អប្រសើរប្រកបដោយសន្តិសុខ និងសុវត្ថិភាពល្អ។

បន្ថែមពីនេះទៅទៀតនៅក្នុងការងាររដ្ឋបាលកងរាជអាវុធហត្ថ មានភារកិច្ចថែរក្សាសុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈដែលមានដូចជា៖ សន្តិសុខសាធារណៈ ភាពស្ងប់ស្ងាត់សាធារណៈ និងសុខុមាលភាពសាធារណៈ ធានារ៉ាប់រងឲ្យមានការគោរពច្បាប់ និងបទបញ្ជាផ្សេងៗ ព្រមទាំងផ្តល់ព័ត៌មាន និងជួយសង្គ្រោះប្រជាជន។

នៅក្នុងក្របខ័ណ្ឌនៃភារកិច្ចនេះ កងរាជអាវុធហត្ថអនុវត្តតាមបញ្ជារបស់មន្ត្រីក្រសួងមហាផ្ទៃ និងអាជ្ញាធររដ្ឋបាលមានសមត្ថកិច្ចដូចជា គណៈអភិបាលរាជធានី ខេត្ត អភិបាលក្រុង ស្រុក ខណ្ឌ។ល។

### ២.២ វិបរិសមកម្មភាពខាងប៉ូលិសតុលាការ

ប៉ូលិសតុលាការ អាចមានន័យថា កងរាជអាវុធហត្ថជានគរបាលយុត្តិធម៌ ព្រោះនៅក្នុងនីតិវិធីព្រហ្មទណ្ឌបានផ្តល់នីតិសម្បទាតាមក្រមនីតិវិធីព្រហ្មទណ្ឌជាមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារយុត្តិធម៌ដល់នាយទាហាននៃកងរាជអាវុធហត្ថ នៅពេលដែលបានបំពេញលក្ខខណ្ឌដែលបានចែងក្នុងក្រមនេះ។ ក្នុងឋានៈជាអ្នករក្សាការពារ និងបម្រើផលប្រយោជន៍លើវិស័យយុត្តិធម៌ និងតុលាការ ក៏ដូចជាការទប់ស្កាត់នូវអំពើទាំងឡាយនានាដែលរំលោភបំពានច្បាប់ ក៏ដូចជាការបង្ក

អសន្តិសុខដល់សង្គម។ កងរាជអាវុធហត្ថមានតួនាទី និងភារកិច្ចរបស់ខ្លួនប្រកបដោយការទទួលខុសត្រូវខ្ពស់ ក្នុងការអនុវត្តសាលក្រម និងដីកាទាំងឡាយរបស់តុលាការបានយ៉ាងសស្រាក់សស្រាំ ប្រកបដោយសុចរិតភាពត្រឹមត្រូវ និងហ្មត់ចត់ និងធ្វើការត្រួតពិនិត្យបទល្មើសព្រហ្មទណ្ឌ មានដូចជាបទឧក្រិដ្ឋ បទមជ្ឈឹម និងបទលហុ ទទួលពាក្យបណ្ដឹង និងកំណត់អត្តសញ្ញាណ ប្រមូលភស្តុតាងដើម្បីឈានទៅដល់ការចាប់ជនល្មើសបញ្ជូនទៅតុលាការ។

ក្នុងក្របខណ្ឌនៃកិច្ចការនេះ កងរាជអាវុធហត្ថអនុវត្តតាមបញ្ជារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អង្គការអយ្យការ និងអាជ្ញាធរមានសមត្ថកិច្ចដូចជាអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ព្រះរាជាអាជ្ញាអមសាលាដំបូងរាជធានី ខេត្ត ចៅក្រមស៊ើបសួរ...។

**២.៣ បំពេញបេសកកម្មដែលមានលក្ខណៈពិសេសខាងយោធា**

មុខងារនេះ សមត្ថកិច្ចកងរាជអាវុធហត្ថបានពង្រាយកំលាំងការពារទីតាំងសំខាន់របស់កងទ័ពនៅតាមព្រំដែន និងកិច្ចការ ប៉ូលិសយោធានៅក្នុង និងក្រៅទីតាំងកងទ័ព ការពារសន្តិសុខ សុវត្ថិភាពជូនឥស្សរជនជាន់ខ្ពស់បានទទួលជោគជ័យផងដែរ។ ម្យ៉ាងទៀតបានធ្វើការត្រួតពិនិត្យ កែសម្រួលអប់រំយោធិនខ្វះវិន័យ ធ្វើការឃាត់ខ្លួន អប់រំប្រជាពលរដ្ឋប្រើប្រាស់ឯកសណ្ឋានយោធា ត្រួតពិនិត្យមធ្យោបាយធ្វើដំណើរ និងស្លាកលេខកងយោពលខេមរភូមិន្ទគ្រប់ប្រភេទ ធ្វើការត្រួតពិនិត្យអាវុធជាតិផ្ទុះ ការដាក់ប៉ុស្ដិ៍អាណាធិបតេយ្យ ទប់ស្កាត់ការប្រើប្រាស់អាវុធខុសច្បាប់ ព្រមទាំងធ្វើការដកហូតសម្ភារៈបរិក្ខាយោធា និងសម្ភារៈសឹកខុសច្បាប់ដោយទទួលបានស្នាដៃនឹងលទ្ធផលល្អយ៉ាងច្រើន។

បន្ថែមនៅក្នុងភារកិច្ចពិសេសរបស់កងរាជអាវុធហត្ថនៅក្នុងវិស័យយោធាមានៈ

- ការពារទីតាំងយោធា
- ទទួលបន្ទុករក្សាសុវត្ថិភាព និងបំពេញតួនាទីជាកងកិត្តិយសជាប្រយោជន៍ដល់ស្ថាប័នរាជរដ្ឋាភិបាល និងអាជ្ញាធរជាន់ខ្ពស់នៃព្រះរាជាណាច្រកកម្ពុជា។
- កិច្ចការប៉ូលិសយោធាទាំងក្នុង និងក្រៅទីតាំងកងទ័ព

ក្នុងក្របខ័ណ្ឌនៃភារកិច្ចនេះ កងរាជហត្ថអនុវត្តតាមបញ្ជារបស់មន្ត្រីក្រសួងការពារជាតិ នាយអគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ និងអាជ្ញាធរមានសមត្ថកិច្ច។

ក្រៅពីភារកិច្ចខាងលើនេះ កងរាជអាវុធហត្ថផ្ដល់កម្លាំងទៅជួយក្រសួងនានា ដែលបានស្នើសុំតាមសេចក្ដីត្រូវការជាចាំបាច់។

### ២.៤ បេសកកម្មផ្នែកប៉ូលិសពិសេស

បេសកកម្មផ្នែកប៉ូលិសពិសេស គឺជាភារកិច្ចដែលត្រូវអនុវត្តជាអចិន្ត្រៃយ៍ ចំណែកឯបេសកកម្មដែលមានលក្ខណៈពិសេស គឺជាកិច្ចការពិសេសមួយដែលរាជរដ្ឋាភិបាលប្រគល់ជូនកងរាជអាវុធហត្ថតាមរយៈអនុក្រឹត្យ។ ឧទាហរណ៍ៈ ការចុះបង្ក្រាបការនេសាទ និងការកាប់ទន្ទ្រានព្រៃលិចទឹកជាដើម។

### ២.៥ ផ្តល់កម្លាំងទៅជួយក្រសួងនានា

កងរាជធាវុធហត្ថជាកំលាំងរបស់រដ្ឋ ដែលមានភារកិច្ចបម្រើប្រយោជន៍ឲ្យសង្គមដោយឈរលើឧត្តមប្រយោជន៍ជាតិខ្ពស់។ ក្នុងនោះដែរកងរាជអាវុធហត្ថបានផ្តល់កំលាំង ដើម្បីធ្វើកិច្ចសហការជាមួយស្ថាប័នផ្សេងៗ មានដូចជាៈ ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (គយ និងរដ្ឋាករ) ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ក្រសួងសុខាភិបាល ក្រសួងព័ត៌មាន ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងកិច្ចការនារី ក្រសួងបរិស្ថាន អង្គការយ៉ាយអេដ និងអង្គការស៊ីអាយ។ ជាក់ស្តែងក្នុងកិច្ចសហប្រតិបត្តិការនេះទទួលបាននូវភាពជោគជ័យច្រើន ដោយការបង្ក្រាបបានចំពោះបទល្មើសគេចពន្ធ ករណីបទល្មើសជលផល បទល្មើសនេសាទខុសបទដ្ឋាន ករណីចរាចរថ្នាំពេទ្យក្លែងក្លាយ ករណីលួចប្រើប្រាស់បណ្តាញទូរស័ព្ទខុសច្បាប់ ករណីបទល្មើសព្រៃឈើ ការកាប់រានទន្ទ្រានព្រៃយកខុសច្បាប់ និងបទល្មើសសត្វព្រៃ។

ទន្ទឹមនឹងលទ្ធផលជាតិ មោទនៈខាងលើនេះ អគ្គបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេសបានជម្រុញយ៉ាងសកម្មបំផុតក្នុងការងារបណ្តុះបណ្តាល បំប៉នជំនាញ និងហ្វឹកហ្វឺនរៀនសូត្រទាំងក្នុង និងក្រៅប្រទេស ទាំងផ្នែកច្បាប់ ផ្នែកជំនាញឯកទេស ក៏ដូចជាភាសាបរទេសដល់នាយ និងពលអាវុធហត្ថ ដើម្បីលើកកំពស់សមត្ថភាពក្នុងការអភិវឌ្ឍន៍ធនធានមនុស្ស។

### ក.បេសកកម្មទប់ស្កាត់ និង បង្ក្រាប

បេសកកម្មក្នុងការទប់ស្កាត់ និងបង្ក្រាបបានជោគជ័យ ចំពោះបាតុកម្មប្រើអំពើហិង្សាដុតកម្ទេចស្ថានទូតថ្ងៃទី២៩-៣០ ខែមករា ឆ្នាំ២០០៣។ ការធ្វើបាតុកម្មហិង្សាដុតកម្ទេចរោងចក្រកាត់ដេរ តេវ៉ាតិច ចាក់អង្រែ ឆ្នាំ២០០៣។ ករណីចាប់ជម្រិតមនុស្សគម្រាមទារប្រាក់នៅស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ ឆ្នាំ២០០៣ និងករណីចាប់ជម្រិតទារប្រាក់លើសិស្សសាលាមត្តេយ្យអន្តរជាតិ ខេត្តសៀមរាបកាលពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៥។ ករណីជ្រើសរើសទ័ពខុសច្បាប់ប្រឆាំងបទបញ្ជាអគ្គមេបញ្ជាការ និងសមគំនិតបង្កើតជនប្រដាប់អាវុធ ឆ្នាំ២០០៤-២០០៥ ព្រមទាំង

បានចូលរួមចំណែកក្នុងការការពារ សន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ ក្នុងកិច្ចប្រជុំកំពូលអាស៊ានធំៗ នៅក្នុងប្រទេស និងការពាររាល់ដំណើរទស្សនកិច្ចរបស់ប្រតិភូជាន់ខ្ពស់ជាតិ អន្តរជាតិ ដោយទទួលបានសន្តិសុខ និងមានសុវត្ថិភាពល្អ។ ជាមួយគ្នានេះផងដែរ ដោយឈរលើស្មារតីមនុស្សធម៌ និងដើម្បីបម្រើប្រយោជន៍ឲ្យសង្គមក៏ដូចជាការជួយរំលែកទុក្ខលំបាករបស់ប្រជាពលរដ្ឋ កងកំលាំងកងរាជអាវុធហត្ថចូលរួមយ៉ាងសកម្ម និងទាន់ពេលវេលាក្នុងការសង្គ្រោះ ប្រជាពលរដ្ឋដែលរងគ្រោះដោយគ្រោះធម្មជាតិ គ្រោះទឹកជំនន់ គ្រោះរាំងស្ងួត អគ្គីភ័យ និងគ្រោះមហន្តរាយផ្សេងៗ។ ដូចគ្នានេះដែរ ក៏បានរួមចំណែកក្នុងការជួយទប់ស្កាត់ និងបង្ក្រាបក្រុមក្មេងពាលដែលបង្កអស្ថេរភាពក្នុងសង្គម ព្រមទាំងជួយអប់រំ និងបន្សាបសារធាតុញៀននៅមណ្ឌលអប់រំកងរាជអាវុធហត្ថបាត់ដំបង និងខេត្តបន្ទាយមានជ័យ ចំពោះអ្នកញៀនគ្រឿងញៀនឲ្យជាសះស្បើយ ហើយវិលត្រឡប់ទៅលំនៅដ្ឋានវិញ និងកំពុងធ្វើការអប់រំបន្សាបសារធាតុញៀនបន្តទៀត។ កត្តាដែលបណ្តាលឲ្យសម្រេចបានជោគជ័យនូវភារកិច្ចធំៗទាំងអស់នេះ គឺជាលទ្ធផលនៃកិច្ចប្រតិបត្តិការរបស់កងរាជអាវុធហត្ថក្នុងការធ្វើសកម្មភាពបានចំគោលដៅ ដោយរក្សាវិន័យបានខ្ជាប់ខ្ជួនមានសីលធម៌ អត្តចរិកថ្លៃថ្នូរមានភាពឈ្លាសវៃ មានស្មារតីចេះគិតចេះធ្វើ និងចេះទទួលខុសត្រូវដោយឈរលើខ្លឹមសារ ប្រឡងប្រណាំងទូទាំងកងរាជអាវុធហត្ថរបស់អង្គភាពនីមួយៗ ក៏ដូចជារបស់នាយ និងពលអាវុធហត្ថម្នាក់ៗ។

**ខ.បេសកកម្មក្រៅប្រទេស**

ជាបន្តបន្ទាប់កងរាជអាវុធហត្ថកាន់តែមានបេសកកម្មយ៉ាងធំធេង និងឧត្តុងឧត្តមថ្លៃថ្លា។ ដោយមានការជឿជាក់ និងទំនុកចិត្តពីប្រមុខរដ្ឋាភិបាល ក៏ដូចជាបណ្តាលក្រសួងស្ថាប័ននានាបានស្នើសុំកំលាំងកងរាជអាវុធហត្ថ ដើម្បីឲ្យចូលរួមក្នុងការងារនៃកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរជាតិ ព្រមទាំងផលប្រយោជន៍ជូនជាតិមាតុភូមិ និងប្រជាពលរដ្ឋច្រើនសន្ធឹកសន្ធាប់។ ជាពិសេសដោយមានជំនឿជឿជាក់យ៉ាងមុតមាំ និងមានទំនុកចិត្តយ៉ាងខ្លាំងក្លាពីអន្តរជាតិ កំលាំងកងរាជអាវុធហត្ថត្រូវបានជ្រើសរើសជាអាទិភាពក្នុងក្របខណ្ឌនៃកងយោពលខេមរភូមិន្ទ ដើម្បីឲ្យបំពេញបេសកកម្មក្រៅប្រទេសក្រោមទង់អង្គការសហប្រជាជាតិ ដែលហៅកាត់ថាកិច្ចរក្សាសន្តិភាពសម្រាប់កិច្ចការមនុស្សធម៌ និងកិច្ចការដទៃទៀត។ ក្នុងនោះមានដូចជា៖ អ្នកសង្កេតការណ៍នៅប្រទេសស៊ូដង់ និងការផ្តល់កំលាំងទៅប្រទសទីម័រខាងកើត ព្រមទាំងផ្តល់កំលាំងទៅធ្វើការសមយុទ្ធនៅប្រទេសម៉ុងហ្គោលី កាលពីពេលកន្លងទៅនេះ។ គឺក្នុងបេសកកម្មនៃកិច្ចសហប្រតិបត្តិការចំណុចត្រួតពិនិត្យ ការល្បាត ការចែកជំនួយមនុស្សធម៌ ការយាមកាមទីតាំងចល័ត កិច្ចប្រតិបត្តិការរថយន្តដឹកជញ្ជូន និងការឡោមព័ទ្ធមិនឲ្យមានការចេញចូល និងឆែកឆេរ។ សមិទ្ធិផលដ៏ធំធេង

ទាំងនេះ គឺជាភារកិច្ចយ៉ាងសំខាន់ និងចាំបាច់តម្រូវឲ្យកងរាជអាវុធហត្ថជាតិ មានកាតព្វកិច្ចដ៏ឧត្តុង្គឧត្តមដើម្បីបំពេញករណីយកិច្ចនេះ។ ក្នុងនោះផងដែរជាគោលការណ៍របស់រាជរដ្ឋាភិបាល ក្នុងការបញ្ជូនកំលាំងទៅក្រៅប្រទេសមាន ៤ចំណុចសំខាន់គឺ៖

១-កំលាំងនេះមិនមែនជាកំលាំងទៅធ្វើការវាយប្រយុទ្ធ ឬជាកំលាំងដែលបំពេញភារកិច្ចមនុស្សធម៌សម្រាប់កិច្ចរក្សាសន្តិភាព។

២-កំលាំងទាំងនេះមិនមែនក្លាយទៅជាកំលាំងឈ្លានពាន និងមិនមែនជាកំលាំងដែលប្រឆាំង ឬក៏គាំទ្រចំពោះភាគីណាមួយនៅក្នុងប្រទេសដែលខ្លួននឹងទៅប្រតិបត្តិការនោះទេ។

៣-កំលាំងទាំងនេះនៅថែរក្សាស្មេរភាព ជាកំលាំងរបស់អង្គការសហប្រជាជាតិផងនិងជាអត្តិភាពសញ្ញាណដើមរបស់កងយោពលខេមរភូមិន្ទ ដែលជាតំណាងរបស់កម្ពុជាទាំងមូល។

៤-ក្រៅពីការបំពេញបេសកកម្មមនុស្សធម៌រក្សាសន្តិភាព កំលាំងនេះគឺជាកំលាំងដែលគាំទ្រកិច្ចការសង្គមផ្សេងៗ ដូចជាការជួយប្រជាជននៅមូលដ្ឋានដែលខ្លួនបានទៅសាងសង់ ការជួយពិនិត្យសុខភាព ការផ្តល់ស្បៀង ការផ្តល់ទឹក និងអ្វីដែលអាចធ្វើទៅបាន។ នេះជាទស្សនៈវិស័យ និងជាគោលការណ៍សំខាន់បំផុត ដែលកំលាំងនេះត្រូវប្រតិបត្តិនៅក្នុងបេសកកម្មនៃប្រតិបត្តិការរបស់ខ្លួននៅក្រៅប្រទេស។ ជាមួយគ្នានេះដែរ ដោយឃើញពីសមត្ថភាពប្រកបដោយសក្កានុពលរបស់កងរាជអាវុធហត្ថទើបសហរដ្ឋអាមេរិចបានស្នើសុំធ្វើការឧបត្ថម្ភគាំទ្រដល់កងរាជអាវុធហត្ថជាតិ ក្នុងការរៀបចំបង្កើតនូវកងអនុសេនាធំប្រឆាំងភេរវកម្មមួយអង្គភាពផងដែរ។

ដូច្នេះសមិទ្ធិផលដ៏ធំធេងត្រចេះត្រចង់ ដែលកងរាជអាវុធហត្ថជាតិទទួលបាន គឺជាលទ្ធផលជោគជ័យនៃការខិតខំប្រឹងប្រែងយកចិត្តទុកដាក់បំពេញបេសកកម្មរបស់ខ្លួន ដោយស្ថិតក្នុងក្របខណ្ឌច្បាប់ និងនីតិវិធីទាំងឡាយ ដោយគោរពម៉ឺងម៉ាត់ទាំងអំណាចឋានានុក្រមការងារ ព្រមជាមួយគ្នានឹងការតស៊ូព្យាយាមអំណត់អត់ធន់ជំនះរាល់ឧបសគ្គ ការលំបាកដោយហ៊ានលះបង់សាច់ស្រស់ឈាមស្រស់ ដើម្បីបុព្វហេតុជាតិ មាតុភូមិ និងប្រជារាស្ត្រខ្មែរទាំងមូល។ កត្តាទាំងអស់នេះហើយ ដែលបានរុញច្រានឲ្យកងរាជអាវុធហត្ថជាតិ ដណ្តើមបាននូវបេះដូង និងក្តីស្រឡាញ់ពេញចិត្ត ព្រមទាំងការគាំទ្រយ៉ាងពេញទំហឹងពីសំណាក់ប្រជាពលរដ្ឋគ្រប់មជ្ឍដ្ឋាន ជាមួយគ្នានឹងការមានទំនុកចិត្តយ៉ាងមុតមាំ និងមានការជឿជាក់បំផុតពីរាជរដ្ឋានភិបាលផងដែរ។ ទាំងនេះគឺជាគុណសម្បត្តិដ៏ធំធេង ថ្លៃថ្លា របស់កងរាជអាវុធហត្ថជាតិ ហើយក៏ជាការរួមចំណែកលើកតំកើងកិត្តិនាម និងសេចក្តីថ្លៃថ្នូររបស់កងយោធពលខេមរភូមិន្ទ ព្រមទាំងជាកត្តារួមចំណែកក្នុងការផ្តល់នូវឧត្តមប្រយោជន៍ចំពោះរាជរដ្ឋាភិបាល ក៏ដូចជាប្រជាពលរដ្ឋ និងប្រទេសជាតិទាំងមូល ឲ្យទទួលបាន

នូវកិត្តិយស កិត្យានុភាពដ៏ល្បីរន្ទឺសុះសាយ និងមោទនភាពជាតិខ្ពស់បំផុត។ កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់កងយោពលខេមរភូមិន្ទ និងក្រសួងការពារជាតិផងដែរ ហើយជាពិសេស គឺរក្សាបាននូវឧត្តមភាពកិត្តិស័ព្ទដ៏ល្បីល្បាញនៃសម្តេចនាយករដ្ឋមន្ត្រី ដែលជាប្រមុខរាជរដ្ឋាភិបាល និងក្នុងនាមជាអ្នកបញ្ជាផ្ទាល់លើស្ថាប័ននៃកងរាជអាវុធហត្ថជាតិ។

ស្របតាមកាលៈទេសៈបច្ចុប្បន្ន ដែលរាជរដ្ឋាភិបាលបាលនឹងកំពុងធ្វើការកែទម្រង់គ្រប់ផ្នែក ជាពិសេសគឺសេដ្ឋកិច្ច សង្គមកិច្ច និងការអភិវឌ្ឍន៍ផ្នែកធនធានមនុស្ស ឲ្យស្របតាមគោលការណ៍នៃការធ្វើសមាហរណកម្មទៅក្នុងតំបន់ និងនិន្នាការសាកលនីយកម្ម ដើម្បីអភិវឌ្ឍន៍សង្គម និងរក្សាសន្តិសុខសណ្តាប់ធ្នាប់ជូនប្រជាពលរដ្ឋ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេសបានអនុវត្តនូវភារកិច្ចរបស់ខ្លួនទទួលលទ្ធផលបានយ៉ាងច្រើនជូនប្រទេសជាតិ និងប្រជាពលរដ្ឋ។ ដោយកំលាំងកងរាជអាវុធហត្ថភាគច្រើនមានជំនាញវិជ្ជាជីវៈត្រឹមត្រូវ និងមានបទពិសោធន៍ខ្ពស់ក្នុងសកម្មភាពការងារនាពេលកន្លងមក បានធ្វើឲ្យបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេសសម្រេចបានជោគជ័យលើការងារដែលក្រសួង និង រាជរដ្ឋាភិបាលបានប្រគល់ឲ្យគួរជាទីមោទនៈ។ លទ្ធផលដែលទទួលបានដ៏ធំធេងនេះ បានបង្ហាញឲ្យឃើញថា បញ្ជាការដ្ឋានបានប្រើប្រាស់ធនធានមនុស្សរបស់ខ្លួនដែលសុទ្ធតែជាអ្នកមានជំនាញវិជ្ជាជីវៈខ្ពស់ និងមានសមត្ថភាពខ្ពស់ ហើយវាជាកត្តាបញ្ជាក់ពីប្រសិទ្ធភាពខ្ពស់នៃគុណភាពការងាររបស់កងកំលាំងទាំងអស់ ព្រមទាំងបានផ្តល់នូវភាពជឿជាក់ក្នុងកំរិតខ្ពស់បំផុត។ ម្យ៉ាងទៀតនៅចំពោះមុខសភាពការណ៍វិវត្តន៍របស់ពិភពលោកបច្ចុប្បន្ន កងកំលាំងភាគច្រើនសុទ្ធតែបានអភិវឌ្ឍន៍នូវអាជីពរបស់ខ្លួន ដោយបានចូលរួមក្នុងវគ្គបំប៉ន វគ្គបណ្តុះបណ្តាលជំនាញឯកទេស និងបន្តការសិក្សាបន្ថែមទៀត ដើម្បីបង្កើនកម្រិតវិជ្ជាជីវៈ និង ទំនាក់ទំនងដែលមានប្រយោជន៍ដល់បញ្ជាការដ្ឋានស្ថាប័នខាងក្រៅ និងសង្គម ហើយជាកត្តាដ៏ចំបងមួយក្នុងការជម្រុញឲ្យកំលាំងទាំងអស់បំពេញការងារប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់ទាំងពេញបច្ចុប្បន្ន ក៏ដូចជាទៅអនាគត។

**គ.ភារៈទទួលខុសត្រូវចំពោះសង្គម**

**កត្តាខាងក្នុង៖** ថ្វីត្បិតតែពុំទាន់អនុវត្តបាន១០០% តាមទ្រឹស្តី តែបញ្ជាការដ្ឋានបានយកចិត្តទុកដាក់បំផុតទៅលើបញ្ហានេះ ដូចជាការអភិវឌ្ឍន៍វិជ្ជាជីវៈ ដើម្បីឲ្យមន្ត្រីទាំងអស់ដើរតាមទាន់នូវភាពរីកចម្រើននៃបច្ចេកទេស និងបច្ចេកវិទ្យាដែលកំពុងតែមានការផ្លាស់ប្តូរ និងមានការវិវឌ្ឍន៍បានយ៉ាងឆាប់រហ័ស។ ដើម្បីឆ្លើយតបទៅនឹងតម្រូវការធនធានមនុស្ស ចំពោះមុខបញ្ជាការដ្ឋានបានត្រូវបើកវគ្គជំនាញ ក៏ដូចជាការបញ្ជូនមន្ត្រីទៅធ្វើការបណ្តុះបណ្តាលនូវគ្រប់រូបភាព ក្នុងគោលបំណង

ឲ្យអ្នកទាំងនោះយកចំណេះដឹងដែលទទួលបានពីការបណ្តុះបណ្តាល ទៅបម្រើការងារប្រកបដោយគុណភាព និងមានសិទ្ធភាពខ្ពស់ ព្រមទាំងមានការទទួលខុសត្រូវខ្ពស់ចំពោះភារកិច្ចឲ្យកាន់តែច្បាស់ទៅលើការផ្សព្វផ្សាយបីអត្ថប្រយោជន៍កងរាជអាវុធហត្ថ និងការការពារសម្បត្តិរួម ការថែរក្សាផលប្រយោជន៍រួមការការពារសណ្តាប់ធ្នាប់ ការងារយេនឌ័រ ការថែទាំសុខភាពបុគ្គលិកពេលលំហែរមាតុភាពរបស់បុគ្គលិកនារីសិទ្ធិកុមារការសន្សំសំចៃការថែរក្សាសម្ភារៈប្រើប្រាស់របស់អង្គភាព និងការការពារផលប្រយោជន៍រួម។

**កត្តាខាងក្រៅ៖** បញ្ជាការដ្ឋានបានចូលរួមដោះស្រាយយ៉ាងសកម្មនូវរាល់បញ្ហាទាំងឡាយជាមួយនឹងក្រសួង ក៏ដូចជារាជរដ្ឋាភិបាល ដូចជាការបង្កើនទំនាក់ទំនង និងការធ្វើសហប្រតិបត្តិការជាមួយបណ្តាប្រទេសក្នុងតំបន់ និងសកលលោក លើការបណ្តុះបណ្តាលធនធានមនុស្សនៅតាមប្រទេសជាសមាជិកអាស៊ាន និងបណ្តាប្រទេសជាដៃគូប្រកបដោយគុណភាព និងប្រសិទ្ធិភាពខ្ពស់។ អនុវត្តប្រព័ន្ធផ្សព្វផ្សាយព័ត៌មានវិទ្យា សង្គ្រោះដល់កងរាជអាវុធហត្ថ លើកកំពស់កំណែទម្រង់រចនាសម្ព័ន្ធការងារ និងការពិនិត្យឡើងវិញលើកម្មវិធីអភិវឌ្ឍន៍ ការប្រើប្រាស់អាវុធបាញ់គ្រាប់ប្រឆាំងបាតុកម្មបំផុសការបោះពុម្ពផ្សាយព័ត៌មានអំពីអភិបាលកិច្ចល្អ ការអប់រំចិត្តសាស្ត្រសិទ្ធិមនុស្ស និងអត្ថបទផ្សេងៗដែលទាក់ទងនឹងកងកំលាំង និងជំនាញនគរបាលរដ្ឋបាល។

តាមលទ្ធផលនៃការស្រាវជ្រាវ កងកំលាំងរបស់បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេសភាគច្រើនមានអាយុជាមធ្យម៣៨ឆ្នាំ ដែលជាវ័យមួយមានលទ្ធភាពខ្ពស់ក្នុងការបំពេញការងារ ថ្វីត្បិតតែកងកំលាំងភាគច្រើនពុំទាន់មានសញ្ញាបត្របរិញ្ញាបត្រ និងសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ក៏ដោយ ក៏អ្នកទាំងនោះសុទ្ធតែជាអ្នកមានសមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញការងារទាំងអស់។

### ៣. តួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងស្ថាប័នចំណុះបញ្ជាការដ្ឋានកងរាជអាវុធហត្ថ

កងរាជអាវុធហត្ថជាកំលាំងមួយ ដែលមានតួនាទីសំខាន់សម្រាប់សង្គមទាំងមូល ក្នុងការពង្រឹងសន្តិសុខ ស្ថេរភាពនយោបាយ និងសណ្តាប់ធ្នាប់សង្គម។ កងរាជអាវុធហត្ថបំពេញតួនាទីភារកិច្ច តាមបញ្ញត្តិច្បាប់ជាធរមាន ដោយឈរលើគោលការណ៍បង្ការ បង្ក្រាប និងសង្គ្រោះ ហើយដើម្បីធានាប្រសិទ្ធិភាពក្នុងការគ្រប់គ្រង ដឹកនាំ បញ្ជា ទទួលបានជោគជ័យ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេសបានរៀបចំឲមានយន្តការ និងរចនាសម្ព័ន្ធការងារទទួលខុសត្រូវផ្ទៃក្នុងដូចជា[៨]៖ មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេសជាអ្នកទទួលខុសត្រូវរួម ហើយមេបញ្ជាការ

[៨] កងរាជអាវុធហត្ថលើផ្ទៃប្រទេស ៖ សៀវភៅកំណត់តួនាទី ភារកិច្ច និង រចនាសម្ព័ន្ធកងរាជអាវុធហត្ថ ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ១៩៩៩

រង និងសេនាធិការ ធ្វើជាប្រធានផែនសេនាធិការ និងគ្រប់គ្រងកំលាំងអន្តរាគមន៍ ព្រមទាំងទទួលដោយស្វ័យប្រវត្តិជាមេបញ្ជាស្តីទីពេលអវត្តមានមេបញ្ជាការ មេបញ្ជាការរងមួយចំនួន ធ្វើជាប្រធានផែនផ្សេងៗ មានផែនប្រភេទកំលាំង ផែនភស្តុភារបច្ចេកទេស ផែនចំរុះ។ រីឯ មេបញ្ជាការរងមួយចំនួនទៀត ទទួលបន្ទុកប្រតិបត្តិការទិសប្រចាំខេត្ត-រាជធានីនានាទូទាំងប្រទេស។ ចំនែកងសេនាធិការរងមួយចំនួននៃកងរាជអាវុធហត្ថលើផ្ទៃប្រទេសធ្វើជាអនុប្រធានតាមផែននីមួយៗហើយព្រមទាំងទទួលបន្ទុកជានាយការិយាល័យជំនាញផ្សេងៗ និងសេនាធិការរងមួយចំនួនទៀតទទួលបន្ទុកប្រតិបត្តិការទិសប្រចាំខេត្ត-រាជធានី នៅទូទាំងប្រទេស។ ក្រៅពីការបែងចែកភារកិច្ចខាងលើអស់លោកមេបញ្ជាការរង និងនាយសេនាធិការត្រូវបំពេញការងារមួយចំនួនទៀត តាមការប្រគល់ភារកិច្ចជាក់ស្តែងរបស់មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស។

### ៣.១ ខុទ្ទកាល័យ

ខុទ្ទកាល័យ មានតួនាទីធ្វើជាសេនាធិការជូនមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេសក្នុងការងាររដ្ឋបាល ការងាររដ្ឋបាលហរិញ្ញវត្ថុ និងសណ្តាប់ធ្នាប់ នៅក្នុងទីបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស ហើយមានភារកិច្ចព្រាងបទបញ្ជា សេចក្តីសម្រេច សេចក្តីណែនាំ សេចក្តីកំណត់ជូនលោកមេបញ្ជាការសម្រេច។ មេបញ្ជាការសម្រេចលើការកសាងរបៀបរបបការងារ ទទួលបន្ទុកការងារ ពិធីការ និងកិច្ចការងារទំនាក់ទំនងអន្តរជាតិ រៀបចំរាល់ពិធីប្រជុំក្នុងការងារនៅទីបញ្ជាការ និងរៀបចំកម្មវិធីការងាររបស់បញ្ជាការ។ សហការជាមួយស្ថាប័ននានា និងអាជ្ញាធររាជធានី-ខេត្តដើម្បីស្វែងយល់គោលការណ៍ទូទៅរបស់កងរាជអាវុធហត្ថ ប្រមូលចងក្រង និងរក្សាទុកឯកសាររបស់អង្គភាព ព្រមទាំងសម្របសម្រួលការងារប្រចាំថ្ងៃ និងសំណូមពរការងារផ្សេងៗពីគ្រប់ស្ថាប័ន និង កងរាជអាវុធហត្ថ រាជធានី-ខេត្ត ដែលពាក់ព័ន្ធជាមួយទីបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស។

ក្រៅពីនេះខុទ្ទកាល័យត្រូវបំពេញការងារមួយចំនួនទៀត តាមការប្រគល់ភារកិច្ចជាក់ស្តែងរបស់មេបញ្ជាការ។[៩] ខុទ្ទកាល័យកងរាជអាវុធហត្ថលើផ្ទៃប្រទេសមានរចនាសម្ព័ន្ធការងារទទួលខុសត្រូវដូចជានាយខុទ្ទកាល័យទទួលខុសត្រូវរួម ហើយនាយរងជួសមុខនាយខុទ្ទកាល័យបំពេញការងារជំនាញ និង ដឹកនាំបញ្ជាតាមផ្នែកនីមួយៗ។ រីឯជំនាញនីមួយៗមានតួនាទីធ្វើសេនាធិការជូនថ្នាក់ដឹកនាំការិយាល័យក្នុងនោះមាន ៖

[៩] អនុក្រឹត្យលេខ១៥៩ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៩ ស្តីពីការកែសម្រួលរៀបចំឡើងវិញរចនាសម្ព័ន្ធក្របខ័ណ្ឌចាត់តាំងបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

- ផ្នែករដ្ឋបាល ៖ ទទួលបន្ទុកក្នុងការទទួល បញ្ជូនលិខិត រៀបចំទុកដាក់ឯកសារ និងទទួលការងារផ្ទៃក្នុងខុទ្ទកាល័យ។
- ផ្នែកបោះពុម្ព និងព័ត៌មានវិទ្យា ៖ ទទួលបន្ទុកការងារបូកសរុប ចងក្រងឯកសារ និងធ្វើរបាយការណ៍។
- ផ្នែកកិច្ចការទំនាក់ទនងអន្តជាតិ ៖ ទំនាក់ទំនងអន្តរជាតិ ទទួលបន្ទុកការងាររៀបចំពិធីការ និងទំនាក់ទំនងអន្តរជាតិរបស់កងរាជអាវុធហត្ថ។
- ផ្នែកគ្រប់គ្រងឯកសារ ៖ ទទួលបន្ទុកការងារបុគ្គលិក ត្រួតពិនិត្យ បូកសរុបស្ថិតិ បំពេញសំណុំបែបបទចុះបញ្ជី ប្រមូលចងក្រងរក្សាទុកឯកសារ ការងារបុគ្គលិក។
- គ្រប់នាយករង និងនាយផ្នែក ព្រមទាំងជំនួយការត្រូវបំពេញការងារមួយចំនួនទៀត តាមការប្រគល់ភារកិច្ចជាក់ស្តែងរបស់ថ្នាក់ដឹកនាំខុទ្ទកាល័យ។

### ៣.២ សេនាធិការដ្ឋាន

សេនាធិការដ្ឋាន មានតួនាទីប្រមូលក្តាប់នូវរាល់ព័ត៌មានទូទៅ ផ្តួចផ្តើមកសាងផែនការ និងបូកសរុបចាត់ចែងប្រតិបត្តិការ និងថែរក្សាសណ្តាប់ធ្នាប់។ តាមដានគ្រប់គ្រងកម្លាំងមធ្យោបាយបំពាក់ ចាត់ចែងតាមដានការងារហ្វឹកហ្វឺន ដើម្បីលើកកម្ពស់សមត្ថភាពជំនាញវិជ្ជាជីវៈដល់បុគ្គលិក។

សេនាធិការដ្ឋាន មានភារកិច្ចដូចខាងក្រោម ៖

- អនុវត្តវិធានការប្រមូលយកព័ត៌មានធ្វើការវិភាគព័ត៌មាន និងពិនិត្យបញ្ជាក់វាយតម្លៃសន្និដ្ឋានឲបានសុក្រឹត្យ។
- លើកគម្រោងផែនការណ៍ការពារ បង្ក្រាប និងពង្រឹងប្រព័ន្ធសន្តិសុខ សណ្តាប់ធ្នាប់សង្គមក្នុងដំណាក់កាលនីមួយៗដើម្បីសុំគោលការណ៍ពីមេបញ្ជាការ។
- តាមដាន និងក្តាប់ព័ត៌មានគ្រប់ករណី ក្តាប់ភូមិសាស្ត្រ សភាពការណ៍ប្រជាជន ធ្វើការវាយតម្លៃសន្និដ្ឋានសភាពការណ៍រួម ដើម្បីជាមូលដ្ឋានសម្រាប់កសាងផែនការសកម្មភាពប្រតិបត្តិការគ្រប់រូបភាពរបស់កងរាជអាវុធហត្ថ។
- តាមដានត្រួតពិនិត្យអំពីកម្លាំង មធ្យោបាយ គ្រឿងបំពាក់ សម្ភារបរិក្ខាសឹក ដើម្បីបម្រើឲការងារប្រតិបត្តិការគ្រប់ថ្នាក់។
- ព្រាងបទបញ្ជា សេចក្តីកំណត់ សេចក្តីណែនាំ ដែលមានការពាក់ព័ន្ធដល់ភារកិច្ចប្រតិបត្តិការរបស់កងរាជអាវុធហត្ថ ដាក់ឆ្លងមេបញ្ជាការដើម្បីសុំគោលការណ៍អនុវត្ត។

– ផ្សព្វផ្សាយផែនការដែលបានអនុវត្តរួច និងប្រគល់ភារកិច្ចជាក់ស្តែងទកងឯកភាពពាក់ព័ន្ធដើម្បីចាត់ចែងអនុវត្ត។

– លើកគោលការណ៍ពង្រឹង និងធានាសុវត្ថិភាព សន្តិសុខទីតាំងមេបញ្ជាការ ការងារប្រចាំការ និងកម្លាំងប្រចាំបញ្ជា។

– លើកផែនការហ្វឹកហ្វឺនរៀនសូត្រ បំប៉នជំនាញទខ្សែរយៈជំនាញក្រោម (រាជធានី/ខេត្ត និងក្រុង/ស្រុក/ខណ្ឌ)

– តាមដាន ស្រាវជ្រាវ ក្តាប់ព័ត៌មានដែលជាអំពើខុសច្បាប់ ពង្រឹងប្រព័ន្ធសន្តិសុខសណ្តាប់ធ្នាប់សង្គម និងក្តាប់សភាពការណ៍សន្តិសុខសង្គមដើម្បីរាយការណ៍ជូនមេបញ្ជាការ។

– អនុវត្តវិធានការប្រមូលព័ត៌មាន ធ្វើការវិភាគព័ត៌មាន ពិនិត្យបញ្ជាក់ វាយតម្លៃសន្និដ្ឋានព័ត៌មានឲ្យសុក្រឹត។

– សហការណ៍ជាមួយស្ថាប័នកងឯកភាពពាក់ព័ន្ធ អនុវត្តការងារការពារផ្ទៃក្នុងកងទ័ពឲរឹងមាំ។

– ត្រួតពិនិត្យរាល់អំពើល្មើសនឹងច្បាប់ ប្រមូលភស្តុតាង កសាងសំណុំរឿង និងកំណត់មុខសញ្ញាប្រព្រឹត្តិបទល្មើសបញ្ជូនទៅតុលាការតាមក្រមនីតិវិធីព្រហ្មទណ្ឌ ដែលបានប្រគល់សិទ្ធ និងអំណាចដល់មន្ត្រីនគរបាលយុត្តិធម៌។

– បូកសរុបរបាយការណ៍ប្រចាំថ្ងៃ ខែ ត្រីមាស ឆមាស និងឆ្នាំ។

– ក្រៅពីនេះ សេនាធិការដ្ឋានត្រូវបំពេញការងារមួយចំនួនទៀត តាមការប្រគល់ភារកិច្ចជាក់ស្តែងរបស់មេបញ្ជាការ។[១០]

សេនាធិការដ្ឋាន កងរាជអាវុធហត្ថលើផ្ទៃប្រទេស មានរចនាសម្ព័ន្ធទទួលខុសត្រូវដូចជា ៖

– ការិយាល័យផែនការ

– ការិយាល័យប្រតិបត្តិការ

– ការិយាល័យព័ត៌មាននិងសន្តិសុខ

– ការិយាល័យហ្វឹកហ្វឺន

– ការិយាល័យប្រឆាំងភេរវកម្ម

– ការិយាល័យជំនួយមនុស្សធម៌ និងសង្គ្រោះគ្រោះមហន្តរាយ

[១០] អនុក្រឹត្យលេខ១៥៩ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលរៀបចំឡើងវិញរចនាសម្ព័ន្ធក្របខ័ណ្ឌចាត់តាំងបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

- ការិយាល័យបញ្ជូនសារ
- ការិយាល័យបំភ័ន្ធអក្ខរ:

### ៣.៣ ស្នងការដ្ឋានរដ្ឋបាលហិរញ្ញវត្ថុ

ស្នងការដ្ឋានរដ្ឋបាលហិរញ្ញវត្ថុ មានតួនាទីធ្វើសេនាធិការជូនមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេសក្នុងការងារធ្វើគម្រោងផែនការថវិកា ធានាបើកចែកគ្រប់គ្រងស្ថាប័ននានា ដើម្បីបម្រើឲកងរាជអាវុធហត្ថ។

ស្នងការដ្ឋានរដ្ឋបាលហិរញ្ញវត្ថុ មានភារកិច្ចធ្វើគម្រោងផែនការ ថវិកាសម្រាប់ធានាបើកចែកឲអង្គភាពចំណុះ និងរាល់ការចំណាយផ្សេងៗតាមសេចក្ដីត្រូវការចាំបាច់របស់អង្គភាព។ ទទួលខុសត្រូវទាំងស្រុងចំពោះបញ្ហាការរាល់ចំណាយ ចំណូលថវិការបស់អង្គភាព។ គ្រប់គ្រាន់ និងកសាងសំណុំឯកសារ លិខិតស្នាមផ្សេងៗព្រមទាំងធ្វើការបូកសរុបការងារហិរញ្ញវត្ថុតាមការកំណត់។ ក្រៅពីនេះការិយាល័យហិរញ្ញវត្ថុ ត្រូវបំពេញការងារមួយចំនួនទៀតតាមការប្រគល់ភារកិច្ចជាក់ស្ដែងរបស់មេបញ្ជាការ។

ស្នងការដ្ឋានរដ្ឋបាលហិរញ្ញវត្ថុរបស់កងរាជអាវុធហត្ថលើផ្ទៃប្រទេស មានរចនាសម្ព័ន្ធការងារទទួលខុសត្រូវដូចជា ៖ នាយការិយាល័យបន្ទុកក្ដាប់រួម ហើយនាយរងជួសមុខនាយការិយាល័យទទួលបន្ទុកបំពេញការងារជំនាញ និងដឹកនាំ បញ្ជាតាមផ្នែកនីមួយៗ រីឯផ្នែកនីមួយៗមាននាទីធ្វើការសេនាធិការជូនថ្នាក់ដឹកនាំការិយាល័យ ក្នុងនោះមាន ៖

- ការិយាល័យផែនការទទួលបន្ទុកលើការងារទំនាក់ទំនងរកថវិកាចំណូល សម្រាប់ធានាការបើកចំណូល សម្រាប់ធានាការបើកចំណាយរបស់អង្គភាព និង ការងាររដ្ឋបាល។
- ការិយាល័យហិរញ្ញវត្ថុ ៖ មានតួនាទីក្នុងការងារគ្រប់គ្រងជំនាញហិរញ្ញវត្ថុ បណ្ដាអង្គភាពចំណុះ និង សរុបការចំណាយថវិការបស់អង្គភាព។
- ការិយាល័យបុគ្គលិក ៖ មានតួនាទីក្នុងការងារកត់ត្រារាល់ការចំណាយចំណូលថវិកា ដែលកើតមានឡើងក្នុងអង្គភាព ( ទាំងសាច់ប្រាក់ ទាំងសំភារ: ) និងគ្រប់គ្រងពេលវេលារបស់អង្គភាព និងការិយាល័យទំនាក់ទំនង។

គ្រប់នាយរង និងនាយផ្នែក ព្រមទាំងជំនួយការត្រូវបំពេញការងារមួយចំនួនទៀតតាមការប្រគល់ភារកិច្ចជាក់ស្ដែងរបស់មេបញ្ជាការ។[១១]

[១១] អនុក្រឹត្យលេខ១៥៩ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៤ ស្ដីពីការកែសម្រួលរៀបចំឡើងវិញរចនាសម្ព័ន្ធក្របខ័ណ្ឌចាត់តាំងបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

### ៣.៤ ស្នងការដ្ឋានយុត្តិធម៌

– ស្នងការដ្ឋានយុតិធមិ មានតួនាទីធ្វើជាសេនាធិការជូនមេបញ្ជាការកងរាជអាវុធហត្ថក្នុងការងារនគរបាលយុត្តិធមិ និងមានភារកិច្ចដូចខាងក្រោម ៖

– ប្រមូលព័ត៌មានតាមរយៈជំនាញក្នុងកងរាជអាវុធហត្ថ និងស្ថាប័នដែលពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់។

– សិក្សាស្រាវជ្រាវ និងសហការជាមួយជំនាញពាក់ព័ន្ធ ដើម្បីបណ្តុះបណ្តាល និងបំប៉នជំនាញឲនាយអាវុធហត្ថដែលទទួលខុសត្រូវជំនាញ។

– ត្រួតពិនិត្យ និងទទួលពាក្យបណ្តឹងពីគ្រប់មជ្ឈដ្ឋាន អំពីបទឧក្រិដ្ឋ បទមជ្ឈឹម បទលហុ បទល្មើសយោធា បទល្មើសគ្រឿងញៀន បទល្មើសការជួញដូរមនុស្សអំពើអាជីវកម្មផ្លូវភេទកំណត់អត្តសញ្ញាណ និងចាប់ជនល្មើសព្រមទាំងប្រមូលភស្តុតាង ដើម្បីកសាងសំណុំរឿងបញ្ជូនទៅតុលាការ។

– ទទួលបន្ទុកអនុវត្តដីការបស់តុលាការស៊ីវិល និងយោធា ដែលពាក់ព័ន្ធបទល្មើសព្រហ្មទណ្ឌ។

– អនុវត្តសេចក្តីបង្គាប់ តាមអំណាចដីកាតុលាការ។

– គ្រប់គ្រងអប់រំ ចំពោះជនដែលបានជាប់ឃុំឃាំង។

– កសាងសំណុំឯកសារជនជាប់ឃុំឃាំងដើម្បីគ្រប់គ្រង។

– ក្រៅពីនេះ ស្នងការដ្ឋានយុត្តិធមិ ត្រូវបំពេញការងារមួយចំនួនទៀត តាមការប្រគល់ភារកិច្ចជាក់ស្តែងរបស់មេបញ្ជាការ។[១២]

ស្នងការដ្ឋានយុត្តិធមិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស មានរចនាសម្ព័ន្ធទទួលខុសត្រូវដូចជា ៖

– ការិយាល័យស្រាវជ្រាវបទល្មើសព្រហ្មទណ្ឌ

– ការិយាផែនការ

– ការិយាល័យស្រាវជ្រាវប្រឆាំងគ្រឿងញៀន

– ការិយាល័យស្រាវជ្រាវប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន

– ការិយាល័យបទល្មើសយោធា។

[១២] អនុក្រឹត្យលេខ១៥៩ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលរៀបចំឡើងវិញរចនាសម្ព័ន្ធក្របខ័ណ្ឌចាត់តាំងបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

### ៣.៥ ស្នងការដ្ឋានភស្តុភារ

– ស្នងការដ្ឋានភស្តុភារ មានតួនាទីធ្វើជាសេនាធិការជូនមេបញ្ជាការកងរាជអាវុធហត្ថក្នុងការធានាភស្តុតាង សម្ភារៈបច្ចេសទេស វិស្វកម្ម និងការងារបង្កបង្កើនផល និងមានភារកិច្ច ៖

– ធានាផ្គត់ផ្គង់ជីវភាពរស់នៅទាំងស្បៀងអាហារ យោធបរិក្ខា ប្រេងឥន្ធនៈឲកងរាជអាវុធហត្ថ។

– ធ្វើផែនការគ្រប់គ្រងថែរក្សា ការជួសជុល កែច្នៃគ្រឿងចក្រ គ្រឿងយន្ត បែងចែក ប្រើប្រាស់សម្ភារៈបរិក្ខាបច្ចេកទេសសព្វាវុធគ្រាប់រំសេវគ្រប់ប្រភេទ និងគ្រឿងយន្តដែលថ្នាក់លើបំពាក់ឲ្យ។

– ថែរក្សាព្យាបាល ផ្ដល់ឱសថដល់អាវុធហត្ថ ឲទាន់ពេលវេលា និងមានប្រសិទ្ធភាពខ្ពស់។

– ធ្វើការអភិវឌ្ឍន៍ សំដៅកែប្រែជីវភាពរបស់កងរាជអាវុធហត្ថ និងរួមចំណែកក្នុងវិស័យអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។

– ក្រៅពីនេះ ស្នងការដ្ឋានភស្តុភារ បច្ចេកទេសត្រូវបំពេញការងារមួយចំនួនទៀតតាមការប្រគល់ភារកិច្ចជាក់ស្ដែងរបស់មេបញ្ជាការ។[១៣]

– ស្នងការដ្ឋានភស្តុភារ កងរាជអាវុធហត្ថលើផ្ទៃប្រទេស មានរចនាសម្ព័ន្ធទទួលខុសត្រូវដូចជា ៖

- ការិយាល័យផែនការ
- ការិយាល័យសម្ភារៈ-បច្ចេកទេស
- ការិយាល័យវិស្វកម្ម
- ការិយាល័យសុខាភិបាល
- ការិយាល័យអភិវឌ្ឍន៍។

### ៣.៦ ស្នងការដ្ឋានប្រភពកម្លាំង

ស្នងការប្រភពកម្លាំង មានតួនាទីធ្វើជាសេនាធិការជូនមេបញ្ជាការកងរាជអាវុអហត្ថក្នុងការគ្រប់គ្រងបុគ្គលិក ហ្វឹកហ្វឺន ទំនាក់ទំនងសាធារណៈ និងការអប់រំផ្សព្វផ្សាយឲកងរាជអាវុធហត្ថ និងមានភារកិច្ច ៖

[១៣] អនុក្រឹត្យលេខ១៥៩ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៤ ស្ដីពីការកែសម្រួលរៀបចំឡើងវិញរចនាសម្ព័ន្ធក្របខ័ណ្ឌចាត់តាំងបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

– គ្រប់គ្រងកម្លាំង ត្រៀមកម្លាំងដើម្បីបម្រើ និងបំពេញតម្រូវការកងរាជអាវុធហត្ថ។

– រៀបចំក្របខ័ណ្ឌ និងរចនាសម្ព័ន្ធចាត់តាំងរបស់កងរាជអាវុធហត្ថគ្រប់កងឯកភាព។

– រៀបសំណើជ្រើសរើសបញ្ចូលក្របខ័ណ្ឌ តម្លើង-បញ្ចុះឋានន្តរសក្តិតែងតាំងផ្លាស់ប្តូរមុខងារ-តួនាទី ដល់នាយ នាយរង និងពលអាវុធហត្ថ។

– បំពេញសំណុំបែបបទដើម្បីបញ្ជូននាយ នាយរង និងពលអាវុធហត្ថទៅបណ្តុះបណ្តាលបំប៉ន ឬបំពេញកម្មសិក្សាក្នុង និងក្រៅប្រទេស ព្រមទាំងបំពេញសិក្ខាកាម ដែលបញ្ចប់វគ្គសិក្សាទៅតាមកងឯកភាព និងតាមជំនាញនីមួយៗ។

– ធ្វើផែនការកសាងកម្លាំង ឬកែសម្រួលកម្លាំងកងរាជអាវុធហត្ថប្រចាំឆ្នាំ ដោយអនុវត្តតាមគោលការណ៍ជ្រើសរើស និងផ្ទេរក្របខ័ណ្ឌ ឬដាក់ចេញចូលនិវត្តន៍តាមផែនការច្បាប់កំណត់។

– ធ្វើការហ្វឹកហ្វឺន ដើម្បីកសាងធនធានមនុស្សក្នុងកងរាជអាវុធហត្ថ។

– លើកគម្រោងសេចក្តីត្រូវការថវិកា ស្បៀងអាហារ យោធបរិក្ខា ប្រេងឥន្ធនៈ និងឧបករណ៍សម្ភារៈសិក្សាសម្រាប់ការងារបណ្តុះបណ្តាល និងហ្វឹកហ្វឺនដល់កងរាជអាវុធហត្ថ។

– ធ្វើការផ្សព្វផ្សាយព័ត៌មាន ឃោសនាចិត្តសាស្ត្រ និងដោះស្រាយគោលនយោបាយព្រមទាំងឃោសនាអប់រំ ផ្សព្វផ្សាយអំពីការរីកចម្រើនរបស់កងរាជអាវុធហត្ថ តាមរយៈការតាំងពិព័ណរូបភាពព្រឹត្តិបត្រ ទស្សនាវដ្តី និងប្រព័ន្ធឃោសនារបស់រដ្ឋ និងឯកជន។

– បំផុសចលនាវប្បធម៌-សិល្បៈជាតិ ចំណេះដឹងទូទៅ និងភាសាបរទេសដើម្បីបង្កើនសមត្ថភាពដល់នាយ នាយរង និងពលអាវុធហត្ថ។

– ក្រៅពីនេះ ស្នងការដ្ឋានប្រភពកម្លាំងត្រូវបំពេញការងារមួយចំនួនទៀតតាមការប្រគល់ភារកិច្ចជាក់ស្តែងរបស់មេបញ្ជាការ។

ស្នងការដ្ឋានប្រភពកម្លាំង កងរាជអាវុធហត្ថលើផ្ទៃប្រទេស មានរចនាសម្ព័ន្ធទទួលខុសត្រូវដូចជា៖

– លេខាធិការដ្ឋាន
– ការិយាល័យរដ្ឋបាល
– ការិយាល័យហ្វឹកហ្វឺន
– ការិយាល័យអប់រំផ្សព្វផ្សាយ។

**៣.៧ ស្នងការដ្ឋានបច្ចេកទេសសន្តិសុខ**

ស្នងការដ្ឋានបច្ចេកទេសសន្តិសុខ មានតួនាទីធ្វើជាសេនាធិការ ក្នុងការតាមដានត្រួតពិនិត្យ និងធ្វើអធិការកិច្ចដល់កងឯកភាព និងបុគ្គលិកកងរាជអាវុធហត្ថ។

ស្នងការដ្ឋានបច្ចេកទេសសន្តិសុខ កងរាជអាវុធហត្ថមានភារកិច្ច ៖

- តាមដានភាពអសកម្ម និងភាពមិនប្រក្រតីទាំងឡាយនៅក្នុងកងរាជអាវុធហត្ថ។
- ត្រួតពិនិត្យដោះស្រាយរាល់ពាក្យបណ្តឹង និងសេចក្តីរាយការណ៍នានាពីគ្រប់មជ្ឈដ្ឋានដែលប៉ះពាល់កិត្យានុភាពរបស់កងរាជអាវុធហត្ថ។
- សហការជាមួយស្ថាប័នជំនាញ ដែលមានការពាក់ព័ន្ធចូលរួមគ្រប់សកម្មភាពការងារដែលមានចរិតអង្កេត។
- ណែនាំបំប៉នជំនាញ ឲខ្សែជំនាញថ្នាក់ក្រោម។
- ក្រៅពីនេះ ស្នងការដ្ឋានបច្ចេកទេសសន្តិសុខ ត្រូវបំពេញការងារមួយចំនួនទៀតតាមការប្រគល់ភារកិច្ចជាក់ស្តែងរបស់មេបញ្ជាការ។[១៤]

ស្នងការដ្ឋានបច្ចេកទេសសន្តិសុខ កងរាជអាវុធហត្ថលើផ្ទៃប្រទេស មានរចនាសម្ព័ន្ធទទួលខុសត្រូវដូចជា ៖

- ការិយាល័យផែនការ
- ការិយាល័យស្រាវជ្រាវបទល្មើសឧក្រិដ្ឋ
- ការិយាល័យអធិការកិច្ចបច្ចេកទេស
- ការិយាល័យការពារសន្តិសុខផ្ទៃក្នុង។

**៣.៨ បញ្ជាការដ្ឋានរដ្ឋបាល**

បញ្ជាការដ្ឋានរដ្ឋបាល មានតួនាទីធ្វើជាសេនាធិការជូនមេបញ្ជាការកងរាជអាវុធហត្ថលើការគ្រប់គ្រង និងធានាការងារភស្តុភារ-ហរិញ្ញវត្ថុ ដល់ស្ថាប័នកងឯកភាពផ្ទៃក្នុងទីបញ្ជាការកងរាជអាវុធហត្ថ។

បញ្ជាការដ្ឋានរដ្ឋបាលកងរាជអាវុធហត្ថមានភារកិច្ចដូចខាងក្រោម ៖

- សម្របសម្រួលការងារប្រចាំថ្ងៃ រៀបចំអនាម័យសណ្តាប់ធ្នាប់ទូទៅផ្ទៃក្នុងទីបញ្ជាការកងរាជអាវុធហត្ថ និងទទួលសំណូមពរការងារផ្សេងៗពីស្ថាប័ន និងកងរាជអាវុធហត្ថ រាជធានី/ខេត្ត

[១៤] អនុក្រឹត្យលេខ១៥៩ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលរៀបចំឡើងវិញរចនាសម្ព័ន្ធក្របខ័ណ្ឌចាត់តាំងបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

ដែលពាក់ព័ន្ធជាមួយបញ្ជាការកងរាជអាវុធហត្ថ។

– ត្រួតពិនិត្យ បូកសរុបស្ថិតិ និងគ្រប់គ្រងប្រវត្តិរូបនាយ នាយរង និងពលអាវុធហត្ថចំណុះបញ្ជាការកងរាជអាវុធហត្ថ។

– គ្រប់គ្រងសម្ភារ ចលនទ្រព្យ និងអចលនទ្រព្យ ព្រមទាំងគ្រឿងបំពាក់របស់ទីបញ្ជាការផ្ទៃក្នុងបញ្ជាការកងរាជអាវុធហត្ថ ធានាបើកចែករាល់គោលរបបកំណត់ភស្តុភារ-ហរិញ្ញវត្ថុដល់នាយ នាយរង និងពលទាហាននៃកងរាជអាវុធហត្ថចំណុះបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស។

– សិក្សាស្រាវជ្រាវលើគម្រោង និងលើកគម្រោងផែងការសាងសង់ ជួសជុលសំណង់គ្រប់ប្រភេទរួមទាំងរៀបចំបណ្ដាញទឹក-ភ្លើងផ្ទៃក្នុងអង្គភាព។

– ត្រួតពិនិត្យ និងគ្រប់គ្រងលើការប្រើប្រាស់ទឹក-ភ្លើង តាមលក្ខណៈបច្ចេកទេស និងសន្សំសំចៃ។

– គ្រប់គ្រង ឬតាមដានរាល់ការប្រើប្រាស់ថែរក្សាសម្ភារៈគ្រឿងបំពាក់ស្ថាប័នកងឯកភាពចំណុះទីបញ្ជាការផ្ទៃក្នុងបញ្ជាការដ្ឋានកងរាជអាវុធហត្ថ ត្រួតពិនិត្យ តាមដានធានាបានលើគ្រប់វិស័យនូវសេវាថែទាំសុខភាពអនាម័យ ពិនិត្យព្យាបាលចាត់វិធានការទប់ស្កាត់ទាន់ពេលវេលានូវរោគរាតត្បាតនានា ជូនដល់នាយ នាយរង និងពលអាវុធហត្ថចំណុះទីបញ្ជាការផ្ទៃក្នុងបញ្ជាការដ្ឋាន។

– ក្រៅពីនេះ បញ្ជាការដ្ឋានរដ្ឋបាលត្រូវបំពេញការងារមួយចំនួនទៀត តាមការប្រគល់ភារកិច្ចជាក់ស្តែងរបស់មេបញ្ជាការ។[១៥]

បញ្ជាការដ្ឋានរដ្ឋបាល កងរាជអាវុធហត្ថលើផ្ទៃប្រទេស មានរចនាសម្ព័ន្ធទទួលខុសត្រូវដូចជា ៖

– មន្ទីររដ្ឋបាលហិរញ្ញវត្ថុ
– មន្ទីរសណ្តាប់ធ្នាប់-សន្តិសុខ
– មន្ទីរភស្តុតាង និងបច្ចេកទេស
– គិលានដ្ឋាន។

**៣.៩ ស្នងការដ្ឋានសម្ភារៈបច្ចេកទេស**

ស្នងការដ្ឋានសម្ភារៈបច្ចេកទេស មានតួនាទីរ៉ាប់រងសម្ភារៈ យុទ្ធោបករណ៍ បំពាក់ គ្រប់គ្រង និងថែទាំបច្ចេកទេស។

[១៥] អនុក្រឹត្យលេខ១៥៩ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលរៀបចំឡើងវិញរចនាសម្ព័ន្ធក្របខ័ណ្ឌចាត់តាំងបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

ស្នងការដ្ឋានសម្ភារៈបច្ចេកទេស មានភារកិច្ចដូចខាងក្រោម ៖

– ធ្វើផែនការគ្រប់គ្រង ថែរក្សាបែងចែក ប្រើប្រាស់សម្ភារៈបរិក្ខារបច្ចេកទេស សព្វាវុធគ្រាប់រំសេវគ្រប់ប្រភេទ និងគ្រឿងយន្ត ព្រមទាំងមធ្យោបាយដឹកជញ្ជូនដែលថ្នាក់លើបានបញ្ជាក់។

– ទំនាក់ទំនងគ្រប់ស្ថាប័នក្នុង និងក្រៅប្រទេស អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស ក្រសួងការពារជាតិ ដើម្បីស្រាវជ្រាវកសាងមូលដ្ឋាន ជួសជុស កែច្នៃ គ្រឿងចក្រ អាវុធ យុទ្ធភ័ណ្ឌ សម្ភារៈបរិក្ខារ គីមីសាស្ត្រ។

– គ្រប់គ្រងគ្រឿងចក្រ គ្រឿងយន្ត ស្នើសុំ និងផ្តល់នូវស្លាកលេខ ប័ណ្ណសម្គាល់ ប័ណ្ណបើកបរ និងចុះបញ្ជីគ្រប់គ្រងគ្រាប់រំសេវតាមបណ្តាលកងឯកភាពនិងឃ្លាំង។

– ធ្វើការហ្វឹកហ្វឺនបណ្តុះបណ្តាល បំប៉នសមត្ថភាពឯកទេស។

– គ្រប់គ្រងបរិមាណគុណភាព ទុកដាក់ថែរក្សារាល់បច្ចេកទេស គ្រឿងចក្រ អាវុធយុទ្ធភ័ណ្ឌសម្ភារៈ មធ្យោបាយដឹកជញ្ជូន។

– ត្រួតពិនិត្យឃ្លាំង ទីកន្លែងរក្សាទុកដាក់អាវុធយុទ្ធភ័ណ្ឌ គ្រប់រំសេវតាមបណ្តាកងឯកភាពចំណុះកងរាជអាវុធហត្ថ។

– គ្រប់គ្រងការជួសជុល កែច្នៃគ្រឿងចក្រ គ្រឿងយន្ត អាវុធគ្រប់ប្រភេទរបស់កងរាជអាវុធហត្ថ។

– ក្រៅពីនេះ ស្នងការដ្ឋានសម្ភារៈបច្ចេកទេស ត្រូវបំពេញការងារមួយចំនួនទៀត តាមការប្រគល់ភារកិច្ចជាក់ស្តែងរបស់មេបញ្ជាការ។[១៦]

ស្នងការដ្ឋានសម្ភារៈបច្ចេកទេស កងរាជអាវុធហត្ថលើផ្ទៃប្រទេស មានរចនាសម្ព័ន្ធទទួលខុសត្រូវដូចជា ៖

– ការិយាល័យផែនការ

– ការិយាល័យសម្ភារៈ

– ការិយាល័យបំពាក់

– ការិយាល័យបច្ចេកទេស

– ការិយាល័យការពារគីមីសាស្ត្រ។

---

[១៦] អនុក្រឹត្យលេខ១៥៩ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលរៀបចំឡើងវិញរចនាសម្ព័ន្ធក្របខ័ណ្ឌចាត់តាំងបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

**ផ្នែកទី២៖ រចនាសម្ព័ន្ធវិទ្យាស្ថានកងរាជអាវុធហត្ថ (កំបូល) និងរចនាសម្ព័ន្ធមជ្ឈមណ្ឌលហ្វឹកហ្វឺនកងរាជអាវុធហត្ថ (ភ្នំជំរាយ)**

**១-សាលាកំបូល**

សាលាកំបូល មានតួនាទីបណ្តុះបណ្តាល និងធ្វើវិក្រឹត្យការដល់នាយទាហាននៃកងរាជអាវុធហត្ថរយៈខ្លី មធ្យម និងវែង។

សាលាកំបូល មានភារកិច្ចដូចខាងក្រោម៖

– រៀបចំកម្មវិធីបង្រៀននាយទាហាននៃកងរាជអាវុធហត្ថឲស្របតាមផែនការហ្វឹកហ្វឺនរបស់បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស។

– សហការត្រួតពិនិត្យ សិក្ខាកាមបញ្ចូលក្នុងវគ្គសិក្សាស្របតាមការណែនាំរបស់មេបញ្ជាការ។

– ធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងឯកសារនានាដែលពាក់ព័ន្ធដល់ការបង្ហាត់បង្រៀន និងដកស្រង់បទពិសោធន៍លើកកម្ពស់គុណភាពនៃការហ្វឹកហ្វឺន។

– តាមដាន និងក្តាប់ជាប់អំពីបរិមាណ និងគុណភាពរៀនសូត្ររបស់សិក្ខាកាម។

– តាមដាន និងក្តាប់ជាប់គុណភាព សមត្ថភាពបង្រៀនរបស់យោធាចារ្យ និងគ្រូមកពីស្ថាប័នផ្សេងៗ។

– ស្នើសុំថ្នាក់លើ ដើម្បីចេញវិញ្ញាបនបត្របញ្ជាក់ការសិក្សាដល់សិក្ខាកាមដែលបញ្ចប់វគ្គ។

– ធានាផ្គត់ផ្គង់ជីវភាពខាងស្មារតីនិងសម្ភារៈដល់បុគ្គលិក យោធាចារ្យ និងសិក្ខាកាម។

– ពង្រឹងសមត្ថភាពគណៈគ្រប់គ្រង យោធាចារ្យ និងសិក្ខាកាម។

– យកចិត្តទុកដាក់ថែទាំសម្ភារៈ គ្រឿងបំពាក់ផ្សេងៗឲបានល្អប្រសើរ។

– ធ្វើការវាយតម្លៃដោយតម្លាភាព អំពីគុណភាពនៃការសិក្សាចំពោះសិក្ខាកាមដែលបានបណ្តុះបណ្តាល និងការហ្វឹកហ្វឺនបញ្ចប់។

– ក្រៅពីនេះសាលាកំបូល ត្រូវបំពេញការងារមួយចំនួនទៀត តាមការប្រគល់ភារកិច្ចជាក់ស្តែងរបស់មេបញ្ជាការ។[១៧]

សាលាកំបូល កងរាជអាវុធហត្ថលើផ្ទៃប្រទេស មានរចនាសម្ព័ន្ធទទួលខុសត្រូវដូចជា៖

[១៧] ប្រកាសលេខ ០២៧/០១០ ស.ស.ណ. ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១០ ស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងស្ថាប័នចំណុះបញ្ជាការដ្ឋានកងរាជអាវុធហត្ថ របស់អគ្គមេបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ

- ទីចាត់ការ
- លេខាធិការដ្ឋាន
- ក្រុមយោធាចារ្យ
- មន្ទីរកិច្ចការហ្វឹកហ្វឺន
- មន្ទីររដ្ឋបាល និងហិរញ្ញវត្ថុ
- មន្ទីរភស្តុតាង
- មន្ទីរសម្ភារៈបច្ចេកទេស
- កងអនុសេនាធំការពារ។

**២-មជ្ឈមណ្ឌលហ្វឹកហ្វឺនភ្នំជំរាយ**

មជ្ឈមណ្ឌលហ្វឹកហ្វឺនភ្នំជុំរាយ មានតួនាទីបណ្តុះបណ្តាលនិងបំប៉នឯកទេសជំនាញ។

មជ្ឈមណ្ឌលហ្វឹកហ្វឺនភ្នំជុំរាយ មានភារកិច្ចដូចខាងក្រោម ៖

- រៀបចំកម្មវិធីបណ្តុះបណ្តាលនាយទាហានរងនៃកងរាជអាវុធហត្ថ ស្របតាមផែនការហ្វឹកហ្វឺនរបស់បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស។
- សហការត្រួតពិនិត្យសិក្ខាកាម បញ្ចូលក្នុងវគ្គសិក្សាស្របតាមការណែនាំរបស់មេបញ្ជាការ។
- ធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងឯកសារនានាដែលពាក់ព័ន្ធដល់ការបង្ហាត់បង្រៀន និងដកស្រង់បទពិសោធន៍លើកកម្ពស់គុណភាពនៃការហ្វឹកហ្វឺន។
- តាមដាននិងក្តាប់ជាប់គុណភាព សមត្ថភាពបង្រៀនរបស់យោធាចារ្យ និងគ្រូមកពីស្ថាប័នក្រៅ។
- ស្នើសុំថ្នាក់លើ ដើម្បីចេញវិញ្ញាបនបត្របញ្ជាក់ការសិក្សាដល់សិក្ខាកាមដែលបញ្ចប់វគ្គ។
- ធានាផ្គត់ផ្គង់ជីវភាពខាងស្មារតី និងសម្ភារៈដល់បុគ្គលិក យោធាចារ្យ និងសិក្ខាកាម។
- ជ្រើសរើស និងបណ្តុះបណ្តាលយោធាចារ្យសម្រាប់បន្ថែមតាមតម្រូវការរបស់មជ្ឈមណ្ឌល។
- ធានាផ្គត់ផ្គង់ឯកសារ និងសម្ភារៈឧបទេសសម្រាប់ការបង្រៀន។
- ធានាសន្តិសុខសណ្តាប់ធ្នាប់ផ្ទៃក្នុងរបស់មជ្ឈមណ្ឌល។
- ធ្វើការវាយតម្លៃដោយតម្លាភាព អំពីគុណភាពនៃការសិក្សាចំពោះសិក្ខាកាមដែល

បានបណ្តុះបណ្តាល និងការហ្វឹកហ្វឺនបញ្ចប់។

– ក្រៅពីនេះមជ្ឈមណ្ឌលហ្វឹកហ្វឺនភ្នំជុំវាយ ត្រូវបំពេញការងារមួយចំនួនទៀត តាមការប្រគល់ភារកិច្ចជាក់ស្តែងរបស់មេបញ្ជាការ។[១៨]

មជ្ឈមណ្ឌលហ្វឹកហ្វឺនភ្នំជុំវាយ កងរាជអាវុធហត្ថលើផ្ទៃប្រទេស មានរចនាសម្ព័ន្ធទទួលខុសត្រូវដូចជា ៖

- ទីចាត់ការ
- លេខាធិការដ្ឋាន
- ក្រុមយោធាចារ្យ
- មន្ទីរកិច្ចការហ្វឹកហ្វឺន
- មន្ទីររដ្ឋបាល និងហិរញ្ញវត្ថុ
- មន្ទីរភស្តុតាង
- មន្ទីរសម្ភារៈបច្ចេកទេស
- កងអនុសេនាធំការពារ។

## ផ្នែកទី៣៖ សមាសភាពនគរបាលយុត្តិធម៌នៃកងរាជអាវុធហត្ថលើផ្ទៃប្រទេស

នគរបាលយុត្តិធម៌ គឺជាជំនួយរបស់អំណាចរបស់តុលាការ មានន័យថានគរបាលយុត្តិធម៌ ជាជំនួយរបស់អំណាចព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរក្នុងការត្រួតពិនិត្យ និងទទួលពាក្យបណ្តឹងពីគ្រប់មជ្ឈដ្ឋានអំពីបទឧក្រិដ្ឋ បទមជ្ឈិម បទលហុ កំណត់អត្តសញ្ញាណ និងចាប់ជនល្មើស ព្រមទាំងប្រមូលភស្តុតាង ដើម្បីកសាងសំណុំបញ្ជូនទៅតុលាការ។[១៩]

សមាសភាពរបស់នគរបាលយុត្តិធម៌រួមមាន៖

- មន្ត្រីនគរបាលយុត្តិធម៌
- ភ្នាក់ងារនគរបាលយុត្តិធម៌
- មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតដែលច្បាប់ដោយឡែកប្រគល់អំណាចឲ្យធ្វើការពិនិត្យបទល្មើសខ្លះៗ ក្នុងវង្វង់សមត្ថកិច្ចរបស់ខ្លួន។[២០]

---

[១៨] ប្រកាសលេខ ០២៧/០១០ ស.ស.ណ. ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១០ ស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងស្ថាប័នចំណុះបញ្ជាការដ្ឋានកងរាជអាវុធហត្ថ របស់អគ្គមេបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ

[១៩] មាត្រា៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[២០] មាត្រា៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

## ១. មន្ត្រីនគរបាលយុត្តិធម៌នៃកងរាជអាវុធហត្ថលើផ្ទៃប្រទេស

ក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់អំពីការទទួលបានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ គឺវាមានរបបគតិយុត្តមួយដាច់ដោយឡែក ហើយការទទួលបានគុណសម្បត្តិជាភ្នាក់ងារនគរបាលយុត្តិធម៌គឺវាមានរបបគតិយុត្តិមួយដាច់ដោយឡែក។

ការទទួលបានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ តាមរយៈលក្ខណៈពីរយ៉ាងគឺ៖ ការទទួលបានគុណសម្បត្តិតាមរយៈការប្រឡងយកសញ្ញាបត្រជាន់ខ្ពស់នៃមន្ត្រីនគរបាលយុត្តិធម៌ និងការទទួលបានគុណសម្បត្តិតាមរយៈឋានន្តរស័ក្តិ និងមុខងារ។

### ១.១ ការទទួលបានគុណសម្បត្តិតាមរយៈការប្រឡង

នាយទាហាននៃកងរាជអាវុធហត្ថដែលបម្រើការងារយ៉ាងតិច ២(ពីរ)ឆ្នាំ ក្នុងកងរាជអាវុធហត្ថរួចហើយ ហើយបន្ទាប់មកបានទទួលសញ្ញាបត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌។

សញ្ញាបត្រជាន់ខ្ពស់នៃនគរបាលយុត្តិធម៌ ត្រូវបានផ្តល់ជូនដល់មន្ត្រីដែលបានប្រឡងបែបវិជ្ជាជីវៈជាប់ ដែលរួមមានវិញ្ញាសាជាមូលដ្ឋានដូចខាងក្រោម:

-វិញ្ញាសាស្តីពីនីតិព្រហ្មទណ្ឌ

-វិញ្ញាសាស្តីពីនីតិវិធីព្រហ្មទណ្ឌ

-វិញ្ញាសាស្តីពីករណីយកិច្ចសាស្ត្រ ដូចដែលមានចែងក្នុងក្រមសីលធម៌ដែលគាត់តែងដោយអង្គការសហប្រជាជាតិ។

គណៈមេប្រយោគនៃការប្រឡង ត្រូវស្ថិតនៅក្រោមអធិបតីភាពរបស់អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ឬចៅក្រមអយ្យការអមតុលាការកំពូលដែលទទួលមុខងារនេះ។ គណៈមេប្រយោគរួមមានសមាសភាពដូចខាងក្រោម:

-ចៅក្រមស៊ើបសួរម្នាក់ ដែលតែងតាំងដោយប្រធានតុលាការកំពូល

-ចៅក្រមអយ្យការម្នាក់ ដែលតែងតាំងដោយប្រធានតុលាការកំពូល

-តំណាង ២(ពីរ)រូប មកពីក្រសួងការពារជាតិ។

បែបបទនៃការចេញសញ្ញាបត្រ ត្រូវកំណត់ដោយប្រកាសរួមមួយរវាងរដ្ឋមន្ត្រីពាក់ព័ន្ធ។

សញ្ញាបត្រជាន់ខ្ពស់នៃមន្ត្រីនគរបាលយុត្តិធម៌នេះ ត្រូវចុះហត្ថលេខារួមដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងការពារជាតិ ដោយមានបោះត្រាផង។

### ១.២ ការទទួលបានគុណសម្បត្តិតាមរយៈឋានន្តរស័ក្តិ និងមុខងារ

ទោះបីមិនបានបំពេញតាមលក្ខខណ្ឌ ដូចបានរៀបរាប់ខាងលើនេះក៏ដោយ ក៏បុគ្គល

មួយចំនួនអាចទទួលបានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌បានដែរ ឲ្យតែបុគ្គលនោះមានឋានន្តរស័ក្តិ និងមុខងារដូចខាងក្រោម:

-មេបញ្ជាការ និងមេបញ្ជាការរងនៃកងរាជអាវុធហត្ថដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ។

-មេបញ្ជាការ និងមេបញ្ជាការរងនៃកងរាជអាវុធហត្ថប្រចាំខេត្តរាជធានី/ ស្រុកខណ្ឌ/ក្រុង/ ដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ។

-ប្រធាន និងអនុប្រធានការិយាល័យ ប្រធាន និងអនុប្រធានផ្នែក នៃកងរាជអាវុធហត្ថទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ។

-ប្រធាន និងអនុប្រធានអង្គភាពផ្សេងទៀត ដែលទទួលបន្ទុកកិច្ចការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ ដែលត្រូវបង្កើតឡើងក្នុងករណីចាំបាច់។

កាលណានាយទាហាននៃកងរាជអាវុធហត្ថទាំងឡាយដែលបាន បំពេញលក្ខខណ្ឌតាមច្បាប់កំណត់ហើយ រដ្ឋមន្ត្រីជាអាណាព្យាបាលមានភារកិច្ចតែងតាំងនាយទាហានទាំងនោះឲ្យបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ ដោយប្រកាសរួមជាមួយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

នាយទាហាននៃកងរាជអាវុធហត្ថ ដែលមានវិញ្ញាបនបត្រនៃមន្ត្រីប៉ូលីសតុលាការ ត្រូវទទួលបានដោយស្វ័យប្រវត្តិនូវសញ្ញាបត្រជាន់ខ្ពស់នៃមន្ត្រីនគរបាលយុត្តិធម៌ ហើយត្រូវតែងតាំងជាមន្ត្រីនគរបាលយុត្តិធម៌ដោយប្រកាសរួមរបស់ក្រសួងការពារជាតិ និងក្រសួងយុត្តិធម៌។[២១]

### ១.៣ សម្បថ

មន្ត្រីនគរបាលយុត្តិធម៌ដែលទើបទទួលបានការតែងតាំង មុននឹងចូលបំពេញមុខងាររបស់ខ្លួនត្រូវធ្វើសម្បថនៅចំពោះមុខសាលាឧទ្ធរណ៍ ដោយស្បថថា ខ្លួននឹងបំពេញដោយភក្តីភាពនូវមុខងាររបស់ខ្លួន។ រូបមន្តនៃសម្បថត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ សម្បថមិនចាំបាច់ធ្វើឡើងជាថ្មីទៀតឡើយ នៅពេលដែលទទួលបាន នីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌នាពេលក្រោយទៀត។[២២]

## ១.៤ កំហុសពេលអនុវត្តភារងារ

### ១.៤.១ នីតិវិធីដាក់វិន័យ

កាលណាមន្ត្រីនគរបាលយុត្តិធម៌មានប្រព្រឹត្តិខុសក្នុងពេលបំពេញការងារ នឹងត្រូវទទួលទណ្ឌកម្មខាងវិន័យ។ ប្រសិនបើមន្ត្រីនគរបាលយុត្តិធម៌ប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌវិញ

[២១] មាត្រា៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[២២] មាត្រា៦៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

នោះមន្ត្រីនគរបាលយុត្តធម៌ និងត្រូវទទួលទោសតាមច្បាប់ជាក់ស្តែងដូចជាករណីនគរបាលយុត្តិធម៌នៃកងរាជអាវុធហត្ថម្នាក់ដែលបានបាញ់ប្រជាការពារខេរបួស នៅទួលសង្កែ គឺត្រូវទទួលទោសតាមច្បាប់ដែរជាសិទ្ធិអំណាចរបស់តុលាការរាជធានីខេត្តក្រុង តែប្រសិនបើមន្ត្រីកងរាជអាវុធហត្ថនោះប្រព្រឹត្តបទល្មើសទាក់ទងទៅ និងបទល្មើសខាងយោធាមន្ត្រីកងរាជអាវុធហត្ថនោះ និងត្រូវទទួលទោសតាមច្បាប់យោធាដែរជាសិទ្ធិអំណាចរបស់តុលាការយោធា (ក្រឹត្យច្បាប់លេខ ០៩ ស្តីពីបទល្មើសមានលក្ខណៈយោធា និងទណ្ឌកម្ម) ចុះថ្ងៃទី៨ ខែ១២ ឆ្នាំ១៩៨១ តែបើមន្ត្រីនគរបាលយុត្តិធម៌នោះប្រព្រឹត្តត្រឹមតែកំហុសខាងរដ្ឋបាលនោះទេ គឺត្រូវទទួលទោសផ្នែករដ្ឋបាលហើយកំហុសនេះត្រូវតែឲ្យដំណឹងដោយព្រះរាជអាជ្ញា ឬដោយចៅក្រមស៊ើបសួរជូនដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ អគ្គព្រះរាជអាជ្ញាប្រកាសប្រាប់រដ្ឋមន្ត្រីក្រសួងការពារជាតិដើម្បីចាប់ផ្តើមនីតិវិធីខាងវិន័យ។ ទណ្ឌកម្មខាងវិន័យរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិមិនមែនជាឧសគ្គដល់ការធ្វើបណ្តឹងអាជ្ញាទេប្រសិន បើមានបទល្មើសណាមួយត្រូវបានប្រព្រឹត្ត។ បើអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍យល់ឃើញថា មានភាពធ្ងន់ធ្ងរនូវកំហុសដែលប្រព្រឹត្តដោយមន្ត្រីនគរបាលយុត្តិធម៌ណាម្នាក់ មានវិសមិតភាពជាមួយនឹងការបំពេញមុខងារ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍មានសិទ្ធិប្រកាសចេញនូវវិធានការដូចខាងក្រោម៖

- ហាមឃាត់មិនឲ្យបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ជាបណ្តោះអាសន្នសម្រាប់រយៈពេល៥ (ប្រាំ)ឆ្នាំយ៉ាងច្រើនបំផុត។
- ហាមឃាត់មិនឲ្យបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ជាស្ថាពរ។

មុននឹងចេញសេចក្តីសម្រេចរបស់ខ្លួន អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍កោះហៅមន្ត្រីនគរបាលយុត្តិធម៌ និងកត់ត្រាទុកនូវសេចក្តីសង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌នោះ។ សាមីជនអាចរកជំនួយពីមេធាវី ឬពីប្រឹក្សាម្នាក់តាមការជ្រើសរើសរបស់ខ្លួន។ សេចក្តីសម្រេចនេះត្រូវតែបញ្ជាក់សំអាងហេតុ និងត្រូវផ្តល់ជាដំណឹងដល់រដ្ឋមន្ត្រីក្រសួងការពារជាតិ។

មន្ត្រីនគរបាលយុត្តិធម៌ដែលត្រូវបានអគ្គព្រះរាជអាជ្ញាសម្រេចហាមឃាត់ អាចដាក់ពាក្យប្តឹងតវ៉ាទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ដោយមានសំអាងហេតុក្នុងកំឡុងពេល១៥ថ្ងៃ គិតពីថ្ងៃទទួលដំណឹងអំពីសេចក្តីសម្រេចនោះ ហើយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវសម្រេចសេចក្តីលើបណ្តឹងតវ៉ានេះក្នុងអំឡុងពេលយ៉ាងយូរបំផុត១ (មួយ)ខែ គិតពិថ្ងៃទទួលពាក្យបណ្តឹង។ សេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌មិនអាចប្តឹងតវ៉ាបានឡើយ។

ក្នុងអំឡុងពេលដែលអាចធ្វើបណ្តឹងតវ៉ា និងអំឡុងពេលនៃការសម្រេចសេចក្តីលើ

បណ្តឹងតវ៉ាមន្ត្រីនគរបាលយុត្តិធម៌ ដែលត្រូវបានអគ្គព្រះរាជអាជ្ញាសម្រេចហាមឃាត់នោះ មិនអាចបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌បានឡើយ។ ក្នុងករណីបំពានសេចក្តីសម្រេចនេះ កិច្ចទាំងឡាយដែលបានបំពេញដោយមន្ត្រីនគរបាលយុត្តិធម៌នោះ ត្រូវចាត់ទុកជាមោឃៈ។ មន្ត្រីនេះអាចបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌វិញបាន ប្រសិនបើរដ្ឋមន្ត្រីក្រសួងយុត្តិធម៌សម្រេចបដិសេធចោលការសម្រេចហាមឃាត់ ឬផុតរយៈពេលហាមឃាត់។

### ១.៤.២ ទណ្ឌកម្ម

កងរាជអាវុធហត្ថដែលប្រព្រឹត្តកំហុសក្នុងពេលបំពេញការងារផ្ទុយពីក្រមនីតិវិធីព្រហ្មទណ្ឌត្រូវទទួលទណ្ឌកម្មខាងវិន័យរដ្ឋបាលនិងទទួលការផ្តន្ទាទោសតាមក្រមព្រហ្មទណ្ឌ ពាក់ព័ន្ធនឹងការប៉ះពាល់ដល់សកម្មភាពរបស់តុលាការ ប្រសិនបើប្រព្រឹត្តិដោយបំពានទៅលើ:

-ការសម្ងាត់នៃការស៊ើបអង្កេត (មាត្រា៨៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

-ការសម្ងាត់នៃការស៊ើបសួរ (មាត្រា១២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

-សកម្មភាពតុលាការ (មាត្រា៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

-ការឃាត់ខ្លួន (មាត្រា៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

-ការឆែកឆេរ (មាត្រា៩១ នៃក្រមនីតិវីធីព្រហ្មទណ្ឌ)

ទណ្ឌកម្មខាងវិន័យរដ្ឋបាល គឺប្រសិនបើកងរាជអាវុធហត្ថនោះប្រព្រឹត្តកំហុសធ្ងន់ធ្ងរនិងត្រូវលុបឈ្មោះចោលចេញពីអង្គភាពតែម្តង ដោយធ្វើការស្នើលុបឈ្មោះចោលតាមឋានានុក្រមក្នុងអង្គភាព ប៉ុន្តែបើកំហុសនោះមិនធ្ងន់ធ្ងរទេ គឺអង្គភាពគ្រាន់តែហៅមកអប់រំណែនាំនិងឲ្យគោរពវិន័យក្នុងអង្គភាព គោរពពេលវេលា គោរពការងារ និងវិន័យឲ្យមកអង្គភាពជារៀងរាល់ថ្ងៃ ប្រសិនបើកងរាជអាវុធហត្ថនោះនៅតែមិនស្តាប់ហើយបង្ករកំហុសបន្តទៅទៀតអាចឈានទៅដល់ការដាក់វិន័យដោយផ្អាកការងារជាបណ្តោះអាសន្ន ឬលុបឈ្មោះចោល។

## ១.៥ សមត្ថកិច្ចដែនដី និងការកំណត់សមត្ថកិច្ច

### ១.៥.១ សមត្ថកិច្ចដែនដី

មន្ត្រីនគរបាលយុត្តិធម៌ម្នាក់ៗ មានសម្តកិច្ចនៅក្នុងព្រំប្រទល់ដែនដីនៃអង្គភាពដែលខ្លួនត្រូវបានចាត់តាំងឲ្យបម្រើការងារ។ ចំណែកសេចក្តីសម្រេចតែងតាំងមន្ត្រីនគរបាលយុត្តិធម៌ត្រូវតែបញ្ជាក់មណ្ឌលរដ្ឋបាលដែលមន្ត្រីនគរបាលយុត្តិធម៌នោះត្រូវចាត់តាំងឲ្យទៅបម្រើការងារ។ សេចក្តីសម្រេចនេះ ត្រូវផ្តល់ដំណឹងដល់អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍។

នៅរាជធានីភ្នំពេញ មន្ត្រីនគរបាលយុត្តិធម៌មានសមត្ថកិច្ចនៅលើវិសាលភាពនៃរាជធានីទាំងមូល ទោះបីជាអង្គភាពដែលខ្លួនផ្លាស់ទៅកាន់នោះ នៅកន្លែងណាក៏ដោយ។

### ១.៥.២ ការកំណត់សមត្ថកិច្ច

ក្នុងវិស័យយុត្តិធម៌ កងរាជអាវុធហត្ថមានសមត្ថកិច្ចធ្វើការត្រួតពិនិត្យបទឧក្រិដ្ឋ បទមជ្ឈិម បទលហុ កំណត់ហេតុអត្តសញ្ញាណ និងចាប់ជនល្មើស ព្រមទាំងប្រមូលភស្តុតាង។ លើសពីនេះទៅទៀតកងរាជអាវុធហត្ថដែលមានគុណសម្បត្តិជានគរបាលយុត្តិធម៌ មានសមត្ថកិច្ចចំពោះបទល្មើសយោធាផងដែរ។

### ១.៥.៣ ការពន្លាតសមត្ថកិច្ច

ក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈឹមជាក់ស្ដែង មន្ត្រីនគរបាលយុត្តិធម៌អាចត្រូវបានអនុញ្ញាតពីព្រះរាជអាជ្ញាដោយផ្ទាល់មាត់ ឲ្យធ្វើប្រតិបត្តិការលើវិសាលភាពនៃដែនដីជាតិទាំងមូល ប្រសិនបើមានការបន្ទាន់។ប៉ុន្តែការអនុញ្ញាតនេះត្រូវតែចុះនិទ្ទេសក្នុងលិខិតស៊ើបអង្កេត។ ម៉្យាងទៀត នៅក្នុងលក្ខខណ្ឌនៃការស៊ើបសួរ កាលណាចៅក្រមស៊ើបសួរចេញដីការចាត់ឲ្យមន្ត្រីនគរបាលយុត្តិធម៌ស៊ើបសួរជំនួស ក្នុងករណីបន្ទាន់ ចៅក្រមនេះអាចអនុញ្ញាតឲ្យមន្ត្រីនគរបាលយុត្តធម៌ធ្វើប្រតិបត្តិការនៅលើវិសាលភាពនៃដែនដីជាតិទាំងមូល។ កាលណាមានការប្រតិបត្តិការក្រៅមណ្ឌលរបស់ខ្លួន (ពន្លាតសមត្ថកិច្ច) មន្ត្រីនគរបាលយុត្តិធម៌ត្រូវសុំជំនួយពីមន្ត្រីនគរបាលយុត្តិធម៌ដែលមានសមត្ថកិច្ចខាងដែនដី។ ចៅក្រមដែលបានអនុញ្ញាតឲ្យពន្លាតសមត្ថកិច្ច ត្រូវជូនព័ត៌មានតាមគ្រប់មធ្យោបាយដល់ព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចខាងដែនដី។

ក្នុងករណីមានការបំពានលើវិធានសមត្ថកិច្ចនេះ កិច្ចទាំងឡាយដែលបំពេញដោយមន្ត្រីនគរបាលយុត្តិធម៌ ត្រូវចាត់ទុកជាមោឃៈ។

## ២. ភ្នាក់ងារនគរបាលយុត្តិធម៌នៃកងរាជអាវុធហត្ថ

### ២.១ ការទទួលបានគុណសម្បត្តិជាភ្នាក់ងារនគរបាលយុត្តិធម៌

ការទទួលបានគុណសម្បត្តិជាភ្នាក់ងារនគរបាលយុត្តិធម៌រួមមាន:

- នាយទាហាននៃកងរាជអាវុធហត្ថ ដែលមិនមែនជាមន្ត្រីនគរបាលយុត្តិធម៌។
- យោធិនផ្សេងៗទៀតនៃកងរាជអាវុធហត្ថ។[២៣]

[២៣] មាត្រា៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

**២.២ សម្បថ**

ក្រសួងសាមីត្រូវបញ្ជូនបញ្ជីឈ្មោះភ្នាក់ងារនគរបាលយុត្តិធម៌ ដើម្បីបន្តនីតិវិធីសម្បថ។

មុននឹងចូលបំពេញមុខងារ ភ្នាក់ងារនគរបាលយុត្តិធម៌ត្រូវស្បថនៅមុខសាលាដំបូងថា បំពេញមុខងាររបស់ខ្លួនដោយស្មោះត្រង់។ រូបមន្តនៃសម្បថត្រូវកំនត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ សម្បថនេះពុំធ្វើសាជាថ្មីទៀតឡើយ នៅពេលដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិនាពេលក្រោយទៀត។[២៤]

**២.៣ កំហុសពេលអនុវត្តភារកិច្ច**

**២.៣.១ នីតិវិធីដាក់វិន័យ**

កាលណាភ្នាក់ងារនគរបាលយុត្តិធម៌មានប្រព្រឹត្តិខុសក្នុងពេលបំពេញការងារ នឹងត្រូវទទួលទណ្ឌកម្មខាងវិន័យ។ កំហុសនេះត្រូវតែឲ្យដំណឹងដោយព្រះរាជអាជ្ញា ឬដោយចៅក្រមស៊ើបសួរជូនដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ អគ្គព្រះរាជអាជ្ញាប្រកាសប្រាប់រដ្ឋមន្ត្រីក្រសួងការពារជាតិដើម្បីចាប់ផ្ដើមនីតិវិធីខាងវិន័យ។ ទណ្ឌកម្មខាងវិន័យរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិមិនមែនជាឧសគ្គដល់ការធ្វើបណ្ដឹងអាជ្ញាទេ ប្រសិនបើមានបទល្មើសណាមួយត្រូវបានប្រព្រឹត្តិ។ ក្នុងករណីនេះតុលាការកំពូលអាចផ្ទេរអំណាចឲ្យទៅយុត្តាធិការផ្សេងទៀតចាត់ការវិញបាន ដើម្បីជាប្រយោជន៍ល្អដល់រដ្ឋបាលតុលាការតាមការស្នើសុំដកសិទ្ធ ដែលធ្វើឡើងដោយព្រះរាជអាជ្ញា។

**២.៣.២ ទណ្ឌកម្ម**

ភ្នាក់ងារនគរបាលយុត្តិធម៌ ត្រូវទទួលការផ្ដន្ទាទោសតាមក្រមព្រហ្មទណ្ឌ ពាក់ព័ន្ធនឹងការប៉ះពាល់ដល់សកម្មភាពរបស់តុលាការ ប្រសិនបើប្រព្រឹត្តិដោយបំពានទៅលើ:

-ការសម្ងាត់នៃការស៊ើបអង្កេត (មាត្រា៨៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

-ការសម្ងាត់នៃការស៊ើបសួរ (មាត្រា១២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

ទណ្ឌកម្មខាងវិន័យរដ្ឋបាល គឺប្រសិនបើកងរាជអាវុធហត្ថនោះប្រព្រឹត្តកំហុសធ្ងន់ធ្ងរ និងត្រូវលុបឈ្មោះចោលចេញពីអង្គភាពតែម្ដង ដោយធ្វើការស្នើលុបឈ្មោះចោលតាមឋានានុក្រមក្នុងអង្គភាព ប៉ុន្តែបើកំហុសនោះមិនធ្ងន់ធ្ងរទេ គឺអង្គភាពគ្រាន់តែហៅមកអប់រំណែនាំ និងឲ្យគោរពវិន័យក្នុងអង្គភាព គោរពពេលវេលា គោរពការងារ និងវិន័យឲ្យមកអង្គភាពជារៀងរាល់ថ្ងៃ ប្រសិនបើកងរាជអាវុធហត្ថនោះនៅតែមិនស្ដាប់ហើយបង្ករកំហុសបន្តទៅទៀតអាចឈានទៅដល់ ការដាក់វិន័យដោយផ្អាកការងារជាបណ្ដោះអាសន្ន ឬលុបឈ្មោះចោល។

---

[២៤] មាត្រា៧៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

## ២.៤ សមត្ថកិច្ចដែនដី និងការកំនត់សមត្ថកិច្ច

### ២.៤.១ សមត្ថកិច្ចដែនដី

ភ្នាក់ងារនគរបាលយុត្តិធម៌ មានសមត្ថកិច្ចព្រំប្រទល់ដែនដីដែលខ្លួនបំពេញមុខងារតាមធម្មតា ដោយមិនអាចធ្វើការពន្លាតសមត្ថកិច្ចដោយខ្លួនឯងបានទេ ប៉ុន្តែខ្លួនអាចអមដំនើរមន្រ្តីនគរបាលយុត្តិធម៌ដែលធ្វើដំនើរទៅក្រៅដែនសមត្ថកិច្ចរបស់ខ្លួន តាមការអនុញ្ញាតដោយចៅក្រមឲ្យពន្លាតសមត្ថកិច្ច។

### ២.៤.២ ការកំណត់សមត្ថកិច្ច

នៅក្នុងវិស័យយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌មានសមត្ថកិច្ចពិនិត្យបទល្មើសជាអាទិ៍ បទលហុ និងជួយដល់មន្រ្តីនគរបាលយុត្តិធម៌ក្នុងការបំពេញមុខងារ។

# ជំពូកទី ៣
## បេសសកម្មនគរបាលយុត្តិធម៌នៃ
## កងរាជអាវុធហត្ថ

# ជំពូកទី ៣

# បេសសកម្មនគរបាលយុត្តិធម៌នៃកងរាជអាវុធហត្ថ

យោងតាមក្រមនីតិវីធិព្រហ្មទណ្ឌ បានកំណត់យ៉ាងច្បាស់អំពីភាពខុសគ្នារវាងបេសសកម្មរបស់កងរាជអាវុធហត្ថដែលមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ និងបេសសកម្មរបស់កងរាជអាវុធដែលមានគុណសម្បត្តិជាភ្នាក់ងារនគរបាលយុត្តិធម៌។

## ផ្នែកទី១៖ បេសសកម្មរបស់មន្ត្រីនគរបាលយុត្តិធម៌

មន្ត្រីនគរបាលយុត្តិធម៌ មានភារកិច្ចត្រួតពិនិត្យបទឧក្រិដ្ឋ បទមជ្ឈឹម និងបទលហុ កំណត់អត្តសញ្ញាណ និងចាប់ជនល្មើស ព្រមទាំងប្រមូលភស្តុតាង ហើយមានភារកិច្ចទទួលពាក្យបណ្តឹងធ្វើការស៊ើបអង្កេតបទល្មើសជាក់ស្តែង និងធ្វើការស៊ើបអង្កេតបឋម។[២៥]

### ១. ការពិនិត្យបទល្មើស

ការពិនិត្យបទល្មើសមានន័យថា នៅពេលដែលមន្ត្រីនគរបាលយុត្តិធម៌បានដឹងថាមានបទល្មើសព្រហ្មទណ្ឌណាមួយកើតឡើង គាត់មានសិទ្ធិធ្វើការងារនេះដោយខ្លួនឯង ទោះគ្មានអ្នកប្តឹងក៏ដោយ លើកលេងតែបទល្មើសមួយតែប៉ុណ្ណោះ។

### ២.ការទទួលពាក្យបណ្តឹង

ការទទួលពាក្យបណ្តឹង គឺជាដំណាក់កាលដំបូងនៃសកម្មភាពរបស់មន្ត្រីនគរបាលយុត្តិធម៌ ដែលអាចកំណត់លក្ខខណ្ឌនៃការស៊ើបអង្កេតបាន។ ការទទួលពាក្យបណ្តឹងនេះ អាចជាបណ្តឹងទាមទារ និងបណ្តឹងបរិហារ។

**២.១ បណ្តឹងទាមទារ** គឺជាបណ្តឹងដែលធ្វើឡើងដោយការប្រតិកម្មរបស់បុគ្គល ដែលជាជនរងគ្រោះប្តឹងប្រឆាំងទៅនឹងចារី ដើម្បីឲ្យសមត្ថកិច្ចដោះស្រាយតាមផ្លូវច្បាប់។

**២.២ បណ្តឹងបរិហារ** គឺជាបណ្តឹងរបស់បុគ្គលដែលមិនមែនជាជនរងគ្រោះដោយសារបទល្មើសទេ (តតិយជន) ដោយបានជូនដំណឹងទៅសមត្ថកិច្ចពីព្រឹត្តិការណ៍មួយដែលខ្លួនបានឃើញ ឬបានដឹង។

នៅពេលទទួលពាក្យបណ្តឹងមន្ត្រីនគរបាលយុត្តិធម៌ ត្រូវធ្វើកំណត់ហេតុទទួលពាក្របណ្តឹងដែលមានបញ្ជាក់អត្តសញ្ញាណរបស់អ្នកប្តឹង កាលបរិច្ឆេទនៃការទទួលពាក្យបណ្តឹង អំពីអំពើល្មើសនូវសេចក្តីត្រូវការរបស់អ្នកប្តឹង។

[២៥] មាត្រា៧១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ក្នុងករណីអ្នកប្តឹងមិនចេះភាសាខ្មែរ មន្ត្រីនគរបាលយុត្តិធម៌ត្រូវរកអ្នកបកប្រែដោយហាមមិនឲ្យយកគ្នាឯងដែលចេះភាសាមកបកប្រែទេ គឺត្រូវយកអ្នកក្រៅដែលត្រូវស្បថតាមជំនឿ ឬសាសនាថាខ្លួននឹងបកប្រែភាសាឲបានត្រឹមត្រូវតាមសេចក្តីរាយការណ៍។

ទំព័រនីមួយៗ ត្រូវចុះហត្ថលេខាដោយមន្ត្រីនគរបាលយុត្តិធម៌ និងដោយអ្នកប្តឹង។ ការឆូតការអ្នកប្តឹងនៅរឹមទំព័រ។

មុននឹងចុះហត្ថលេខា ឬផ្តិតស្រាមដៃ អ្នកប្តឹងត្រូវអានកំណត់ហេតុឡើងវិញ។ ក្នុងករណីអ្នកប្តឹងមិនចេះអក្សរ មន្ត្រីនគរបាលយុត្តិធម៌ត្រូវអាននូវខ្លឹមសារកំណត់ហេតុដោយសម្លេងខ្លាំងៗ។[២៦]

នៅគ្រប់អង្គភាពមន្ត្រីនគរបាលយុត្តិធម៌ ត្រូវតែមានបញ្ជីនៃបណ្តឹងមួយសម្រាប់ចុះពាក្យបណ្តឹងនូវនិទ្ទេសដូចតទៅៈ

- អត្តសញ្ញាណរបស់អ្នកប្តឹង
- កាលបរិច្ឆេទនៃការទទួលពាក្យបណ្តឹង
- ឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌ដែលបានធ្វើកំណត់ហេតុស្តីពីការដាក់ពាក្យប្តឹង។
- ប្រភេទនៃអំពើដែលប្តឹង
- ចំណាត់ការលើបណ្តឹងដូចជាបញ្ជូនទៅព្រះរាជអាជ្ញា ឬក៏ផ្តើមធ្វើការស៊ើបអង្កេតដោយខ្លួនឯង។ បញ្ជីនេះត្រូវកាន់កាប់ជាអចិន្ត្រៃយ៍សម្រាប់ជូនអាជ្ញាធរតុលាការតាមត្រូវការ។[២៧]

### ២.៣ ចំណាត់ការលើពាក្យបណ្តឹង

កាលណាទទួលបានបណ្តឹងមន្ត្រីនគរបាលយុត្តិធម៌ត្រូវតែចាត់ការភ្លាមៗ គឺធ្វើការស៊ើបអង្កេតដោយខ្លួនឯង ឬក៏បញ្ជូនកំណត់ហេតុស្តីពីការដាក់ពាក្យបណ្តឹងនោះទៅព្រះរាជអាជ្ញាដើម្បីចាត់ការ។ មុននឹងធ្វើការស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌អាចសុំសេចក្តីណែនាំពីព្រះរាជអាជ្ញា។ ប៉ុន្តែកាលណាទទួលពាក្យបណ្តឹងពីបទឧក្រិដ្ឋ ឬបណ្តឹងបរិហារ ដែលអាចសន្និដ្ឋានបានថាមានបទល្មើស មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនព័ត៌មានដល់ព្រះរាជអាជ្ញា និងសុំការណែនាំ។[២៨]

ក្នុងករណីណាក៏ដោយ មន្ត្រីនគរបាលយុត្តិធម៌មិនអាចតម្កល់រឿងព្រហ្មទណ្ឌណាមួយទុកឥតចាត់ការបានទេ ទោះបីពីមានការសម្រុះសម្រួលគ្នារវាងជនល្មើស និងជនរងគ្រោះក៏ដោយ

[២៦] មាត្រា៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[២៧] មាត្រា៧៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ឬក៏សម្រុះសម្រួល ឬការដកពាក្យបណ្តឹងបានឡើយ។ លើកលែងតែមានបទល្មើសមួយចំនួនប៉ុណ្ណោះ ( អំពើហិង្សាក្នុងគ្រួសារ ឯកពន្ធភាព..................)។

ក្នុងករណីមន្រ្តីនគរបាលយុត្តិធម៌បំពានលើវិធាននេះមានន័យថា បំពានលើសកម្មភាពរបស់តុលាការដែលទាក់ទងនឹងការស្រាវជ្រាវរកភស្តុតាង គឺជាបទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១( មួយ )ឆ្នាំ ទៅ ៣( បី )ឆ្នាំ និងពិន័យជាប្រាក់ពី ២ ( ពីរ )លានរៀល ទៅ ៦( ប្រាំមួយ )លានរៀល។

### ៣. ការស៊ើបអង្កេត

ក្នុងរឿងក្តីព្រហ្មទណ្ឌ ការស៊ើបអង្កេតរបស់មន្រ្តីនគរបាលយុត្តិធម៌ គឺជាដំណាក់កាលដ៏សំខាន់ និងជាចំនុចចាប់ផ្តើម ព្រោះការស៊ើបអង្កេតនេះមានទិសដៅជាការស្រាវជ្រាវដំបូងដែលត្រូវធ្វើឡើងភ្លាមៗបន្ទាប់ពីបានរកឃើញបទល្មើស រួចឈានទៅប្រមូលភស្តុតាង ហើយមន្រ្តីនគរបាលយុត្តិធម៌មានអំណាចខុសគ្នាទៅតាមពេល ដែលមន្រ្តីនោះបំរើការក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតករណីជាក់ស្តែង ឬក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតបឋម មានន័យថាបើករណីការស៊ើបអង្កេតករណីជាក់ស្តែង អំណាចរបស់មន្រ្តីនគរបាលយុត្តិធម៌ត្រូវបានកំណត់ដោយរបបគតិយុត្តមួយផ្សេង បើការស៊ើបអង្កេតបឋម អំណាចរបស់មន្រ្តីនគរបាលយុត្តិធម៌ត្រូវបានកំណត់ដោយរបបគតិយុត្តមួយផ្សេងទៀត។

#### ៣.១ ការស៊ើបអង្កេតជាក់ស្តែង

ការឲ្យអំណាចដ៏ធំធេងដល់មន្រ្តីនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេតបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងដោយសំអាងលើភាពបន្ទាន់នៃការធ្វើសកម្មភាព ដើម្បីបញ្ចប់ភាពវឹកវរដល់សណ្តាប់ធ្នាប់សាធារណៈ និងប្រមូលភស្តុតាងដែលបន្សល់ទុកនៅទីកន្លែងប្រព្រឹត្តបទល្មើស ព្រមទាំងចាប់ខ្លួនចារី។

ការស៊ើបអង្កេតជាក់ស្តែង គឺជាការស៊ើបអង្កេតទៅលើបទល្មើសជាក់ស្តែង ដែលមានថិរវេលាមិនលើសពី៧ (ប្រាពីរថ្ងៃ)ថ្ងៃ គិតថ្ងៃដែលបទល្មើសបានកើតឡើង។ កិច្ចនៃការស៊ើបអង្កេតត្រូវប្រព្រឹត្តទៅជាប់ជានិច្ចនៅក្នុងថិរវេលានេះ។ ប្រសិនបើការស៊ើបអង្កេតមិនបានបញ្ចប់ក្នុងរយៈពេល៧ (ប្រាំពីរ)ថ្ងៃនេះទេ មន្រ្តីនគរបាលយុត្តិធម៌ត្រូវស្នើសុំយោបល់ទៅព្រះរាជអាជ្ញា ដើម្បីធ្វើការបើកអង្កេតបឋម។

[២៨] មាត្រា៧៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

មុននឹងយល់ពីវិធានដែលមន្ត្រីនគរបាលយុត្តិធម៌យកមកអនុវត្ត ចំពោះការស៊ើបអង្កេតបទល្មើសជាក់ស្តែងគប្បីត្រូវយល់ថា តើបទល្មើសដូចម្តេចទើបគេចាត់ទុកថាជាបទល្មើសជាក់ស្តែង?

បទល្មើសជាក់ស្តែងគឺ:

-បទល្មើសដែលកំពុងប្រព្រឹត្ត

-បទល្មើសដែលទើបប្រព្រឹត្តរួចភ្លាម

-កាលណានៅក្រោយពេលមានបទល្មើសរួចបន្តិចមក

-ជនសង្ស័យត្រូវបានសាធារណជន ស្រែកដេញប្រដាប់ចាប់ប្រភឹង

-បុគ្គលដែលគេរកឃើញមានវត្ថុ ឬមានស្លាកស្នាម ឬមានតម្រុយច្បាស់លាស់ហើយស៊ីសង្វាក់ផ្សេងទៀត ដែលនាំឲ្យគេសន្និដ្ឋានបានថា បុគ្គលនោះបានប្រព្រឹត្ត ឬបានចូលរួមប្រព្រឹត្តបទល្មើស។[២៩]

-ត្រូវបានចាត់ទុកដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងផងដែរ គឺគ្រប់បទឧក្រិដ្ឋ ឬបទមជ្ឈិមទាំងឡាយណាដែលត្រូវបានប្រព្រឹត្តនៅក្នុងទីកន្លែងដែលអ្នកកាន់កាប់ទីនោះ សុំឲ្យព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ចូលមកពិនិត្យ ឬភ្នាក់ងារនគរបាលយុត្តិធម៌ ក្នុងករណីដែលគ្មានមន្ត្រីនគរបាលយុត្តិធម៌នៅទីកន្លែងនោះ។[៣០]

ក្នុងករណីមានបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងដូចបានរៀបរាប់ខាងលើ មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ភ្លាមទៅព្រះរាជអាជ្ញា និងចុះទៅកាន់ទីកន្លែងកើតហេតុដើម្បីធ្វើការពិនិត្យបទល្មើស និងធានារក្សាទុកនូវតម្រុយនៃភស្តុតាងទាំងឡាយណាដែលអាចងាយបាត់បង់ និងអាចចាប់យកវត្ថុតាង។ មន្ត្រីនគរបាលយុត្តិធម៌ អាចហាមឃាត់បុគ្គលគ្រប់រូបកុំឲ្យទៅទីណាឆ្ងាយពីកន្លែងកើតហេតុរហូតដល់ពេលបញ្ចប់កិច្ចប្រតិបត្តិការរបស់ខ្លួន។[៣១] មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុស្តីពីការស្រាវជ្រាវ និងការពិនិត្យរបស់ខ្លួន។

ក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង គ្រប់បុគ្គលទាំងអស់អាចចាប់ខ្លួនជនល្មើស ហើយនាំខ្លួនជននោះទៅប្រគល់ជូនមន្ត្រីនគរបាលយុត្តិធម៌ដែលនៅជិតបំផុត។

---

[២៩] មាត្រា៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[៣០] មាត្រា៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[៣១] មាត្រា៨៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ដើម្បីប្រមូលភស្តុតាង មន្ត្រីនគរបាលយុត្តិធម៌អាចហៅ និងនាំមកកាន់អង្គភាពរបស់ខ្លួននូវបុគ្គលគ្រប់រូបដែលសង្ស័យថាបានចូលរួមក្នុងការប្រព្រឹត្តបទល្មើស។ មន្ត្រីនគរបាលយុត្តិធម៌ធ្វើការស្តាប់ចម្លើយជនទាំងនោះ។ ក្នុងការស្តាប់ចម្លើយនីមួយៗត្រូវធ្វើកំណត់ហេតុ ដែលត្រូវដកស្រង់តាមដោយត្រឹមត្រូវនូវសេចក្តីរាយការណ៍របស់បុគ្គលដែលបានផ្តល់ចម្លើយ។ ក្នុងករណីចាំបាច់មន្ត្រីនគរបាលយុត្តិធម៌អាចរកអ្នកបកប្រែភាសា ដែលត្រូវស្បថថានិយាយតែការពិតស្របតាមជំនឿ ឬសាសនារបស់ខ្លួន។ អ្នកបកប្រែមិនអាចជ្រើសរើសយកពីក្នុងចំណោមកងរាជអាវុធហត្ថ ឬបុគ្គលដែលទាក់ទិនក្នុងរឿងជាមួយគ្នាបានទេ។

នៅលើទំព័រនីមួយៗនៃកំណត់ហេតុ ត្រូវចុះហត្ថលេខា ឬផ្តិតម្រាមដៃរបស់បុគ្គលដែលបានផ្តល់ចម្លើយ។ មុននឹងចុះហត្ថលេខា ឬផ្តិតម្រាមដៃ បុគ្គលនោះត្រូវអានកំណត់ហេតុឡើងវិញ។

ក្នុងករណីបុគ្គលដែលផ្តល់ចម្លើយមិនចេះអក្សរ មន្ត្រីនគរបាលយុត្តិធម៌ត្រូវអានដោយសំឡេងខ្លាំងៗ នូវខ្លឹមសារនៃកំណត់ហេតុ។ កាលណាបុគ្គលនោះមិនព្រមចុះហត្ថលេខា ឬមិនព្រមផ្តិតម្រាមដៃទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុ។[៣២]

### ការកោះហៅ និងការបញ្ជូនកំណត់ហេតុទៅព្រះរាជអាជ្ញា

មន្ត្រីនគរបាលយុត្តិធម៌អាចកោះហៅ និងស្តាប់ចម្លើយបុគ្គលគ្រប់រូបដែលអាចផ្តល់ព័ត៌មានស្តីពីរឿងហេតុបាន។ ក្នុងករណីរឹងទទឹងមិនចូលខ្លួន មន្ត្រីនគរបាលយុត្តិធម៌ ត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញាដែលអាចចេញបញ្ជាអោយចូលខ្លួនបាន ហើយមន្ត្រីនគរបាលយុត្តិធម៌អាចប្រើប្រាស់កម្លាំងសាធារណៈ ដើម្បីបង្ខំបុគ្គលនោះអោយចូលបង្ហាញខ្លួនបាន។[៣៣]

ប្រសិនបើត្រូវការធ្វើការពិនិត្យបច្ចេកទេស ឬវិទ្យាសាស្ត្រដែលមិនអាចបង្អង់បានមន្ត្រីនគរបាលយុត្តិធម៌អាចពឹងដល់បុគ្គលដែលមានជំនាញ។ ក្រោយពីបញ្ចប់ការស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនកំណត់ហេតុ និងវត្ថុតាងទាំងអស់ទៅព្រះរាជអាជ្ញា។កាលណាបុគ្គលណាមួយត្រូវបានបញ្ជូនទៅព្រះរាជអាជ្ញា នោះការបញ្ជូនកំណត់ហេតុ និងវត្ថុតាងត្រូវធ្វើជាមួយការបញ្ជូនខ្លួនបុគ្គលនោះដែរ។[៣៤]

[៣២] មាត្រា៩៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[៣៣] មាត្រា៩៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[៣៤] មាត្រា១០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

**ការឆែកឆេរ**

ការឆែកឆេរគឺជា កិច្ចប្រតិបត្តិការមួយរបស់មន្ត្រីនគរបាលយុត្តិធម៌ ដែលត្រូវអនុវត្តឲ្យសមស្របទៅតាមក្រមខ័ណ្ឌនៃការស៊ើបអង្កេតក្នុងគោលបំណងស្វែងរកយ៉ាងហ្មត់ចត់នូវ:

-អាវុធ ឧបករណ៍ សម្ភារៈ ឬវត្ថុផ្សេងៗដែលបានបម្រើឲ្យការប្រព្រឹត្តបទល្មើស

-ផលនៃបទល្មើស

-ភស្តុតាងជាលាយលក្ខណ៍អក្សរ និងតម្រុយផ្សេងៗទៀត។ល។

ក្នុងការស៊ើបអង្កេតករណីជាក់ស្តែងមន្ត្រីនគរបាលយុត្តិធម៌ អាចធ្វើការឆែកឆេរបានតែត្រូវទទួលការអនុញ្ញាតជាបឋមពីព្រះរាជអាជ្ញា ទោះបីការអនុញ្ញាតនោះដោយផ្ទាល់មាត់ក៏ដោយ។ ការឆែកឆេរត្រូវធ្វើនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង បើគ្មានអ្នកកាន់កាប់ទីកន្លែងទេ ត្រូវធ្វើនៅចំពោះមុខសាក្សីពីរនាក់ដែលចាត់តាំងដោយមន្ត្រីនគរបាលយុត្តិធម៌។ សាក្សីនេះមិនអាចជានគរបាល ឬក៏ជាកងរាជអាវុធហត្ថដែលជាកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះបានឡើយ។

មន្ត្រីនគរបាលយុត្តិធម៌ មិនអាចផ្តើមធ្វើការឆែកឆេរមុនម៉ោង ៦(ប្រាំមួយ) ព្រឹកនិងក្រោយម៉ោង ១៨(ដប់ប្រាំបី) ល្ងាចបានឡើយ លើកលែងតែ:

-ក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈឹមជាក់ស្តែង និងករណីការចាត់ទុកដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈឹមជាក់ស្តែង។

-ក្នុងករណីមានសម្រែកអោយគេជួយពីក្នុងទីកន្លែង

-ក្នុងករណីឆែកឆេរនៅទីកន្លែង ក្នុងពេលម៉ោងដែលបើកចំហដល់សាធារណជន

-ក្នុងករណីឆែកឆេរនៅគ្រប់ទីកន្លែងដែលផលិត រក្សាទុក ជួញដូរ ចែកចាយប្រើប្រាស់គ្រឿងញៀន។

មន្ត្រីនគរបាលយុត្តិធម៌មិនអាចធ្វើការឆែកឆេរនៅក្នុងការិយាល័យមេធាវីបានទេ។ មានតែព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរតែប៉ុណ្ណោះ ដែលអាចធ្វើការឆែកឆេរនេះបាន នៅចំពោះមុខប្រធានគណៈមេធាវី ឬប្រតិភូគណៈមេធាវី ឬមេធាវីសាមី។

ចំពោះការឆែកឆេរនៅក្នុងអគារសារព័ត៌មាន សហគ្រាសនៃសារព័ត៌មានសរសេរ ឬសហគ្រាសសារព័ត៌មានសោតទស្សន៍ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើបានតែនៅចំពោះមុខព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរម្នាក់។[៣៥]

---

[៣៥] មាត្រា៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

រាល់ប្រតិបត្តិការឆែកឆេរ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុស្តីពីការឆែកឆេរ ដែលក្នុងនោះត្រូវមានចុះដូចជា:

-ការអនុញ្ញាតរបស់ព្រះរាជអាជ្ញាដោយប្រាប់ថ្ងៃ និងម៉ោងនៃការអនុញ្ញាតនេះ

-អត្តសញ្ញាណរបស់អ្នកកាន់កាប់ទីកន្លែង ឬរបស់សាក្សីនីមួយៗ។

មន្ត្រីនគរបាលយុត្តិធម៌ អាចចាប់យកវត្ថុតាង ដោយត្រូវបិទស្លាកបោះត្រាលើវត្ថុតាងនោះ ក្រោមពីបានបង្ហាញដល់អ្នកកាន់កាប់ទីកន្លែង ឬដល់សាក្សីពីរនាក់មើលរួច ព្រមទាំងធ្វើកំណត់ហេតុស្តីពីការចាប់យក ដែលរួមមានបញ្ជីសារពើភ័ណ្ឌនៃវត្ថុចាប់យក ដោយត្រូវចុះហត្ថលេខា ឬផ្តិតម្រាមដៃដោយអ្នកកាន់កាប់ទីកន្លែង ឬដោយសាក្សីពីរនាក់។

**ការឃាត់ខ្លួន**

ក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង គ្រប់បុគ្គលទាំងអស់អាចចាប់ខ្លួនជនល្មើស ហើយនាំខ្លួនជននោះទៅប្រគល់ជូនមន្ត្រីនគរបាលយុត្តិធម៌ដែលនៅជិតបំផុត ដោយអនុញ្ញាតឲ្យរក្សាទុកជាបណ្តោះអាសន្នក្រោមការចាត់ចែងរបស់ខ្លួន ដើម្បីភាពចាំបាច់នៃការស៊ើបអង្កេតនូវបុគ្គលដែលមានមូលហេតុមួយ ឬច្រើនដោយសង្ស័យថាបានប្រព្រឹត្ត ឬប៉ុនប៉ងប្រព្រឹត្តបទល្មើស។

ដើម្បីឆ្លើយតបនឹងតម្រូវការចាំបាច់នៃការស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌អាចឃាត់ខ្លួនបុគ្គលដែលសង្ស័យថាបានចូលរួមក្នុងការប្រព្រឹត្តបទល្មើស។ មន្ត្រីនគរបាលយុត្តិធម៌ក៏អាចឃាត់ខ្លួនបុគ្គលដែលអាចផ្តល់ព័ត៌មានស្តីពីរឿងហេតុបានដែរ ប្រសិនបើលក្ខខណ្ឌខាងក្រោមបានបំពេញ:

-បុគ្គលដែលអាចផ្តល់ព័ត៌មានប្រកែកមិនព្រមផ្តល់ព័ត៌មាន

-មានការយល់ព្រមជាលាយលក្ខណ៍អក្សរឲ្យធ្វើការឃាត់ខ្លួនពីព្រះរាជអាជ្ញា។

មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ភ្លាមជូនព្រះរាជអាជ្ញា ព្រមទាំងត្រូវបញ្ជូនគ្រប់ភស្តុតាងទាំងអស់ដែលតម្រូវឲ្យមានការឃាត់ខ្លួននេះ។ ការឃាត់ខ្លួនមានថិរវេលា៤៨ម៉ោង គិតចាប់ពីម៉ោងដែលសាមីខ្លួនមកដល់អង្គភាពកងរាជអាវុធហត្ថ។ ប៉ុន្តែចំពោះបទឧក្រិដ្ឋកាលណាមានតម្រុយដែលបង្ហាញឲ្យឃើញថាមានពិរុទ្ធភាពលើបុគ្គលដែលឃាត់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌អាចពន្យារពេលឃាត់ខ្លួនបាន ប្រសិនបើវិធានការនេះជាការចាំបាច់ ដោយត្រូវសុំការអនុញ្ញាតទៅព្រះរាជអាជ្ញាដែលត្រូវផ្ទៀងផ្ទាត់មើលមូលកភាព។ ការអនុញ្ញាតឲ្យពន្យាលពេលឃាត់ខ្លួនត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុដែលត្រូវដាក់បញ្ចូលក្នុងសំណុំរឿង។ រយៈពេលពន្យាលបានតែ២៤ម៉ោង ដោយមិនគិតពីថិរវេលាចាំបាច់ក្នុងការដឹកជញ្ជូន។ ប៉ុន្តែបើបុគ្គលដែលត្រូវឃាត់ខ្លួននោះជាអនីតិជនមិនអាចពន្យាលពេលបានទេ ហើយមន្ត្រីនគរបាលយុត្តិធម៌ត្រូវជនព័ត៌មានតាមគ្រប់

មធ្យោបាយដល់ឪពុកម្តាយ ឬដល់អ្នកតំណាងស្របច្បាប់ ឬដល់អ្នកទទួលភារកិច្ចលើអនីតិជននេះ។

**តារាងរយៈពេលឃាត់ខ្លួន**

| អាយុ | ក្រោម ១៤ឆ្នាំ | ពី១៤ឆ្នាំទៅក្រោម១៦ឆ្នាំ | ពី១៦ឆ្នាំទៅក្រោម១៨ឆ្នាំ | ពី១៨ឆ្នាំឡើងទៅ |
|---|---|---|---|---|
| បទមជ្ឈឹម | មិនអាចឃាត់ខ្លួនបាន | ២៤ម៉ោង | ៣៦ម៉ោង | ៤៨ម៉ោង |
| បទឧក្រិដ្ឋ | មិនអាចឃាត់ខ្លួនបាន | ៣៦ម៉ោង | ៤៨ម៉ោង | ៤៨ម៉ោងអាចពន្យាបាន២៤ម៉ោងទៀត |

កាលណាមានការឃាត់ខ្លួនបុគ្គលណាមួយ មន្ត្រីនគរបាលយុត្តិធម៌ត្រូវឲ្យដំណឹងជាបន្ទាន់អំពីសេចក្តីសម្រេចរបស់ខ្លួនដល់បុគ្គលនោះ ដោយប្រាប់ដល់សាមីខ្លួនឲ្យបានដឹងអំពីមូលហេតុនៃការឃាត់ខ្លួននេះ។ មន្ត្រីនគរបាលយុត្តិធម៌ប្រាប់ដល់សាមីខ្លួនឲ្យបានដឹងផងដែរ អំពីសិទ្ធិជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន។

**ភាតព្វកិច្ចក្នុងការធ្វើកំណត់ហេតុ**

ក្នុងករណីមានការឃាត់ខ្លួនបុគ្គលណាម្នាក់ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើ:

**ទី១.កំណត់ហេតុស្តីពីការឃាត់ខ្លួន**

កំណត់ហេតុស្តីពីការឃាត់ខ្លួន ត្រូវចុះសេចក្តីដូចតទៅ:

-ឈ្មោះ និងឋានៈរបស់មន្ត្រីមគរបាលយុត្តិធម៌ដែលបានបង្គាប់ឲ្យឃាត់ខ្លួន

-អត្តសញ្ញាណនៃបុគ្គលដែលត្រូវឃាត់ខ្លួន

-មូលហេតុដែលត្រូវឃាត់ខ្លួន

-ថ្ងៃ ខែ ឆ្នាំ និងម៉ោងដែលផ្តើមឃាត់ខ្លួន

-ការឲ្យដំណឹងអំពីសិទ្ធិជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន។

-ជាយថាហេតុ ឈ្មោះអ្នកបកប្រែ។

-ត្រូវមានចុះហត្ថលេខា ឬផ្តិតម្រាមដៃរបស់ជនឃាត់ខ្លួន ក្រោយពីបានអានកំណត់ហេតុរួច ឬបើសាមីខ្លួនមិនចេះអក្សរ មន្ត្រីនគរបាលយុត្តិធម៌ត្រូវអានកំណត់ហេតុឲ្យស្តាប់។ បើជននោះប្រកែកមិនព្រមចុះហត្ថលេខា ឬផ្តិតម្រាមដៃទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេស។[៣៦]

ក្រោយពីការឃាត់ខ្លួនបានកន្លងផុតរយៈពេល ២៤ម៉ោង មន្ត្រីនគរបាលយុត្តិធម៌អាចអនុញ្ញាតតាមការស្នើសុំរបស់បុគ្គលដែលឃាត់ខ្លួន សន្ទនាជាមួយមេធាវី ឬជាមួយជនណាម្នាក់ដែលខ្លួនជ្រើសរើស កុំឲ្យតែជននោះមានការទាក់ទិនក្នុងរឿងជាមួយ។ ជនដែលជ្រើសរើសនេះត្រូវបានទទួលដំណឹងតាមគ្រប់មធ្យោបាយ និងជាបន្ទាន់ ហើយអាចចូលទៅកាន់ទីកន្លែងឃាត់ខ្លួននិងទាក់ទងជាមួយបុគ្គលសាមីខ្លួនបាន ៣០(សាមសិប)នាទី ក្នុងលក្ខខណ្ឌធានាការសម្ងាត់នៃការសន្ទនានេះ។[៣៧]

ក្នុងករណីនេះ មន្ត្រីនគរបាលយុត្តិធម៌អាចសុំឲ្យគ្រូពេទ្យមកពិនិត្យបុគ្គលដែលឃាត់ខ្លួនបានគ្រប់ពេលវេលា។

**ទី២.បញ្ជីនៃការឃាត់ខ្លួន**

នៅទីកន្លែងនីមួយៗរបស់កងរាជអាវុធហត្ថ ដែលសម្រាប់ទទួលជនដែលត្រូវឃាត់ខ្លួន ត្រូវមានបញ្ជីស្តីពីការឃាត់ខ្លួនមួយ ដោយមានចុះសេចក្តីដូចតទៅ:

-ឈ្មោះ និងឋានៈមន្ត្រីនគរបាលយុត្តិធម៌ដែលបង្គាប់ឲ្យធ្វើការឃាត់ខ្លួន

-អត្តសញ្ញាណរបស់បុគ្គលដែលឃាត់ខ្លួន

-ថ្ងៃ ខែ ឆ្នាំ និងម៉ោងដែលចាប់ផ្តើមធ្វើការឃាត់ខ្លួន និងបញ្ចប់ការឃាត់ខ្លួន

-ឈ្មោះ និងឋានៈចៅក្រមដែលបានអនុញ្ញាតឲ្យបន្តការឃាត់ខ្លួន ជាយថាហេតុ

-ឈ្មោះគ្រូពេទ្យដែលបានពិនិត្យបុគ្គលឃាត់ខ្លួន ជាយថាហេតុ

-ប្រភេទនៃសេចក្តីសម្រេចរបស់តុលាការនៅពេលផុតកំណត់ការឃាត់ខ្លួន។

បញ្ជីនេះត្រូវកាន់កាប់ជាប្រចាំសម្រាប់ជូនអាជ្ញាធរតុលាការតាមត្រូវការ។[៣៨]

**ទី៣.កំណត់ហេតុសរុបនៃការឃាត់ខ្លួន**

គ្រប់ការឃាត់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែធ្វើកំណត់ហេតុសរុបនៃការឃាត់ខ្លួន ដែលត្រូវចុះនិទ្ទេសដូចតទៅ:

-ឈ្មោះ និងឋានៈមន្ត្រីនគរបាលយុត្តិធម៌ដែលបង្គាប់ឲ្យឃាត់ខ្លួន

---

[៣៦] មាត្រា៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[៣៧] មាត្រា៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[៣៨] មាត្រា១០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

-អត្តសញ្ញាណរបស់បុគ្គលដែលត្រូវឃាត់ខ្លួន

-មូលហេតុនៃការឃាត់ខ្លួន

-ថ្ងៃ ខែ ឆ្នាំ និងម៉ោងដែលចាប់ផ្តើមធ្វើការឃាត់ខ្លួន

-បែបបទនៃការជូនដំណឹងដល់ព្រះរាជអាជ្ញា

-បែបបទនៃការជូនដំណឹង ក្នុងករណីបុគ្គលដែលឃាត់ខ្លួនជាអនីតិជន

-ប្រភេទនៃសេចក្តីសម្រេចរបស់តុលាការនៅពេលផុតកំណត់ការឃាត់ខ្លួន។

-ឈ្មោះគ្រូពេទ្យដែលបានពិនិត្យបុគ្គលឃាត់ខ្លួន

-អត្តសញ្ញាណរបស់ជនដែលបានសន្ទនាជាមួយបុគ្គលឃាត់ខ្លួនស្របតាម មាត្រា ៩៨ (ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន)។

-ឈ្មោះ និងឋានៈរបស់ចៅក្រមដែលជាយថាហេតុបានអនុញ្ញាតឲ្យបន្តការឃាត់ខ្លួន

-ថិរវេលានៃការស្តាប់ចម្លើយនីមួយៗ និងថិរវេលានៃការសម្រាកដែលនៅចន្លោះការស្តាប់ចម្លើយនីមួយៗ។

-ប្រភេទនៃសេចក្តីសម្រេចរបស់អាជ្ញាធរតុលាការនៅពេលបញ្ចប់ការឃាត់ខ្លួន។

-លក្ខខណ្ឌនៃការប្រព្រឹត្តទៅនៃការឃាត់ខ្លួន ព្រមទាំងឧប្បត្តិហេតុជាយថាហេតុ។[៣៩]

នៅពេលផុតកំណត់នៃរយៈពេលឃាត់ខ្លួន បុគ្គលដែលត្រូវបានឃាត់ខ្លួននោះត្រូវបញ្ជូនទៅព្រះរាជអាជ្ញា ឬដោះលែងអោយមានសេរីភាពឡើងវិញ។ សេចក្តីសម្រេចនេះធ្វើឡើងដោយព្រះរាជអាជ្ញា។[៤០] កាលណាបុគ្គលដែលត្រូវឃាត់ខ្លួនត្រូវបញ្ជូនទៅព្រះរាជអាជ្ញា បុគ្គលនេះត្រូវបានគេនាំខ្លួនភ្លាមយកទៅចំពោះមុខព្រះរាជអាជ្ញា។

ប្រសិនបើការបង្ហាញខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួន ពុំអាចធ្វើឡើងនៅថ្ងៃតែមួយបានដោយសារមានមូលហេតុពិសេសដែលបណ្តាលមកពីការលំបាកក្នុងការដឹកជញ្ជូន ឬចម្ងាយផ្លូវនៃការដឹកជញ្ជូន នោះរយៈពេលបន្ថែមអាចផ្តល់ឲ្យដោយព្រះរាជអាជ្ញាបាន។ មូលហេតុនៃការយឺតយ៉ាវត្រូវចុះក្នុងកំណត់ហេតុ ដែលត្រូវប្រគល់ជូនព្រះរាជអាជ្ញាដោយមន្ត្រីនគរបាលយុត្តិធម៌។

[៣៩] មាត្រា១០២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[៤០] មាត្រា១០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

នៅក្នុងគ្រប់ករណីទាំងអស់ ការបង្ហាញខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួន ត្រូវធ្វើឡើងនៅក្នុងរយៈពេលដ៏ឆាប់បំផុតតាមការដែលអាចធ្វើទៅបាន។[៤១]

### ៣.២ ការស៊ើបអង្កេតបឋម

ការស៊ើបអង្កេតបឋម គឺជាការស៊ើបអង្កេតទៅលើបទល្មើសឧក្រិដ្ឋ ឬបទល្មើសមជ្ឈិម ឬបទលហុទាំងឡាយណាដែលមិនជាក់ស្តែង។ ក្នុងករណីនេះមន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការស៊ើបអង្កេតបឋមដោយខ្លួនឯង ឬតាមការសុំរបស់ព្រះរាជអាជ្ញា។

**ការកោះហៅ**

ក្នុងករណីស៊ើបអង្កេតបឋម មន្ត្រីនគរបាលយុត្តិធម៌អាចហៅ និងស្តាប់ចម្លើយបុគ្គលគ្រប់រូបដែលត្រូវបានសង្ស័យថា បានចូលរួមក្នុងបទល្មើស ឬដែលអាចផ្តល់ព័ត៌មានស្តីពីរឿងហេតុ។ បុគ្គលដែលកោះហៅត្រូវតែចូលបង្ហាញខ្លួន។ ក្នុងករណីរឹងទទឹងមិនចូលខ្លួន មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា ដែលអាចចេញបញ្ជាឲ្យចូលខ្លួនបាន ហើយមន្ត្រីនគរបាលយុត្តិធម៌អាចប្រើប្រាស់កម្លាំងសាធារណៈដើម្បីបង្ខំបុគ្គលនោះឲ្យចូលបង្ហាញខ្លួនបាន។[៤២]

**ការឆែកឆេរ**

ក្នុងករណីស៊ើបអង្កេតបឋមដែលទាក់ទងនឹងបទឧក្រិដ្ឋ ឬបទមជ្ឈិម មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរ និងចាប់យកវត្ថុតាងបាន តែជាបឋមត្រូវទទួលការយល់ព្រមច្បាស់លាស់និងពិតប្រាកដពីអ្នកកាន់កាប់ទីកន្លែង។ ការយល់ព្រមនេះត្រូវធ្វើជាលាយលក្ខណ៍អក្សរសរសេរដោយផ្ទាល់ដៃរបស់អ្នកកាន់កាប់ទីកន្លែង។ ប្រសិនបើអ្នកកាន់កាប់ទីកន្លែងមិនចេះអក្សរ នោះមន្ត្រីនគរបាលយុត្តិធម៌ត្រូវសរសេរឲ្យបានច្បាស់លាស់ក្នុងកំណត់ហេតុថា អ្នកកាន់ទីកន្លែងមិនចេះអក្សរ ហើយយល់ព្រមឲ្យឆែកឆេរ។

ក្នុងករណីដែលអ្នកកាន់កាប់ទីកន្លែងអវត្តមាន ឬបដិសេធការឆែកឆេរ ប្រធានសាលាដំបូងដែលមានសមត្ថកិច្ចដែនដី អាចចេញដីការអនុញ្ញាតឲ្យឆែកឆេរតាមការសុំរបស់ព្រះរាជអាជ្ញាហើយព្រះរាជអាជ្ញាត្រូវដឹកនាំដោយផ្ទាល់នូវការឆែកឆេរនេះ នៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ទីកន្លែងទេ ត្រូវធ្វើនៅចំពោះសាក្សីពីរនាក់ដែលត្រូវចាត់តាំងដោយព្រះរាជអាជ្ញា។ សាក្សីមិនអាចជានគរបាល ឬជាកងរាជអាវុធហត្ថដែលជាកម្លាំងរួមប្រតិបត្តការក្នុងការឆែកឆេរនោះឡើយហើយការឆែកឆេរមិនអាចផ្តើមធ្វើមុនម៉ោង ៦(ប្រាំមួយ)ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំបី)

[៤១] មាត្រា១១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[៤២] មាត្រា១១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ល្ងាចឡើយ។[៩៣]

**ការឃាត់ខ្លួន**

ដើម្បីឆ្លើយតបនឹងតម្រូវការចាំបាច់នៃការស៊ើបអង្កេតបឋម មន្រ្តីនគរបាលយុត្តិធម៌អាចឃាត់ខ្លួនបុគ្គលដែលសង្ស័យថា បានចូលរួមក្នុងការប្រព្រឹត្តបទល្មើស តែជាបឋមត្រូវទទួលបានការអនុញ្ញាតពីព្រះរាជអាជ្ញាជាមុនសិន។ មន្រ្តីនគរបាលយុត្តិធម៌ក៏អាចឃាត់ខ្លួនបុគ្គលដែលអាចផ្តល់ព័ត៌មានស្តីពីរឿងហេតុបានដែរប្រសិនបើលក្ខខណ្ឌខាងក្រោមបានបំពេញ:

-បុគ្គលដែលអាចផ្តល់ព័ត៌មានប្រកែកមិនព្រមផ្តល់ព័ត៌មាន

-មានការយល់ព្រមជាលាយលក្ខណ៍អក្សរឲ្យធ្វើការឃាត់ខ្លួនពីព្រះរាជអាជ្ញា។

មន្រ្តីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ភ្លាមជូនព្រះរាជអាជ្ញា ព្រមទាំងត្រូវបញ្ជូនគ្រប់ភស្តុតាងទាំងអស់ដែលតម្រូវឲ្យមានការឃាត់ខ្លួននេះ។

ចំពោះរយៈពេលឃាត់ខ្លួនក្នុងការស៊ើបអង្កេតបឋម គឺដូចគ្នានឹងរយៈពេលឃាត់ខ្លួន នៃការស៊ើបអង្កេតជាក់ស្តែងដែរ។

**៣.៣ ការបញ្ជូននីតិវិធី**

ក្រោមពីធ្វើការស៊ើបអង្កេត (ការស៊ើបអង្កេតជាក់ស្តែង ឬការស៊ើបអង្កេតបឋម) មន្រ្តីនគរបាលយុត្តិធម៌ត្រូវតែបញ្ជូននូវនិតិវិធីភ្ជាប់ជាមួយកំណត់ហេតុ និងរបាយការណ៍ ព្រមទាំងវត្ថុតាង(ប្រសិនបើមាន) ទៅព្រះរាជអាជ្ញា។

**៣.៤ តម្លៃគតិយុត្តនៃកំណត់ហេតុ**

មានតែមន្រ្តីនគរបាលយុត្តិធម៌ប៉ុណ្ណោះ ដែលមានសិទ្ធិសរសេរកំណត់ហេតុ ហើយតាមគោលការណ៍កំណត់ហេតុរបស់មន្រ្តីនគរបាលយុត្តិធម៌ មានតម្លៃត្រឹមតែជាព័ត៌មានប៉ុណ្ណោះ។ ប៉ុន្តែកំណត់ហេតុនេះ ត្រូវទុកជាបន្ទាល់(ឯកសារដើម) មានន័យថា ត្រូវទុកជាឯកសារដែលត្រូវជឿរហូតដល់មានភស្តុតាងផ្ទុយ។ ភស្តុតាងផ្ទុយអាចជូនមកចៅក្រមបានដោយសេរីតាមគ្រប់មធ្យោបាយត្រឹមត្រូវតាមច្បាប់។

ចៅក្រមធ្វើមូលវិចារណ៍ដោយសេរីលើកំណត់ហេតុ ដែលធ្វើដោយមន្រ្តីនគរបាលយុត្តិធម៌ក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតបឋម។

**៤. ការអនុវត្តសេចក្តីសម្រេចរបស់តុលាការ**

នៅគ្រប់ដំណាក់កាលនៃកិច្ចនីតិវិធីទាំងអស់របស់តុលាការ ដើម្បីឲ្យកិច្ចនោះប្រកបដោយ

[៩៣] មាត្រា១៧៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ប្រសិទ្ធភាព និងមានគុណភាពក្នុងការស្វែងរកការពិត និងឈានទៅដល់ការដាក់ទណ្ឌកម្មបុគ្គលដែលជាចារី ជាទូទៅតុលាការមិនអាចបំពេញកិច្ចទាំងនោះតែម្នាក់ឯងបានទេ គឺតែងតែត្រូវការជំនួយពីមន្ត្រីនគរបាលយុត្តិធម៌ ដើម្បីជួយអនុវត្តសេចក្តីសម្រេចរបស់ខ្លួនដូចជា:

**៤.១ ការអនុវត្តដីកាកោះ**

ចំពោះការអនុវត្តដីកាកោះរបស់ព្រះរាជអាជ្ញា ឬចៅក្រម នគរបាលយុត្តិធម៌មានភារកិច្ចត្រឹមតែយកដីការនោះទៅប្រគល់ឲ្យជនដែលត្រូវកោះឲ្យចូលខ្លួនប៉ុណ្ណោះ ដោយមិនមានអំណាចចាប់បង្ខំនាំខ្លួនជននោះបញ្ជូនទៅម្ចាស់ដីកាឡើយ។

**៤.២ ការអនុវត្តដីកាបញ្ជាឲ្យចូលខ្លួន**

ការអនុវត្តដីកាបញ្ជាឲ្យចូលខ្លួនដែលចេញដោយព្រះរាជអាជ្ញា មន្ត្រីនគរបាលយុត្តិធម៌មានភារកិច្ចយកដីការនោះទៅអនុវត្ត ដោយប្រើប្រាស់កម្លាំងសាធារណៈដើម្បីបង្ខំបុគ្គលនោះឲ្យចូលបង្ហាញខ្លួនបាន។

**៤.៣ ការអនុវត្តដីកាបង្គាប់ឲ្យចូលខ្លួន**

ចំពោះការអនុវត្តដីកាបង្គាប់ឲ្យចូលខ្លួន នគរបាលយុត្តិធម៌មានភារកិច្ចត្រឹមតែយកដីកានោះទៅប្រគល់ឲ្យជនដែលត្រូវបង្គាប់ឲ្យចូលខ្លួនតែប៉ុណ្ណោះ ដោយមិនមានអំណាចចាប់បង្ខំនាំខ្លួនជននោះបញ្ជូនទៅម្ចាស់ដីកាឡើយ ព្រមទាំងឲ្យបុគ្គលដែលពាក់ព័ន្ធទទួលចុងដីកា ហើយត្រូវចុះហត្ថលេខានៅលើដើមដីកា ដែលត្រូវបង្វិលជូនចៅក្រមស៊ើបសួរវិញ។ បុគ្គលដែលពាក់ព័ន្ធមានសិទ្ធិចូលក៏បាន មិនចូលក៏បាន។ ប៉ុន្តែក្នុងករណីមិនចូលតាមដីការបង្គាប់ឲ្យចូលខ្លួននេះ នាំឲ្យចៅក្រមចេញដីកាបង្គាប់ឲ្យនាំខ្លួន។

នគរបាលយុត្តិធម៌ ត្រូវជូនដំណឹងដល់ចៅក្រមស៊ើបសួរ នូវគ្រប់ការលំបាកក្នុងការអនុវត្តបេសកកម្មរបស់ខ្លួន។

**៤.៤ ការអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួន**

ការអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួនដែលចេញដោយចៅក្រមស៊ើបសួរ មន្ត្រីនគរបាយុត្តិធម៌អាចប្រើប្រាស់កម្លាំងសាធារណៈចាប់ និងនាំខ្លួនបុគ្គលដែលពាក់ព័ន្ធ រួចបញ្ជូនទៅចំពោះមុខម្ចាស់ដីកា(ចៅក្រមស៊ើបសួរ) តាមគ្រប់មធ្យោបាយដែលអាចធ្វើទៅបាន។

មន្ត្រីនគរនបាលយុត្តិធម៌ មិនអាចចូលទៅក្នុងលំនៅឋានរបស់បុគ្គលដែលពាក់ព័ន្ធមិនម៉ោង៦(ប្រាំមួយ)ព្រឹក និងក្រោមម៉ោង ១៨(ដប់ប្រាំបី)ល្ងាចបានទេ។

ប្រសិនបើក្រោមពេលចាប់ខ្លួន បុគ្គលពាក់ព័ន្ធមិនអាចត្រូវនាំទៅបង្ហាញខ្លួនដល់ចៅក្រមស៊ើបសួរបានទេ ដោយមូលហេតុនៃកាលៈទេសៈ បុគ្គលនេះត្រូវតែនាំខ្លួនទៅក្នុងអង្គភាពកងរាជអាវុធហត្ថក្នុងមណ្ឌលឃុំខ្លួន ឬទៅក្នុងពន្ធធនាគារ។ បុគ្គលនេះត្រូវតែនាំខ្លួនទៅបង្ហាញខ្លួនយ៉ាងយូរបំផុតថ្ងៃបន្ទាប់ដល់ចៅក្រមស៊ើបសួរ ឬដល់អ្នកជំនួស។ បើមិនដូច្នេះទេ ត្រូវដោះលែងឲ្យមានសេរីភាព។

### ៤.៥ ការអនុវត្តដីកាបង្គាប់ឲ្យចាប់ខ្លួន

ក្នុងការអនុវត្តដីការបង្គាប់ឲ្យចាប់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌មានភារកិច្ចយកដីកានេះទៅអនុវត្ត ដោយប្រើប្រាស់កម្លាំងសាធារណៈស្រាវជ្រាវរកចាប់ និងឲ្យនាំខ្លួនបុគ្គលនោះទៅក្នុងពន្ធនាគារ ឬមណ្ឌលឃុំខ្លួន។

មន្ត្រីនគរបាលយុត្តិធម៌ មិនអាចចូលទៅក្នុងលំនៅឋានរបស់បុគ្គលពាក់ព័ន្ធមុនម៉ោង ៦(ប្រាំមួយ)ព្រឹក និងក្រោយម៉ោង ១៨(ដប់ប្រាំបី)ល្ងាចបានទេ ហើយត្រូវឲ្យដំណឹងដល់ចៅក្រមស៊ើបសួរអំពីការលំបាកទាំងអស់ក្នុងពេលអនុវត្តបេសកកម្មរបស់ខ្លួន។

### ៤.៦ ការអនុវត្តដីការបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្ន

ដីកាបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្ន គឺជាសេចក្តីសម្រេចរបស់ចៅក្រម បង្គាប់ឲ្យយកជនល្មើសទៅឃុំខ្លួនក្នុងពន្ធធនាគារ ឬមណ្ឌលឃុំខ្លួន ដែលត្រូវអនុវត្តដោយមន្ត្រីនគរបាលយុត្តិធម៌ ដើម្បីធានាកុំឲ្យជនល្មើសរត់គេចខ្លួន រួចផុតពីការទទួលខុសត្រូវនៅចំពោះមុខច្បាប់ និងមិនអាចប្រព្រឹត្តបទល្មើសផ្សេងទៀត ឬបង្កការលំបាកដល់ដំណើរការស៊ើបសួរ។

ក្នុងន័យនេះ មន្ត្រីនគរបាលយុត្តិធម៌មានភារកិច្ចត្រឹមតែនាំជនល្មើសពីតុលាការទៅប្រគល់ជូនប្រធានពន្ធធនាគារ ឬមណ្ឌលឃុំខ្លួនតែបណ្តោះ។

### ៤.៧ ការអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស

នៅក្នុងដំណាក់កាលនៃការស៊ើបសួរ ដើម្បីឲ្យកិច្ចនៃការស៊ើបសួរប្រកបដោប្រសិទ្ធិភាព និងមានគុណភាពក្នុងការស្វែងរកការពិត ចៅក្រមស៊ើបសួរមិនអាចបំពេញកិច្ចទាំងនោះតែម្នាក់ឯងបានទេ ព្រោះជួនកាលត្រូវជួបប្រទះនូវការលំបាកដូចជា ត្រូវធ្វើការឆែកឆេរព្រមៗគ្នានៅទីកន្លែងជាច្រើនដើម្បីឲ្យមានប្រសិទ្ធិភាពការងារ ឬខ្វះខាតពេលវេលា និងមធ្យោបាយក្នុងការបំពេញកិច្ចនៅតាមសមត្ថកិច្ចដែនដីឆ្ងាយៗ។ ហេតុដូចនេះដើម្បីឲ្យមានប្រសិទ្ធិភាពការងារ ចៅក្រមស៊ើបសួរអាចធ្វើប្រិតភូតកម្មនូវកិច្ចការរួមមួយចំនួនរបស់ខ្លួន ប្រគល់ទៅឲ្យចៅក្រមនៃតុលាការរបស់ខ្លួន ឬតុលាការផ្សេងទៀត ឬមន្ត្រីនគរបាលយុត្តិធម៌ ឬដល់អង្គភាពនគរបាលយុត្តិធម៌ដើម្បីបំពេញកិច្ចស៊ើបសួរ

ជំនួសខ្លួន។ ដីកាចាត់ឲ្យស៊ើបសួរជំនួសមិនអាចមានលក្ខណៈជាទូទៅទេ ត្រូវតែណែនាំឲ្យបានច្បាស់លាស់អំពីប្រភេទនៃកិច្ចដែលត្រូវធ្វើ និងកំណត់ថិរវេលាដែលត្រូវអនុវត្ត ហើយចៅក្រមស៊ើបសួរអាចដកហូតដីកាចាត់ឲ្យស៊ើបសួរជំនួសបានគ្រប់ពេលវេលា។

នៅពេលដែលមន្ត្រីនគរបាលយុត្តិធម៌អនុវត្តដីកាចាត់ឲ្យស៊ើបសួរ មន្ត្រីនគរបាលយុត្តិធម៌ត្រូវស្ថិតនៅក្រោមអំណាចរបស់ចៅក្រមស៊ើបសួរ ហើយត្រូវរាយការណ៍ជូនទៅចៅក្រមស៊ើបសួរនេះតែប៉ុណ្ណោះ។ ក្នុងករណីនេះ មន្ត្រីនគរបាលយុត្តិធម៌មិនអាចធ្វើហួសពីសេចក្តីបង្គាប់ដែលខ្លួនបានទទួលឡើយ គឺត្រូវបំពេញកិច្ចតាមអ្វីដែលមានចែងក្នុងដីកាចាត់ឲ្យស៊ើបសួរជំនួស និងនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន លើកលែងតែមានការពន្លាតសមត្ថកិច្ចដែលមានចែងក្នុងមាត្រា ៦៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌដោយផ្អែកតាមស្ថានភាពចាំបាច់ និងមានការអនុញ្ញាតពីចៅក្រមស៊ើបសួរ។ មន្ត្រីនគរបាលយុត្តិធម៌ធ្វើកំណត់ហេតុស្តីពីការស្រាវជ្រាវ និងការពិនិត្យរបស់ខ្លួន។ កាលណាស្តាប់ចម្លើយដោយអនុវត្តតាមដីកាចាត់ឲ្យស៊ើបសួរជមនួស មន្ត្រីនគរបាលយុត្តិធម៌អាចកោះហៅ និងស្តាប់ចម្លើយសាក្សី។ មុននឹងឆ្លើយសំណួរ សាក្សីម្នាក់ៗត្រូវស្បថតាមសាសនា ឬជំនឿរបស់ខ្លួនថា និយាយតែការពិត លើកលែងសាក្សីដែលអនុញ្ញាតឲ្យរួចពីសម្បថ។

ក្នុងការស្តាប់ចម្លើយដោយអនុវត្តតាមដីការឲ្យស៊ើបសួរជំនួស ដើម្បីគោរពសិទ្ធិការពារខ្លួន មន្ត្រីនគរបាលយុត្តិធម៌មិនអាចស្តាប់ចម្លើយក្នុងឋានៈជាសាក្សី នូវបុគ្គលណាមួយដែលមានតម្រុយនៃពិរុទ្ធភាពលើបុគ្គលនោះទេ។ កាលណាការស្តាប់ចម្លើយសាក្សីណាម្នាក់ បានធ្វើឲ្យលេចតម្រុយនៃពិរុទ្ធភាពលើសាក្សីនោះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ឈប់ការស្តាប់ចម្លើយ ហើយត្រូវរាយការណ៍ជូនចៅក្រមស៊ើបសួរ។ ក្នុងករណីចាំបាច់មន្ត្រីនគរបាលយុត្តិធម៌ អាចហៅរកអ្នកបកប្រែដែលបានស្បថតាមសាសនា ជំនឿរបស់ខ្លួនថា ខ្លួននឹងជួយបកប្រែឲ្យបានត្រឹមត្រូវ។

បុគ្គលដែលកោះហៅក្នុងឋានៈជាសាក្សី ដែលអាចចេញបញ្ជាឲ្យចូលបង្ហាញខ្លួន។

បញ្ជាឲ្យចូលបង្ហាញខ្លួន អនុញ្ញាតឲ្យមន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់កម្លាំងសាធារណៈដើម្បីបង្ខំឲ្យសាក្សីចូលបង្ហាញខ្លួនចំពោះមុខខ្លួន។[៩៩]

**បញ្ជាក់**: មន្ត្រីនគរបាលយុត្តិធម៌មិនអាចស្តាប់ចម្លើយជនត្រូវចោទ ឬស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីបានទេ។

ការអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស មន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់អំណាចដែលប្រគល់ឲ្យតាមការកំណត់ក្នុងដីកាដោយចៅក្រមស៊ើបសួរ នូវអំណាចដែលចៅក្រមស៊ើបសួរ

[៩៩] មាត្រា៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

មានដូចជាការស្តាប់ ការថតសន្ទនាតាមទូរស័ព្ទ ការចាប់ និងការថតគ្រប់ការឆ្លើយឆ្លងតាមមធ្យោបាយទូរគមនាគមន៍ជាអាទិ៍ សារតាមទូរសារ ឬតាមអ៊ិនធើណែត។

ការឃាត់ខ្លួន ការឆែកឆេរ ការចាប់យកវត្ថុតាង និងការបញ្ជូនខ្លួនបុគ្គលដែលបានឃាត់ខ្លួនក្នុងពេលអនុវត្តដីការចាត់ឲ្យស៊ើបសួរជំនួស អំណាចដែលប្រគល់ដោយព្រះរាជអាជ្ញាត្រូវប្រើប្រាស់ដោយចៅក្រមស៊ើបសួរវិញ។

**៥. ឋានានុក្រមក្នុងពេលបំពេញបេសកម្ម**

ក្នុងពេលបំពេញបេសកម្មរបស់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌ទទួលបញ្ជា ឬសុំបញ្ជា តែពីអាជ្ញាធរតុលាការ។[៩៥] មានន័យថា នៅដំណាក់កាលស៊ើបអង្កេតបទល្មើសឧក្រិដ្ឋ ឬបទល្មើសមជ្ឈិមជាក់ស្តែង ឬស៊ើបអង្កេតបឋម ការបំពេញបេសកកម្មរបស់ខ្លួនត្រូវស្ថិតនៅក្រោមការដឹកនាំ និងសម្របសម្រួលការងារពីព្រះរាជអាជ្ញា។[៩៦] នៅក្នុងដំណាក់កាលស៊ើបសួរ កាលណាអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស មន្ត្រីនគរបាលយុត្តិធម៌ស្ថិតនៅក្រោមអំណាចរបស់ចៅក្រមស៊ើបសួរ។[៩៧]

មន្ត្រីនគរបាលយុត្តិធម៌ទទួលអំណាចទាំងអស់ពីព្រះរាជអាជ្ញាមកប្រើប្រាស់ ក្នុងការស៊ើបអង្កេត។ អំណាចទាំងឡាយដែលផ្តល់ឲ្យមន្ត្រីនគរបាលយុត្តិធម៌ខុសគ្នា ទៅតាមពេលដែលមន្ត្រីនោះបំរើការងារក្នុងក្របខណ្ឌនៃការស៊ើបអង្កេតករណីជាក់ស្តែង ឬក្នុងក្របខណ្ឌនៃការស៊ើបអង្កេតបឋម។[៩៨]

ក្នុងការស៊ើបអង្កេត នគរបាលយុត្តិធម៌ទទួលគ្រប់ការណែនាំដែលមានប្រយោជន៍ពីព្រះរាជអាជ្ញា។ ក្នុងករីចាំបាច់ពិសេស ព្រះរាជអាជ្ញាអាចដកសិទ្ធិស៊ើបអង្កេតពីមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ និងរៀបចំជំនួសមន្ត្រី និងភ្នាក់ងារនេះ។

អង្គភាពនគរបាលយុត្តិធម៌ អាចត្រូវបានធ្វើអធិការកិច្ចដោយព្រះរាជអាជ្ញាគ្រប់ពេលវេលា ហើយព្រះរាជអាជ្ញាអាចចូលរួមស្តាប់ចម្លើយ អាចត្រួតពិនិត្យការអនុវត្តវិធានការឃាត់ខ្លួន ជាពិសេសគឺការគោរពទម្រង់ច្បាប់ និងការកាន់កាប់ទីកន្លែងឃាត់ខ្លួនរបស់នគរបាលុត្តិធម៌។[៩៩]

---

[៩៥] មាត្រា៣៧ និងមាត្រា៥៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[៩៦] មាត្រា៣៧ និងមាត្រា១៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[៩៧] មាត្រា៨៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[៩៨] មាត្រា៣៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[៩៩] មាត្រា៣៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

នគរបាលយុត្តិធម៌ទាំងអស់ ត្រូវស្ថិតនៅក្រោមការឃ្លាំមើល ការត្រួតពិនិត្យ និងការអនុវត្ត អំណាចខាងវិន័យរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អាចកោះអញ្ជើញអ្នកទទួលខុសត្រូវនៃអង្គភាពនគរបាលយុត្តិធម៌ ដើម្បីពិភាក្សាអំពីបញ្ហាដែល ទាក់ទងនឹងការប្រព្រឹត្តទៅរបស់អង្គភាពនគរបាលយុត្តិធម៌ ហើយអាចប្រគល់ភារកិច្ចដល់មន្ត្រី នគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់ឲ្យបំពេញកិច្ចទាំងឡាយ ដែលខ្លួនយល់ ឃើញថាមានប្រយោជន៍ដល់ការគ្រប់គ្រង ឬដំណើរការដ៏ល្អនៃនគរបាលយុត្តិធម៌។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អាចចូលរួមក្នុងការស្តាប់ចម្លើយ អាចត្រូវពិនិត្យការ អនុវត្តវិធានការឃាត់ខ្លួន ជាពិសេសគឺការគោរពទម្រង់ការច្បាប់ និងការកាន់កាប់គ្រប់គ្រងកន្លែងឃាត់ខ្លួន។ ប្រធានអង្គភាពនគរបាលយុត្តិធម៌ មន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌គ្រប់រូប ត្រូវគោរពតាមអធិបញ្ញារបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។[៥០]

## ៦. ទម្រង់នៃការបំពេញកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌

រាល់ប្រតិបត្តិការរបស់មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុ ដែលមានចុះហត្ថលេខា ដោយមន្ត្រីនគរបាលយុត្តិធម៌នោះ ដូចជាកំណត់ហេតុលើការស្រាវជ្រាវ និងពិនិត្យ ការបិទស្លាក បោះត្រាលើវត្ថុតាង កំណត់ហេតុលើការស្តាប់ចម្លើយ..........................។

តាមគោលការណ៍កំណត់ហេតុដែលធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ មានតម្លៃគ្រាន់ តែជាព័ត៌មានប៉ុណ្ណោះ។ ប៉ុន្តែកំណត់ហេតុនេះត្រូវទុកជាបន្ទាល់(ឯកសារដើម) មានន័យថាត្រូវ ទុកជាឯកសារដែលត្រូវជឿរហូតដល់មានភស្តុតាងផ្ទុយ។[៥១] ភស្តុតាងផ្ទុយអាចជូនមកចៅក្រម បានដោយសេរីតាមគ្រប់មធ្យោបាយត្រឹមត្រូវតាមច្បាប់។

ព្រះរាជអាជ្ញា ឬចៅក្រមធ្វើមូលវិចារណ៍ដោយសេរី លើកំណត់ហេតុដែលធ្វើឡើងដោយមន្ត្រី នគរបាលយុត្តិធម៌ អាស្រ័យទៅតាមក្របខណ្ឌនៃការស៊ើបអង្កេតជាក់ស្តែង ឬក្របខ័ណ្ឌនៃការ ស៊ើបអង្កេតបឋម។ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវធ្វើកិច្ចទាំងឡាយដោយប្រុងប្រយ័ត្ន និងត្រឹមត្រូវ តាមទម្រង់ការដែលបានកំណត់ដោយក្រមនីតិវិធីព្រហ្មទណ្ឌ ព្រោះថានៅពេលខ្លះបើយល់ឃើញថា មានប្រយោជន៍ ប្រធានសវនាការអាចអញ្ជើញមន្ត្រីនគរបាលយុត្តិធម៌មកផ្តល់នូវចម្លើយក្នុងឋានៈជា សាក្សី។[៥២] ក្នុងករណីនេះ មន្ត្រីនគរបាលយុត្តិធម៌មុននឹងឆ្លើយទៅនឹងសំណួរ ត្រូវធ្វើសម្បថស្រប

[៥០] មាត្រា៣៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[៥១] មាត្រា១១០ និងមាត្រា១១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[៥២] មាត្រា៣២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

តាមសាសនា ឬជំនឿរបស់ខ្លួនថានិយាយតែការពិត។ ការអញ្ជើញមន្ត្រីនគរបាលយុត្តិធម៌ឲ្យមកផ្តល់ចម្លើយនេះគឺដើម្បីបញ្ជាក់ថា តើមានការបង្ខិតបង្ខំឲ្យឆ្លើយដែរ ឬទេ? បើចម្លើយដែលទទួលបានដោយសារការបង្ខិតបង្ខំខាងរូបកាយក្តី ឬផ្លូវចិត្តក្តី គ្មានតម្លៃជាភស្តុតាងទេ។[៥៣]

**៧. កិច្ចដែលមន្ត្រីនគរបាលយុត្តិធម៌ត្រូវជៀសវាង**

ទោះក្នុងករណីណាក៏ដោយមន្ត្រីនគរបាលយុត្តិធម៌មិនត្រូវៈ

-ឃាត់ខ្លួនអនីជនដែលមានអាយុក្រោម១៥ឆ្នាំឡើយ។

-លួចស្តាប់ ឬបង្គាប់ឲ្យស្តាប់ និងថតសម្លេងតាមការសន្ទនាតាមទូរស័ព្ទ និងមិនមានអំណាចបង្គាប់ឲ្យចាប់ និងថតការឆ្លើយឆ្លងដែលចេញតាមមធ្យោបាយទូរគមនាគមន៍ជាអាទិ៍សារតាមទូរសារ ឬតាមអ៊ិនធើណិតដោយឯកឯងទេ។

-តម្កល់រឿងព្រហ្មទណ្ឌណាមួយទុកឥតចាត់ការបានទេ ទោះបីក្រោយពីមានការសម្រុះសម្រួលគ្នារវាងជនល្មើស និងជនរងគ្រោះ ឬក៏មានការដកពាក្យបណ្តឹងក៏ដោយ ព្រោះជាគោលការណ៍ទូទៅបណ្តឹងអាជ្ញាមិនអាចរលត់ដោយសារការសម្រុះសម្រួល ឬការដកពាក្យបណ្តឹងទេលើកលែងតែបទល្មើសមួយចំនួនប៉ុណ្ណោះ ដូចជាអំពើហិង្សាក្នុងគ្រួសារ ឯកពន្ធភាព.................។

-រក្សាទុកកំណត់ហេតុ ឬវត្ថុតាងដោយចេតនា ឬក៏លាក់បំបាំងដល់អាជ្ញាធរតុលាការអំពីអត្ថិភាពនៃកំណត់ហេតុ ឬវត្ថុតាងទេ។

-ទម្លាយការសម្ងាត់នៃការស៊ើបអង្កេត ឬស៊ើបសួរ។

-ប្រព្រឹត្តអំពើពុករលួយជាដាច់ខាត ហើយត្រូវប្រយុទ្ធប្រឆាំងអំពើរលួយនេះឲ្យបានយ៉ាងខ្លាំងក្លាបំផុត។

**ផ្នែកទី២-បេសកកម្មរបស់ភ្នាក់ងារនគរបាលយុត្តិធម៌**

ភ្នាក់ងារនគរបាលយុត្តិធម៌មានភារកិច្ចៈ

-ពិនិត្យបទល្មើស ជាអាទិ៍ បទលហុ

-ជួយដល់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការបំពេញមុខងាររបស់គេ។

**១.ឋានានុក្រមក្នុងការបំពេញបេសកកម្ម**

រាល់ប្រតិបត្តិការរបស់ភ្នាក់ងារនគរបាលយុត្តិធម៌ត្រូវស្ថិតនៅក្រោមការដឹកនាំ និងសម្របសម្រួលរបស់ព្រះរាជអាជ្ញា។

[៥៣] មាត្រា៧១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញ

**២.ទម្រង់នៃការបំពេញកិច្ចរបស់ភ្នាក់ងារនគរបាលយុត្តិធម៌**

ចំពោះការពិនិត្យបទល្មើស ភ្នាក់ងារនគរបាលយុត្តិធម៌ត្រូវធ្វើរបាយការណ៍។ របាយការណ៍នេះ មានតម្លៃត្រឹមតែជាព័ត៌មានធម្មតាតែប៉ុណ្ណោះ។

ក្នុងករណីណាក៏ដោយ ភ្នាក់ងារនគរបាលយុត្តិធម៌មិនអាចបំពេញកិច្ចទាំងឡាយដែលត្រូវរក្សាទុកជូនតែមន្ត្រីនគរបាលយុត្តិធម៌បានទេ។ កិច្ចទាំងឡាយណាដែលបាបំពេញដោយបំពានលើការហាមឃាត់នេះ ត្រូវចាត់ទុកជាមោឃៈ។[៥៤]

រាល់ការបំពេញកិច្ច ភ្នាក់ងារនគរបាលយុត្តិធម៌ត្រូវរាយការណ៍ជាបន្ទាន់ជូនមន្ត្រីនគរបាលយុត្តិធម៌។

[៥៤] មាត្រា៧៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

# សេចក្តីសន្និដ្ឋាន

# និង

# អនុសាសន៍

# សេចក្តីសន្និដ្ឋាន និង អនុសាសន៍

## សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទ តួនាទី ភារកិច្ច កងរាជអាវុធហត្ថលើផ្ទៃប្រទេសរួចមក អាចធ្វើសេចក្តីស្និដ្ឋានបានថា តាំងពីការចាប់បដិសន្ធិឆ្នាំ១៩៥៤ និង ការបង្កើតជាផ្លូវការនាឆ្នាំ១៩៥៧ រហូតដល់បច្ចុប្បន្នឃើញថាកងរាជអាវុធហត្ថមានការវិវត្ត ព្រមទាំងមានកំណែទម្រង់ជាច្រើនដំណាក់កាល។ ពីឆ្នាំ១៩៥៧ ដល់ឆ្នាំ១៩៧០ មានឈ្មោះថា កងរាជអាវុធហត្ថខ្មែរ ហើយមានភារៈ និងបំពេញបេសកកម្មខាងការពារប្រទេសជាតិ និងផ្តល់ការជួយដល់អំណាចទាហាន រដ្ឋបាល និងតុលាការ។ ចាប់ពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ ប្តូរឈ្មោះមកជា កងរាជអាវុធហត្ថជាតិ ហើយមានភារកិច្ចរ៉ាបរងខាងប៉ូលិសយោធា ខាងប៉ូលិសរដ្ឋបាល ខាងប៉ូលិសតុលាការ។ ប៉ុន្តែការបង្កើត កងរាជអាវុធហត្ថសារជាថ្មីឡើងវិញ ចាប់ពីឆ្នាំ១៩៩៣ រហូតមកដល់បច្ចុប្បន្ន បានធ្វើឲ្យតួនាទី និងភារកិច្ច ត្រូវបានពង្រីកយ៉ាងទូលំទូលាយពេញផ្ទៃប្រទេសទាំងមូល។ ការកំណត់ឲ្យមានមុខងារជានគរបាលរដ្ឋបាល មុខងារជានគរបាលយុត្តិធម៌ និងបំពេញបេសកកម្មដែលមានលក្ខណៈពិសេសខាងយោធា បានផ្តល់សិទ្ធិអំណាចឲ្យកងរាជអាវុធហត្ថ មានលទ្ធភាពគ្រប់គ្រាន់ ព្រមទាំងករណីយកិច្ចពេញលេញក្នុងការបម្រើប្រជារាស្ត្រ និងសង្គមជាតិដោយបង្កើតបាននូវសមិទ្ធិផលដ៏ត្រចះត្រចង់យ៉ាងច្រើនគួរឲ្យកត់សំគាល់ និង ជាមោទនៈក្រៃលេង។ កត្តាទាំងនេះបញ្ជាក់ឲ្យឃើញថា កងរាជអាវុធហត្ថ គឺជាកំលាំងមួយមិនអាចខ្វះបានក្នុងការចូលរួមចំណែករក្សាស្ថេរភាព សុវត្ថិភាព ការការពារសណ្តាប់ធ្នាប់សាធារណៈសង្គម សន្តិសុខនយោបាយ និងកិច្ចអភិវឌ្ឍន៍សង្គមជាតិ។

ទន្ទឹមនឹងគុណសម្បត្តិខាងលើ ច្បាប់វិសោធនកម្មមាត្រា៣៦ បានកាត់បន្ថយនូវមុខងារជានគរបាលយុត្តិធម៌របស់កងរាជអាវុធហត្ថ ដែលជាហេតុបណ្តាលឲ្យជះឥទ្ធិពល និងបង្កនូវភាពអសកម្មមួយចំនួនក្នុងសកម្មភាពបង្ក្រាប និងទប់ស្កាត់នូវបទល្មើសផ្សេងៗ ដែលជាការផ្តល់ឱកាសឲ្យជនល្មើសបង្កើនសកម្មភាពក្នុងការង្គអស្ថេរភាព អសន្តិសុខដល់សង្គមជាតិ និង ប្រជាពលរដ្ឋ។ ជាមួយគ្នានេះដែរបុគ្គលឱកាសនិយមមួយចំនួនតូចបានបង្កើតនូវបាតុកម្មខុសឆ្គងមួយចំនួន ដោយយកសិទ្ធិអំណាចនិងកេរ្តិ៍ឈ្មោះកងរាជអាវុធហត្ថទៅប្រើប្រាស់ខុសគោលការណ៍ ខុសបទបញ្ជា វិន័យ ដើម្បីលាភសក្ការៈ និងប្រយោជន៍ផ្ទាល់ខ្លួន។ នេះគឺជាមូលហេតុបណ្តាលឲ្យកើតមាននូវកំហុសឆ្គង ដែលជាគុណវិបត្តិធ្វើឲ្យប៉ះពាល់ដល់កិត្តិយស សេចក្តីថ្លៃថ្នូរ នៃស្ថាប័នកងរាជអាវុធហត្ថជាតិ។ តាមទស្សនៈសមត្ថកិច្ចពីរនាក់ចាប់ជនល្មើសម្នាក់ ប្រសើរជាងសមត្ថកិច្ចម្នាក់ចាប់ជនល្មើសម្នាក់ គឺមានភាពឡូស៊ិក និងមានលក្ខណៈវិជ្ជមានក្នុងការយុទ្ធនាការបង្ក្រាបបទល្មើសផ្សេងៗ ព្រោះថាកងរាជអាវុធ

ហត្ថ ត្រូវមានភារកិច្ចក្នុងមុខងារនគរបាលយុត្តិធម៌ ដូចកងកំលាំងនគរបាលជាតិដែរ គឺស្ថិតនៅក្រោមបញ្ជាថ្នាក់ដឹកនាំតែមួយជាមួយគ្នា។ ម្យ៉ាងទៀតទាំងចៅក្រម ព្រមទាំងប្រជាពលរដ្ឋ គឺមានសិទ្ធិក្នុងការជ្រើសរើសចំពោះស្ថាប័នណាមួយ ឬ សមត្ថកិច្ចណាមួយ ដែលគាត់មានការជឿជាក់ និងមានទំនុកចិត្តដើម្បីបម្រើឲ្យខ្លួន។ ដើម្បីបង្កើនបានទំនុកចិត្តពីប្រជាពលរដ្ឋ រាជរដ្ឋាភិបាល ព្រមទាំងអាជ្ញាធរផ្សេងទៀត ស្ថាប័នកងរាជអាវុធហត្ថត្រូវពិនិត្យជាចាំបាច់នូវបុគ្គលិករបស់ខ្លួនក្នុងការគោរព អនុវត្តនូវតួនាទី ភារកិច្ច ដោយគោរពម៉ឹងម៉ាត់ហ្មត់ចត់តាមក្បួនខ្នាតអនុក្រឹត្យ ក្រមសីលធម៌វិជ្ជាជីវៈ និងនីតិវិធីច្បាប់។

ឆ្លងកាត់បទពិសោធន៍កន្លងមកតម្រូវឲ្យកងរាជអាវុធហត្ថម្នាក់ៗ មានសមត្ថភាពយល់ដឹងបានស៊ីជម្រៅលើគ្រប់បញ្ហា ដែលទាក់ទងទៅនឹងការអនុវត្តច្បាប់គ្រប់ប្រភេទ ព្រោះថាច្បាប់ជាត្រីវិស័យបង្ហាញផ្លូវក្នុងកិច្ចប្រតិបត្តិការគ្រប់រូបភាព និងគ្រប់យថាហេតុ ដោយឆ្លុះបញ្ចាំងឲ្យឃើញពីសារៈសំខាន់របស់ខ្លួនកងរាជអាវុធហត្ថបានធ្វើការអភិវឌ្ឍទៅរកការរីកចម្រើនទាំងបរិមាណ គុណភាព ស្មេរភាព ក្នុងការទទួលរ៉ាប់រងក្នុងគ្រប់សកម្មភាពទាំងឡាយដែលត្រូវបានប្រគល់សិទ្ធិជាបន្តបន្ទាប់។ ជោគជ័យជាជំហានៗនៃដំណើរការប្រជាធិបតេយ្យភាវូបនីយកម្ម និងការកសាងសង្គមមួយឲ្យមានលក្ខណៈជានីតិរដ្ឋ គឺមួយផ្នែកអាស្រ័យទៅលើប្រសិទ្ធិភាពក្នុងការអនុវត្ត និងការធ្វើកំណែទម្រង់នៃប្រព័ន្ធកងកំលាំងប្រដាប់អាវុធឲ្យមានភាពរឹងមាំ។ រាល់អត្ថបទច្បាប់ និងបទបញ្ជាទាំងឡាយដែលបានកំណត់អំពីតួនាទីភារកិច្ចរបស់កងរាជអាវុធហត្ថ ក្នុងកិច្ចទំនាក់ទំនងការងារជាមួយអាជ្ញាធរនានាទាំងស៊ីវិល ទាំងយោធាបានផ្តល់សិទ្ធិ និងអំណាចដល់កងរាជអាវុធហត្ថ ក្នុងការផ្តល់នូវកំលាំងជំនួយរបស់ខ្លួនដែលមានលក្ខណៈសមស្របដល់អាជ្ញាធរសាធារណៈនៅពេលចាំបាច់។ ជាក់ស្តែងដោយអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវបទបញ្ញត្តិរបស់កងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថបានរួមចំណែកដោះស្រាយនូវកិច្ចការធំៗជាច្រើនក្នុងរយៈពេលកន្លងមក។ ប្រសិទ្ធភាពរបស់កងរាជអាវុធហត្ថ ដែលស្ថិតនៅលើតម្លៃ និងគុណធម៌ របស់នាយ និងពលអាវុធហត្ថម្នាក់ៗនោះ គឺការផ្តើមចេញពីការយល់ដឹងអំពីច្បាប់ ការគោរពវិន័យ និងករណីកិច្ចរបស់ខ្លួនក្នុងស្មារតីរបស់ខ្លួន ហ៊ានពលីកម្មគ្រប់យ៉ាងប្រកបដោយភក្តីភាពនិងសេចក្តីស្មោះត្រង់ ដើម្បីបុព្វហេតុជាតិមាតុភូមិ និងប្រជារាស្ត្រ។ នៅក្នុងកាលៈទេសៈចាំបាច់ណាមួយដែលជាប្រយោជន៍ដល់ប្រទេសជាតិ មាតុភូមិ និងប្រជាពលរដ្ឋ កំលាំងកងរាជអាវុធហត្ថនឹងត្រូវទទួលបេសកកម្មពិសេសនៅសមរភូមិទៀតផង ដើម្បីការពារឯករាជ្យ អធិបតេយ្យភាព សុខសន្តិភាព និងសេចក្តីសុខក្សេមក្សាន្ត។ ចក្ខុវិស័យទាំង

នេះ គឺជាខ្នាតសម្រាប់វាស់នូវដំណើរការអនុវត្តរបស់ប្រព័ន្ធកងកំលាំងប្រដាប់អាវុធនៅកម្ពុជាបច្ចុប្បន្ន និងទៅអនាគត។

# អនុសាសន៍

យោងតាមពាក្យស្លោកមួយពោលថា (ស្រុកមានសង្គ្រាមគេត្រូវការអ្នកក្លាហាន ស្រុកបានសាន្តត្រាណគេត្រូវការអ្នកចេះដឹង) មានកងទ័ពមិនហ្វឹកហាត់ គឺដូចជាព្រលែងហ្វូងចៀមចូលក្នុងហ្វូងចចក។ ជំនាន់នេះ គឺជាសម័យអន្តរកាលជំនាន់មួយរវាងប្រជាជនចាស់អ្នកតស៊ូសម័យសង្គ្រាមពីមុន និង យុវជនជំនាន់ថ្មីដែលមានទ្រឹស្តីអប់រំសម័យទំនើប។ ទស្សនអ្នកក្លាហានយល់ថា "យុវជនអត់បានជួយតស៊ូអ៊ីចឹងដល់មានសន្តិភាពហេតុអ្វីស្រួលៗត្រូវផ្ទេរអំណាច? "យុវជនសម័យសន្តិភាពស្រាប់តែយល់ឃើញថា "មានតែអ្នកចេះដឹងទេទើបអាចកសាងសង្គមមួយរីកចម្រើនបាន ពីព្រោះអ្នកក្លាហានបានត្រឹមតែពន្លត់ភ្លើងសង្គ្រាមតែប៉ុណ្ណោះ"។ តើអ្នកក្លាហាន (អ្នកតស៊ូរំដោះជាតិខ្មែរសម័យសង្គ្រាម) និងអ្នកចេះដឹង (យុវជនសម័យសន្តិភាព) អាចស្រុះស្រួលដោយងាយស្រួលទេ? ហើយតើយុវជនគួរដោះស្រាយបញ្ហានេះដោយរបៀបណា? បើមិនទាន់អាចធ្វើបានសូមត្រឹមតែត្រៀមខ្លួនទៅបានហើយពីព្រោះគ្មានអ្វីមួយ ឬគ្មាននរណាម្នាក់អមតទេ។ យើងគ្រាន់តែត្រូវចាំថា "យើងមិនអាចក្លាយទៅជាយុវជនខ្លាំងក្នុងថ្ងៃនេះ តែយើងអាចប្រឹងប្រែងរៀនសូត្រចាប់ពីថ្ងៃនេះតទៅ ដើម្បីត្រៀមខ្លួនជួយសង្គមជាតិឱ្យខ្លាំងនាពេលអនាគត"។ សង្គមមួយរីចម្រើនខ្លាំងជាសង្គមដែលមានធនធានមនុស្សខ្លាំងពោល គឺជាធនធានមនុស្សដែលមានការអប់រំខ្ពស់មានការគិតស៊ីជម្រៅមានគំនិតច្នៃប្រឌិតខ្ពស់ និងមានភាពជាពលរដ្ឋល្អ។ល។ ផ្ទុយទៅវិញពលរដ្ឋដែលមានផ្នត់គំនិតពឹងផ្អែកតែសង្គម ឬ រស់ដោយសារតែសង្គមផ្តល់ឲ្យ គឺពួកគេតែងតែចោទសួរថាតើសង្គមអាចជួយ ឬ ផ្តល់អ្វីខ្លះដល់ខ្ញុំ(ពលរដ្ឋ)? នៅក្នុងសង្គមដែលមានធនធានមនុស្សបែបនេះពិតជាមិនអាចអភិវឌ្ឍន៍ប្រទេសឲ្យរីកចម្រើនបានឡើយ។ មុននឹងអភិវឌ្ឍន៍សង្គមជាតិមួយឲ្យមានអ្វីៗគ្រប់យ៉ាង គឺមេដឹកនាំគ្រប់ជាន់ថ្នាក់ ឪពុកម្តាយ អាណាព្យាបាល និងលោកគ្រូអ្នកគ្រូគ្រប់រូបត្រូវបណ្តុះផ្នត់គំនិតដល់ពលរដ្ឋយុវជន និងសិស្សនិស្សិតទាំងអស់ឲ្យមានគតិបណ្ឌិតក្នុងខ្លួន និងមានមនសិការស្នេហាសង្គមជាតិជាមុនសិន។

- ការអភិវឌ្ឍខ្លួន គឺជាជំហានដំបូងមុននឹងឈានទៅចូលរួមជួយអភិវឌ្ឍន៍សង្គមជាតិ។ ដូច្នេះអ្នកត្រូវស្គាល់ខ្លួនឯងឲ្យបានច្បាស់ពោល គឺស្គាល់ពីចំណង់ចំណូលចិត្តទេពកោសល្យចំនុចខ្លាំងខ្សោយខ្លួនឯងហើយចាប់ផ្តើមកំណត់គោលដៅជីវិតឲ្យបានច្បាស់។ នៅពេលអ្នកស្គាល់ខ្លួនឯងច្បាស់ គឺអ្នកអាចជួយអភិវឌ្ឍន៍សង្គមជាតិទៅតាមគោលដៅជីវិតរបស់អ្នកបានយ៉ាងងាយស្រួល ពេលនោះគោលដៅនៅក្នុងជីវិតរបស់អ្នកក៏ទទួលបានជោគជ័យហើយកិច្ចការជួយអភិវឌ្ឍន៍សង្គមក៏-អ្នកបានធ្វើ។

- បង្កើនចំណេះដឹងខ្លួនឯង គឺ ខំរៀនឲ្យពូកែដោយត្រូវស្វែងរកចំណេះដឹងបន្ថែមក្រៅពីរៀននៅសាលាដូចជា៖ អានសៀវភៅស្តាប់កម្មវិធីវិទ្យុមើលកម្មវិធីទូរទស្សន៍រៀនពីបុគ្គលឆ្នើមបុគ្គលជោគជ័យសាលាដូចជា៖ អានសៀវភៅស្តាប់កម្មវិធីវិទ្យុមើលកម្មវិធីទូរទស្សន៍រៀនពីបុគ្គលឆ្នើមបុគ្គលជោគជ័យ ចូលរួមក្នុងវិទិកាសាធារណៈ និងសិក្ខាសាលានានាដែលទាក់ទិននឹងការអប់រំការអភិវឌ្ឍខ្លួនឯង និងបញ្ហាសង្គមជាតិនានា។
- ភាពជាពលរដ្ឋ គឺគោរពតាមច្បាប់ដែលរដ្ឋបានកំណត់មានសីលធម៌ល្អមានគោលការណ៍ សុចរិតភាពចូលរួមដោះស្រាយបញ្ហាសង្គមជាតិមិនប្រព្រឹត្តិអំពើពុករលួយមិនរំលោភទ្រព្យសម្បត្តិ និងសិទ្ធិអ្នកដទៃមិនបង្កហិង្សាលើអ្នកដទៃមិនគាំទ្រសកម្មភាពដែលបំផ្លាញជាតិ និងមិនធ្វើសកម្មភាព ឬ ទង្វើណាដែលប៉ះពាល់ដល់សង្គមឡើយ។
- បណ្តុះផ្នត់គំនិតស្រឡាញ់ជាតិ គឺតាមដានព្រឹត្តិការណ៍សង្គមស្ថានការណ៍នៃការវិវត្តក្នុងសង្គម ចូលរួមចំណែកដោះស្រាយបញ្ហាសង្គម និង អភិវឌ្ឍន៍សង្គមតាមរយៈការបរិច្ចាគកម្លាំងកាយ កម្លាំងចិត្ត ប្រាជ្ញា ឬ ទ្រព្យសម្បត្តិផ្សេងៗទៅតាមអ្វីដែលអ្នកអាចធ្វើបានដើម្បីសង្គមជាតិ។

- ធ្វើការស្ម័គ្រចិត្តជួយសង្គម គឺយកពេលទំនេរ ឬ ឆ្លៀតពេលខ្លះដើម្បីធ្វើកិច្ចការស្ម័គ្រចិត្តជួយ អភិវឌ្ឍន៍សង្គមជាតិដូចជា៖ ការសម្អាតទីធ្លាសាធារណៈការដាំកូនឈើជួយមនុស្សមានវិបត្តិមនុស្ស ចាស់ ឬ ជួយបណ្តុះបណ្តាលចែករំលែកចំណេះដឹង និងបទពិសោធន៍ទៅដល់អ្នកដទៃ។ល។ កងរាជអាវុធហត្ថគប្បីត្រូវមានចំណេះដឹងជំនាញ និងភាពក្លាហានដែរចាំបាច់ត្រូវដើរទន្ទឹមគ្នាក្នុងការបំពេញការងារប្រកបទៅដោយឆន្ទៈ ស្មារតីអង់អាចក្លាហាន សមត្ថភាពជំនាញ ការទទួលខុសត្រូវខ្ពស់ និងភាពជាអ្នកដឹកនាំជាកត្តាសំខាន់ណាស់សម្រាប់ភាពជោគជ័យបន្ថែមពីលើនេះទៀតដើម្បីលើកកំពស់ថែមទៀតនូវសមត្ថភាព ប្រសិទ្ធិភាពការងាររបស់កងរាជអាវុធហត្ថក្នុងការធានានិរន្តរភាព និងរក្សាបាននូវកិត្យានុភាពនោះ។ ទស្សនៈទានដើម្បីរួមចំណែកឲ្យកងរាជអាវុធហត្ថមានភាពរឹងមាំ និងមានការអភិវឌ្ឍរីកចម្រើន ព្រមទាំងស្ថិតក្នុងបរិមាណសមស្របដោយធានាបាននូវគុណភាពការងារប្រកបដោយធនធានបញ្ញា ហើយដែលជាសេចក្តីត្រូវការដ៏សំខាន់មិនអាចខ្វះបាន។ គោលការណ៍នេះត្រូវប្រើប្រាស់វិធានការជាជំហានៗ ទោះបីត្រូវចំណាយពេលវេលា ឬជួយឧបសគ្គយ៉ាងណាក៏ដោយ គឺត្រូវធ្វើដំណើរឲ្យដល់គោលដៅជាចាំបាច់ដើម្បីធ្វើឲ្យសង្គមមានស្ថេរភាព សមភាពយុត្តិធម៌មានការគោរពច្បាប់មានការការពារសិទ្ធិមនុស្សប្រកបដោយលទ្ធិប្រជាធិបតេយ្យសេរី និងគ្មាននិទណ្ឌភាពឈានឆ្ពោះទៅកាន់សង្គមនីតិរដ្ឋ។ ដូច្នេះដើម្បីធានា

ឲ្យបាននូវបញ្ហាទាំងនេះ គួរតែធ្វើការកែលំអ និងអនុវត្តបន្តនូវរាល់តួនាទី និងភារកិច្ចរបស់ខ្លួន ដោយផ្អែកតាមយុទ្ធសាស្ត្រកំណែទម្រង់មួយចំនួនដូចខាងក្រោមនេះ៖

-បន្តខិតខំបណ្តុះបណ្តាលធនធានមនុស្ស ទាំងជំនាញឯកទេសវិជ្ជាជីវៈ ក៏ដូចជាភាសារបរទេស ដើម្បីកសាងលើកកំពស់សមត្ថភាព និងធានាបានទាំងបរិមាណ និងគុណភាព ដោយបន្តចាត់បញ្ជូនកង

កំលាំងឲ្យទៅសិក្សាទាំងក្នុង និងក្រៅប្រទេសឲ្យបានច្រើនជាងមុន។

-ជំរុញរៀបចំបង្កើតបណ្ណាល័យ បង្កើតគេហទំព័រ (Website) សម្រាប់កងរាជអាវុធហត្ថ ដើម្បីផ្សព្វផ្សាយ និងទទួលជ្រួតជ្រាបតាមប្រព័ន្ធព័ត៌មានវិទ្យាឲ្យបានទូលំទូលាយទាំងក្នុង និងក្រៅប្រទេស។

-ពង្រឹងពង្រីកសមត្ថភាពស្ថាប័ន អង្គភាពលើវិស័យច្បាប់ ធានាប្រសិទ្ធិភាពក្នុងការគ្រប់គ្រងកំលាំងតាមឋានានុក្រមការងារឲ្យកាន់តែមានតម្លាភាព។

-បន្តបំពាក់សម្ភារៈ មធ្យោបាយ ឧបករណ៍បន្ថែមទៀត ដល់គ្រប់កងឯកភាពដើម្បីបង្កើនប្រសិទ្ធិភាព ប្រតិបត្តិការ ដោយពង្រីកសមត្ថភាពបច្ចេកទេសតាមប្រព័ន្ធបច្ចេកវិទ្យាទំនើប។

-បង្កើនការយកចិត្តទុកដាក់អនុវត្តនូវគោលការណ៍លើកទឹកចិត្ត លើកសរសើរ ជូនរង្វាន់ដល់បុគ្គលដែលមានស្នាដៃក្នុងការបំពេញភារកិច្ច ដោយយកចិត្តជាពិសេសចំពោះកងកំលាំងអាវុធហត្ថដែលចូលនិវត្តន៍ និង ក្រុមគ្រួសារអាវុធហត្ថដែលពលី មរណៈ ក្នុងបេសកកម្ម ហើយក្នុងនោះត្រូវយកចិត្តទុកដាក់ខ្ពស់ចំពោះបញ្ហាប្រាក់បៀវត្សរ៍ដល់នាយ នាយរង និងពលអាវុធហត្ថឲ្យបានក្នុងកម្រិតមួយសមស្រប។

-បន្តកិច្ចសហការល្អជាមួយស្ថាប័នពាក់ព័ន្ធ ពិសេសស្ថាប័ននគរបាលជាតិ និងតុលាការ។

-គួរពិចារណាដល់ទាហានចំណាស់ និងអ្នកបាត់បង់សមត្ថភាពការងារ ឲ្យបានចូលនិវត្តន៍តាមច្បាប់ ឬផ្ទេរទៅក្រសួងការពារជាតិ ឬ ក្រសួងសង្គមកិច្ច ដើម្បីបំពេញកំលាំងថ្មីជំនួស។

-គួរលើកសំណើបង្កើនចំនួនទ័ពឲ្យកងរាជអាវុធហត្ថទៅតាមតម្រូវការភារកិច្ច ដែលធ្វើឲ្យកងរាជអាវុធហត្ថអាចបំពេញការងារបានតាមខ្លឹមសារនៃអនុក្រឹត្យលេខ៧៧ អនក្រ.បក ពោលគឺមានកំលាំងបំពេញភាកិច្ចបានទូទាំងប្រទេស ប្រកបដោយគុណភាព និងមានប្រសិទ្ធិភាពខ្ពស់។

-គួរធ្វើការកែសម្រួលផ្នែកប្រឆាំងភេរវកម្ម ឲ្យទៅជាការិយាល័យប្រឆាំងភេរវកម្ម នៅបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស និងបង្កើតផ្នែកប្រឆាំងភេរវកម្មនៅតាមបញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានី ខេត្ត ដែលចំណុះការិយាល័យព័ត៌មាន និងសន្តិសុខ ឲ្យបានគ្រប់រាជធានី ខេត្ត។

-គួរធ្វើការកែសម្រួលផ្នែកប្រឆាំងគ្រឿងញៀន ឲ្យទៅជាការិយាល័យប្រឆាំងគ្រឿងញៀន នៅបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស និងបង្កើតផ្នែកប្រឆាំងគ្រឿងញៀននៅតាមបណ្តាបញ្ជាការដ្ឋាន កងរាជអាវុធហត្ថរាជធានី ខេត្ត ដែលចំណុះការិយាល័យស្រាវជ្រាវឲ្យបានគ្រប់រាជធានី-ខេត្ត។

-ការតែងតាំងមុខងារ ឬតម្លើងឋានន្តរសក្តិដល់បុគ្គលិក ដោយផ្អែកលើគោលការណ៍ច្បាស់លាស់ដូចជាឲ្យស្របតាមសញ្ញាបត្រនៃចំណេះវិជ្ជា តាមជំនាញ ទេពកោសល្យ ចិរៈវេលាកំណត់ស្នាដៃក្នុងការបំពេញមុខងារ សីលធម៌ និង តាមការគោរពវិន័យរបស់បុគ្គលិកម្នាក់ៗ។

-ធ្វើការដោះស្រាយគោលនយោបាយជាសម្ភារៈ ថវិកាដល់បុគ្គលិកជួប ការលំបាក ឬមានគ្រោះថ្នាក់ដោយប្រការផ្សេងៗ។

-ជំរុញការស្រង់បញ្ជីឈ្មោះនាយអាវុធហត្ថទាំងអស់ ដែលបានឆ្លងវគ្គបណ្តុះបណ្តាលជាមន្ត្រីនគរបាលយុត្តិធម៌ ដើម្បីស្នើសុំផ្តល់នីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌ។

-គួរលើកសំណើផ្តល់កិត្តិយសជាមន្ត្រីនគរបាលយុត្តិធម៌ដល់មេបញ្ជាការ និងមេបញ្ជាការរង និង អង្គភាពដែលទទួលបានបន្ទុកការងារយុត្តិធម៌មាននីតិសម្បទានជាមន្ត្រីនគរបាលយុត្តិធម៌។

-គួរលើកសំណើរជូនក្រសួងយុត្តិធម៌ ដើម្បីសុំការទទួលស្គាល់ដោយស្របច្បាប់ជូនកងរាជអាវុធហត្ថ ឲ្យមាននីតិសម្បទាផ្នែកកោសល្យវិច័យលើស្លាកស្នាមក្រយៅដៃ និង វត្ថុតាងផ្សេងៗទៀត។

-ជំរុញបង្កើនការផ្សព្វផ្សាយ និងការបំប៉នឲ្យបានស៊ីជំរៅស្តីពីនិតិវិធីព្រហ្មទណ្ឌដល់កងរាជអាវុធហត្ថ ដែលជាមន្ត្រីនគរបាលយុត្តិធម៌ និងអាវុធហត្ថទូទាំងក្នុងស្ថាប័នកងរាជអាវុធហត្ថទាំងមូលឲ្យបានទូលំទូលាយ៕

# ឯកសារយោង


១.រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។

២.ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

៣.ព្រះរាជក្រឹត្យលេខ ៥៤៦NS និង ៥៤៧NS ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៥៧ ស្តីពីការបង្កើតកងរាជអាវុធហត្ថ។

៤.ច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧។

៥.អនុក្រឹត្យលេខ ១៣៦. អនក្រ.ប.ក ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ ២០០៩ ស្តីពីការបង្កើតស្នងការដ្ឋានដាក់ចំណុះបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស។

៦.អនុក្រឹត្យលេខ ៧៧ អនក្រ. ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ ១៩៩៤ ស្តីពីភារកិច្ច និង រចនាសម្ព័ន្ធទូទៅរបស់កងរាជអាវុធហត្ថ។

៧.អនុក្រឹត្យលេខ ៥៧៤/៧១CE ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៧១ ស្តីពីការបង្កើតកងរាជអាវុធហត្ថ។

៨.អនុក្រឹត្យលេខ ២៥ អ.ន.ក្រ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩៤ ស្តីពីការបង្កើតកងឯកភាពកងរាជអាវុធហត្ថ។

៩.ប្រកាសលេខ ០២៧/០១០ ស.ក.ណ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១០ ស្តីពីសេចក្តីកំណត់តួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងបញ្ជាការដ្ឋានកងរាជអាវុធហត្ថ។

១០.រចនាសម្ព័ន្ធចាត់តាំងបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស។

១១.បញ្ជាផ្ទៃក្នុងបញ្ជាការដ្ឋានកងរាជអាវុធហត្ថផ្ទៃប្រទេស ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៩។

១២.វចនានុក្រមខ្មែរ ការផ្សាយរបស់ពុទ្ធសាសនាបណ្ឌិត្យ ព.ស២៥១២ គ.ស ១៩៦៧-១៩៦៨។

១៣.ក្រឹត្យចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ១៩៩៣ ស្តីពីការចាត់តាំងរចនាសម្ព័ន្ធរបស់ក្រសួងការពារជាតិ និងអគ្គសេនាធិការ។

១៤.អនុក្រឹត្យលេខ០៩អនក្រ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ ១៩៩៤ ស្តីពីការបង្កើតសេនាធិការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តកំពង់ចាម និង ក្រុងព្រះសីហនុ។

១៥.អនុក្រឹត្យលេខ៥៦អនក្រ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៤ ស្តីពីការបង្កើតសេនាធិការដ្ឋានកងរាជអាវុធហត្ថខេត្តស្វាយរៀង ខេត្តព្រៃវែង ខេត្តកណ្តាល ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ស្ពឺ និងខេត្តស្ទឹងត្រែង។

១៦.អនុក្រឹត្យលេខ៥៤អនក្រ.បក ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ១៩៩៥ ស្ដីពីការបង្កើតបញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តមណ្ឌលគិរី ខេត្តរតនគិរី ខេត្តព្រះវិហារ ខេត្តឧត្តរមានជ័យ។

១៧.អនុក្រឹត្យលេខ០៨អនក្រ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៩៥ ស្ដីពីការបង្កើតបញ្ជាការដ្ឋាន កងរាជអាវុធហត្ថខេត្តក្រចេះ ខេត្តកំពង់ធំ ខេត្តតាកែវ ខេត្តពោធិ៍សាត់ ខេត្តកំពត ខេត្តកោះកុង និងក្រុងកែប។

១៨.អនុក្រឹត្យលេខ១៥៩អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៤ ស្ដីពីការកែសម្រួលរៀបចំឡើងវិញ រចនាសម្ព័ន្ធក្របខ័ណ្ឌចាត់តាំងបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស។

១៩.សេចក្ដីណែនាំ លេខ ៦៣/០៧ របក ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០០៧ ស្ដីពីផែនការហ្វឹកហ្វឺនរបស់កងយោធាពលខេមរភូមិន្ទ។

២០.សេចក្ដីកំណត់ លេខ០២/០១ ហាកណ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០០១ ស្ដីពីការកំណត់តួនាទីភារកិច្ច និងរចនាសម្ព័ន្ធរបស់ការិយាល័យ ផ្នែក ចំណុះបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស។

# ឧបសម្ព័ន្ធ

## តារាងឧសម្ព័ន្ធ

ក. ក្រឹត្យ ពីការចាត់តាំងរចនាសម្ព័ន្ធរបស់ក្រសួងការពារជាតិ និងអគ្គសេនាធិការ

ខ. អនុក្រឹត្យលេខ២៥ អ.ន.ក្រ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩៤ ស្តីពីភារកិច្ច និង រចនាសម្ព័ន្ធទូទៅរបស់កងរាជអាវុធហត្ថ

គ. អនុក្រឹត្យលេខ៧៧ អនក្រ. ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ ១៩៩៤ ស្តីពីភារកិច្ច និង រចនាសម្ព័ន្ធទូទៅរបស់កងរាជអាវុធហត្ថ

ឃ. អនុក្រឹត្យលេខ១៣៦. អនក្រ.ប.ក ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ ២០០៩ ស្តីពីការបង្កើតស្នងការដ្ឋានដាក់ចំណុះបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

ង. អនុក្រឹត្យលេខ១៥៩ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលរៀបចំឡើងវិញរចនាសម្ព័ន្ធក្របខ័ណ្ឌចាត់តាំងបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

ច. រចនាសម្ព័ន្ធចាត់តាំងបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

ឆ. បទបញ្ជាផ្ទៃក្នុងនៃកងរាជអាវុធហត្ថ

ជ. នីតិវិធីក្នុងការធ្វើសម្បថ និងពាក្យសច្ចាប្រណិធាន

# ក្រឹត្យ ស្តីពីការចាត់តាំង
# រចនាសម្ព័ន្ធរបស់
# ក្រសួងការពារជាតិ និង
# អគ្គសេនាធិការ

# ក្រឹត្យ

យើង

សម្ដេចព្រះឧបយុវរាជ

នរោត្តម សីហនុ

ប្រមុខរដ្ឋ នៃ កម្ពុជា

និង ជាឧត្តមមេបញ្ជាការ នៃ កងទ័ពជាតិ កម្ពុជា

យោងតាម លិខិតស្នើសុំរបស់សហប្រធាន នៃ រដ្ឋាភិបាលជាតិបណ្ដោះអាសន្ន កម្ពុជា ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ១៩៩៣ ស្ដីអំពីការចាត់តាំងរចនាសម្ព័ន្ធរបស់ក្រសួង ការពារជាតិ និង អគ្គសេនាធិការ ។

បង្គាប់

មាត្រា១: ត្រូវបានបង្កើតអគ្គសេនាធិការដ្ឋាន នៃ កងទ័ពជាតិកម្ពុជា ជាស្ថាប័នមួយ ដែលស្ថិតនៅក្រោមកិច្ចដឹកនាំ និង បញ្ជាការរបស់ សមូហអគ្គមេបញ្ជាការ និង មានភារកិច្ចដូចខាងក្រោម ÷

- អនុវត្តស្របតាមនយោបាយរបស់រដ្ឋាភិបាល ក្នុងវិស័យកងទ័ពជាតិ
- បញ្ជា ដឹកនាំ គ្រប់គ្រង កងទ័ពគ្រប់ប្រភេទ ដើម្បីធានាការប្រយុទ្ធ
- បណ្ដុះបណ្ដាលមុខជំនាញយោធា ជូននាយទាហាន និង ពលទាហាន ក្នុងវិស័យកងទ័ពជាតិ ។
- សហការជាមួយកងកម្លាំងសន្តិសុខ ដើម្បីការពារសន្តិសុខ និង សណ្ដាប់ធ្នាប់សង្គម ។

មាត្រា២: រចនាសម្ព័ន្ធចាត់តាំងអគ្គលេខាធិការដ្ឋាន ជារួមមាន ៖

- នាយអគ្គលេខាធិការដ្ឋាន
- នាយអគ្គលេខាធិការដ្ឋានរង ទី១
- បណ្តានាយអគ្គលេខាធិការដ្ឋានរង
- អធិការដ្ឋាន
- ខុទ្ទកាល័យ
- បញ្ជាការដ្ឋានវរជាល នៃ អគ្គលេខាធិការដ្ឋាន
- ការិយាល័យទី១
- ការិយាល័យទី២
- ការិយាល័យទី៣
- ការិយាល័យទី៤
- ការិយាល័យទី៥
- ក្រុមផែនការ
- ក្រុមសុខាភិបាល
- ក្រុមដឹកជញ្ជូន
- ក្រុមវិស្វកម្ម
- ក្រុមបញ្ជូនសារ
- ក្រុមឃ្លាំងសំភារៈ
- ក្រុមហិរញ្ញវត្ថុ
- ក្រុមបច្ចេកទេស
- ក្រុមស្រាវជ្រាវ
- កងអន្តរាគមន៍
- កងការពារព្រំដែន
- កងច័ក្រពិសេស
- កងកាំភ្លើងធំ
- កងវរសេនាធំ
- កងអាវុធហត្ថ
- សាលាហ្វឹកហ្វឺន សំរាប់នាយទាហាន នាយទាហានរង
  ពលទាហាន និង សាលាបច្ចេកទេស

- ទីបញ្ជាការកងទ័ពជើងទឹកជាតិ កម្ពុជា
- ទីបញ្ជាការកងទ័ពអាកាសជាតិ កម្ពុជា (ការការពារដែនអាកាស)
- បណ្ដាកងយោធភូមិភាគ

មាត្រា៣: ប្រគល់ជូនអគ្គលេខាធិការដ្ឋាន នូវ ភារកិច្ច កំណត់ពេលវេលា និង ទីតាំង ជាក់ស្ដែង ក្នុងការរៀបចំបណ្ដាស្ថាប័នខាងលើ ។

មាត្រា៤: សហប្រធាន នៃ រដ្ឋាភិបាលជាតិបណ្ដោះអាសន្ន កម្ពុជា ត្រូវទទួលបន្ទុកអនុវត្តក្រឹត្យនេះ ។

មាត្រា៥: ក្រឹត្យនេះ ចូលជាធរមាន ចាប់ពីពេលឡាយព្រះហស្ថលេខានេះ តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ១៩៩៣

នរោត្តម សីហនុ

# អនុក្រឹត្យលេខ២៥
# ស្តីពីភារកិច្ច និង
# រចនាសម្ព័ន្ធទូទៅនៃ
# កងរាជអាវុធហត្ថ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាល

លេខ : ២៥ អនក្រ

# អនុក្រឹត្យ

ស្តីពី

## ភារកិច្ច និង រចនាសម្ព័ន្ធទូទៅនៃកងរាជអាវុធហត្ថ

## រាជរដ្ឋាភិបាល

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញក្រឹត្យចុះថ្ងៃទី ២ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងសហអគ្គមេបញ្ជាការ នៃកងកម្លាំងប្រដាប់អាវុធជាតិកម្ពុជា
- បានឃើញក្រឹត្យចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញក្រឹត្យ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតអគ្គសេនាធិការដ្ឋាន នៃកងទ័ពជាតិកម្ពុជា
- បានឃើញយោបល់របស់ទីប្រឹក្សាខាងកិច្ចការពារជាតិ និងក្រុមប្រឹក្សាអ្នកច្បាប់អមនាយករដ្ឋមន្ត្រី

## សំរេច

**មាត្រា ១** : កងរាជអាវុធហត្ថដែល ឋិតនៅក្រោមការគ្រប់គ្រងរបស់អគ្គសេនាធិការកងយោធពល ខេមរភូមិន្ទនោះ ត្រូវឋិតនៅក្រោមបញ្ជាផ្ទាល់របស់នាយករដ្ឋមន្ត្រី ។

**មាត្រា ២** : នាយករដ្ឋមន្ត្រី ជាអ្នកកំណត់ក្របខ័ណ្ឌសកម្មភាពទូទៅ ។

សហរដ្ឋមន្ត្រីក្រសួងការពារជាតិជាអ្នកទទួលខុសត្រូវលើផ្នែករដ្ឋបាលទូទៅ និង ជាអ្នកផ្តល់សម្ភារ

និង ថវិកាសំរាប់ផ្គត់ផ្គង់កងរាជអាវុធហត្ថ តាមរយៈអគ្គសេនាធិការកងយោធពលខេមរភូមិន្ទ។

**មាត្រា ៣** : កងរាជអាវុធហត្ថ ជាផ្នែកមួយរបស់កងយោធពលខេមរភូមិន្ទ ដែលមានស្វ័យភាពក្នុងកិច្ចអនុវត្តច្បាប់ ។ កងរាជអាវុធហត្ថមានសកម្មភាពផ្នែកប៉ូលិសដែលមានឧបនិស្ស័យ ជាអន្តរក្រសួង ។ សមត្ថកិច្ចកងរាជអាវុធហត្ថ ត្រូវអនុវត្តពេញផ្ទៃប្រទេសទាំងមូលទៅលើពលរដ្ឋស៊ីវិលព្រមទាំងទៅលើយោធាក្នុងជួរកងទ័ពផង ។

**មាត្រា ៤** : កងរាជអាវុធហត្ថមានភារកិច្ច :

ក/ រ៉ាប់រងសកម្មភាពខាងប៉ូលិសរដ្ឋបាល :

- រក្សាសុវត្ថិភាព និង សណ្តាប់ធ្នាប់សាធារណៈទូទៅ
- រ៉ាប់រងអោយមានការគោរពច្បាប់ និង បទបញ្ជាទាំងឡាយ
- ផ្តល់ពត៌មាន និង ជួយសង្គ្រោះពលរដ្ឋស៊ីវិល ។

ក្នុងករណី នៃការអនុវត្តន៍ភារកិច្ចនេះកងរាជអាវុធហត្ថ អាចនឹងទទួលបញ្ជា ពីសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អាជ្ញាធររដ្ឋបាលមានសមត្ថកិច្ច ។

ខ/ រ៉ាប់រងសកម្មភាពខាងប៉ូលិសតុលាការ :

- ពិនិត្យកត់ត្រានូវឧក្រិដ្ឋកម្ម និង ទោសកម្ម
- ធ្វើកំណត់ហេតុអំពីបទល្មើស
- ប្រមូលផ្តុំភ័ស្តុតាងផ្សេងៗ
- ស្រាវជ្រាវរាវរកអ្នកប្រព្រឹត្តបទល្មើស ដើម្បីបញ្ជូនខ្លួនទៅតុលាការ តាមដីកាតុលាការ
- ទទួលបន្ទុកអនុវត្ត តាមដីកាផ្ទេរអំណាចពីចៅក្រមស៊ើបសួរ ។

ក្នុងករណីអនុវត្តភារកិច្ចនេះ កងរាជអាវុធហត្ថអាចនឹងទទួលបទបញ្ជាពីរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ អគ្គការអយ្យការ និង អាជ្ញាធរ តុលាការមានសមត្ថកិច្ច ។

គ/ បំពេញបេសកម្មដែលមានលក្ខណៈពិសេសខាងយោធា :

- ទទួលបន្ទុករក្សាសុវត្ថិភាព និង បំពេញតួនាទីជាកងកិត្តិយសជាប្រយោជន៍ដល់ស្ថាប័នរាជរដ្ឋាភិបាល និង អាជ្ញាធរជាន់ខ្ពស់ នៃព្រះរាជាណាចក្រកម្ពុជា

- ការពារទីតាំងយោធា

- កិច្ចការប៉ូលីសយោធានៅក្នុង ឬ ក្រៅទីតាំងកងទ័ព ។

ក្នុងករណីអនុវត្តភារកិច្ចនេះ កងរាជអាវុធហត្ថអាចនឹងទទួលបញ្ជា ពីសហរដ្ឋមន្ត្រីក្រសួងការពារជាតិ នាយអគ្គសេនាធិការកងយោធពលខេមរភូមិន្ទ និង អាជ្ញាធរយោធា មានសមត្ថកិច្ច ។ ឃ/ ផ្តល់កំលាំងទៅជួយក្រសួងនានា ដែលបានស្នើសុំតាមសេចក្តីត្រូវការផាំចាំបាច់ ។

**មាត្រា ៥** : កងរាជអាវុធហត្ថអាចនឹងទទួលបេសកកម្មផ្នែកប៉ូលីស ពិសេសបន្ថែមដោយអនុលោមតាមអនុក្រឹត្យក្នុងបច្ចាកាល ។

**មាត្រា ៦** : រចនាសម្ព័ន្ធទូទៅរបស់កងរាជអាវុធហត្ថមាន :

- អធិការដ្ឋានកងរាជអាវុធហត្ថ

- នាយកដ្ឋានកងរាជអាវុធហត្ថ

**មាត្រា ៧ : អធិការដ្ឋានកងរាជអាវុធហត្ថ**

អធិការកងរាជអាវុធហត្ថមានភារកិច្ចបំពេញបេសកកម្មត្រួតពិនិត្យ សិក្សា និង ផ្តល់ពត៌មាន ។

អធិការកងរាជអាវុធហត្ថត្រូវឋិតនៅក្រោមបញ្ជានាយករដ្ឋមន្ត្រីផ្ទាល់ដែលជាអ្នកកំណត់បេសកកម្ម ។

អធិការកងរាជអាវុធហត្ថជាទីប្រឹក្សាអចិន្ត្រៃយ៍របស់នាយករដ្ឋមន្ត្រី ។ ក្នុងករណីនេះ អធិការកងរាជអាវុធហត្ថ ត្រូវផ្តល់យោបល់ដល់នាយករដ្ឋមន្ត្រី នូវគ្រប់គំរោង ស្តីពីអនាគតផ្នែករចនាសម្ព័ន្ធ និង មុខងាររបស់កងរាជអាវុធហត្ថ ។ អធិការកង រាជអាវុធហត្ថតោងតែតាម ពិនិត្យមើលដោយផ្ទាល់ នូវកិច្ចប្រតិបត្តិការងារ និង ការប្រើប្រាស់បុគ្គលិកកងរាជអាវុធហត្ថ អោយសមស្របតាម ក្បួនច្បាប់ ។

**មាត្រា ៨ : នាយកដ្ឋានកងរាជអាវុធហត្ថ**

នាយកដ្ឋានកងរាជអាវុធហត្ថ ដឹកនាំដោយនាយកមួយរូប អាចជានាយទាហានថ្នាក់ឧត្តម

សេនីយ៍ ឬ បុគ្គលិក ស៊ីវិលជាន់ខ្ពស់ មានភារកិច្ច ៖

- ចងក្រងបទបញ្ញត្តិការងារទូទៅ និង តាមពិនិត្យការអនុវត្តដោយមានទំនាក់ទំនងជាមួយក្រសួងពាក់ព័ន្ធដូចជាក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ជាដើម

- ផ្តល់ពត៌មានដល់នាយករដ្ឋមន្ត្រី អំពីមធ្យោបាយគ្រប់យ៉ាង ដែលមានភាពចាំបាច់ការងារបាន

- ដោះស្រាយកែសំរួលចំពោះបញ្ហាទាក់ទងក្នុងការរៀបចំផ្នែករដ្ឋបាល និង ដំណើរការប្រព្រឹត្តិទៅ របស់កងរាជអាវុធហត្ថ ។

ឋិតនៅក្រោមបញ្ជារបស់ នាយកកងរាជអាវុធហត្ថ មាន ៖

- សាលាហ្វឹកហ្វឺនកងរាជអាវុធហត្ថ

- កងរាជអាវុធហត្ថផ្ទៃប្រទេស

- កងរាជអាវុធហត្ថចល័ត

- តម្រួតយោធា

**ម.២.៩ ៖ សាលាហ្វឹកហ្វឺនកងរាជអាវុធហត្ថ**

សាលាហ្វឹកហ្វឺនកងរាជអាវុធហត្ថ ត្រូវទទួលបន្ទុក ៖

- រៀបចំកម្មវិធីបង្រៀន

- ហ្វឹកហ្វឺនបុគ្គលិក

- ត្រួតពិនិត្យការហ្វឹកហ្វឺន

- រៀបរៀង និង ចងក្រងឯកសារសម្រាប់បង្រៀន

- ធ្វើសំណើទៅនាយកដ្ឋានកងរាជអាវុធហត្ថ នូវសម្ភារៈជាចាំបាច់សំរាប់ដំណើរការសិក្សាអោយមានប្រសិទ្ធភាព ។

**មាត្រា ១០ : កងរាជអាវុធហត្ថផ្ទៃប្រទេស :**

កងរាជអាវុធហត្ថផ្ទៃប្រទេស ដែលដាក់អោយអនុវត្តការងារនៅពេញផ្ទៃ ព្រះរាជាណាចក្រកម្ពុជា រហូតទៅដល់ថ្នាក់ ឃុំ ត្រូវទទួលបន្ទុកបំពេញបេសកកម្មរបស់កងរាជអាវុធហត្ថដែលមានចែងនៅ ក្នុង មាត្រា ៤ នៃអនុក្រឹត្យនេះ ។

សមត្ថកិច្ច នៃកងរាជអាវុធហត្ថផ្ទៃប្រទេសអនុវត្តទៅលើពលរដ្ឋស៊ីវិល និង យោធា ។

**មាត្រា ១១ : កងរាជអាវុធហត្ថចល័ត**

កងរាជអាវុធហត្ថចល័ត ជាកងកម្លាំងសម្រាប់ការពារ អោយមានសណ្តាប់ធ្នាប់ និង ប្រយុទ្ធប្រឆាំង នឹងក្រុមប្រដាប់អាវុធខុសច្បាប់ ។ កងរាជអាវុធហត្ថចល័តអនុវត្តការងារពេញ ផ្ទៃប្រទេសតាមការសុំ ពីកងរាជអាវុធ ហត្ថផ្ទៃប្រទេស ឬ តាមសំបុត្រកំណែនពីអាជ្ញាធរមានសមត្ថកិច្ច ផ្នែករដ្ឋបាល ឬ តុលាការ ។ កងរាជអាវុធហត្ថចល័តត្រូវត្រៀមខ្លួនជានិច្ចសំរាប់ បន្ថែមកម្លាំងក្នុងពេលខ្លីបំផុតទៅ ជួយកងឯកភាពនៃកង រាជអាវុធហត្ថផ្ទៃប្រទេស ។

**មាត្រា ១២ : តម្រួតយោធា**

តម្រួតយោធា គឺ ជាកងកម្លាំងមួយនៃកងរាជអាវុធហត្ថ ដែលមានភារកិច្ចចុះទៅធ្វើការផ្ទាល់ជាមួយ និង កងទ័ពទាំង ៣ ប្រភេទ នៃកងយោធពលខេមរភូមិន្ទ ។ តម្រួតយោធាបំពេញបេសកកម្មនេះ ក្រោមបញ្ជាអាជ្ញាធរដូចមានចែងក្នុងវគ្គ « គ » នៃមាត្រា ៤ នៃអនុក្រឹត្យនេះ ។

**មាត្រា ១៣** :អធិការ ឬ នាយកកងរាជអាវុធហត្ថអាចស្នើបង្កើតនូវអង្គភាពឯកទេសផ្សេង ៗ ទៀត ដើម្បីប្រសិទ្ធភាពការងារក្នុងកាលៈទេសៈចាំបាច់ ។

**មាត្រា ១៤** :ប្រគល់ជូនសហរដ្ឋមន្ត្រីការពារជាតិ និង នាយអគ្គសេនាធិការកងយោធពលខេមរភូមិន្ទ នូវនាទីកំណត់ភារកិច្ច ចំនួនជាក់ស្តែងនិងការស្នើតែងតាំង ក្នុងការរៀបចំស្ថាប័នដែលមានចែងខាងលើ ដោយមានការពិគ្រោះយោបល់ជា មួយសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ១៥** - បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយអំពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករ។

**មាត្រា ១៦** - សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ នាយអគ្គសេនាធិការកងយោធពលខេមរភូមិន្ទ និងគ្រប់ក្រសួងពាក់ពន្ធ័ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ដែលចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និងចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ១៩៩៤

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

**នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**

<u>ចំលងជូន</u> :

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋាននៃរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី១
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី ២
- ដូចមាត្រា ១៦ « ដើម្បីអនុវត្ត »
- កាលប្បវត្តិ- ឯកសារ

# អនុក្រឹត្យលេខ៧៧
# ស្ដីពីភារកិច្ច និង
# រចនាសម្ព័ន្ធទូទៅរបស់
# កងរាជអាវុធហត្ថ

wednesday 04 Jan, 95

POLROTH

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាល

លេខ: ៧៧ អនក្រ

[illegible] 27-12-94

1069 ម៉ោង 3,00

# អនុក្រឹត្យ

ស្តីពី

ភារកិច្ច និង រចនាសម្ព័ន្ធទូទៅនៃកងរាជអាវុធហត្ថ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០២ កក្កដា ១៩៩៣ ស្តីពីការតែងតាំងសមាសភាពអគ្គមេបញ្ជាការនៃកងកម្លាំងប្រដាប់អាវុធជាតិកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតក្រសួងការពារជាតិ និង អគ្គសេនាធិការ នៃ កងទ័ពជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២៨ អនក្រ ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ១៩៩៤ ស្តីពីភារកិច្ចនិងរចនាសម្ព័ន្ធទូទៅនៃកងរាជអាវុធហត្ថ
- បានឃើញយោបល់របស់ទីប្រឹក្សាខាងកិច្ចការពារជាតិនិងក្រុមប្រឹក្សាអ្នកច្បាប់របស់នាយករដ្ឋមន្ត្រី

សំរេច

មាត្រា ១: កងរាជអាវុធហត្ថដែលគ្រប់គ្រងដោយអគ្គសេនាធិការ កងយោធពលខេមរភូមិន្ទនោះ ត្រូវឋិតនៅក្រោមបញ្ជាផ្ទាល់របស់នាយករដ្ឋមន្ត្រី។

មាត្រា ២: នាយករដ្ឋមន្ត្រីជាអ្នកកំណត់ក្របខ័ណ្ឌសកម្មភាពទូទៅ។ សហរដ្ឋមន្ត្រីក្រសួងការពារជាតិជាអ្នក [illegible] ត្រួតពិនិត្យការរដ្ឋបាលទូទៅ និង ជាអ្នកផ្តល់សំភារៈ និង ថវិកាសំរាប់ផ្គត់ផ្គង់កងរាជអាវុធហត្ថ [illegible] អគ្គសេនាធិការកងយោធពលខេមរភូមិន្ទមានភារៈគ្រប់គ្រងសំដៅហ្វឹកហ្វឺនកសាងរៀបចំ [illegible] ឱ្យរីកចំរើន ដើម្បីមានសមត្ថភាពគ្រប់គ្រាន់ក្នុងការរ៉ាប់រងតួនាទី និង

មាត្រា ៣: កងរាជអាវុធហត្ថជាផ្នែកមួយរបស់កងយោធពលខេមរភូមិន្ទ ដែលមានស្វ័យភាពក្នុងកិច្ចអនុវត្ត

ច្បាប់ កងរាជអាវុធហត្ថមានសកម្មភាពផ្នែកប៉ូលិសដែលមានឧបនិស្ស័យជាអន្តរក្រសួង ។ សមត្ថកិច្ចកងរាជអាវុធហត្ថត្រូវអនុវត្តពេញផ្ទៃប្រទេសទាំងមូល ទៅលើពលរដ្ឋស៊ីវិល ព្រមទាំងទៅលើយោធាក្នុងជួរកងទ័ពផង ។

មាត្រា ៤: កងរាជអាវុធហត្ថមានភារកិច្ច :

ក- ប្រតិបត្តិសកម្មភាពខាងប៉ូលិសរដ្ឋបាល:

- រក្សាសុវត្ថិភាព និង សណ្តាប់ធ្នាប់សាធារណៈ
- ធានាអោយមានការគោរពច្បាប់ និង បទបញ្ជាទាំងឡាយ
- ផ្តល់ព័ត៌មាន និង ជួយសង្គ្រោះពលរដ្ឋស៊ីវិល

ក្នុងក្របខ័ណ្ឌនៃភារកិច្ចនេះ កងរាជអាវុធហត្ថអនុវត្តតាមបញ្ជារបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អាជ្ញាធររដ្ឋបាលមានសមត្ថកិច្ច ។

ខ- ប្រតិបត្តិសកម្មភាពខាងប៉ូលិសតុលាការ:

- ពិនិត្យកត់ត្រានូវឧក្រិដ្ឋកម្ម និង បទល្មើស
- ធ្វើកំណត់ហេតុអំពីបទល្មើស
- ប្រមូលផ្តុំភស្តុតាងផ្សេង ៗ
- ស្រាវជ្រាវរាវរកអ្នកប្រព្រឹត្តិបទល្មើស ដើម្បីបញ្ជូនខ្លួនទៅតុលាការតាមដីកាតុលាការ
- ទទួលបន្ទុកអនុវត្តតាមដីកាផ្ទេរអំណាចពីចៅក្រមស៊ើបសួរ

ក្នុងក្របខ័ណ្ឌនៃភារកិច្ចនេះ កងរាជអាវុធហត្ថអនុវត្តតាមបញ្ជារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អង្គការអយ្យការ និង អាជ្ញាធរតុលាការមានសមត្ថកិច្ច ។

គ- បំពេញបេសកកម្មដែលមានលក្ខណៈពិសេសខាងយោធា:

- ទទួលបន្ទុករក្សាសុវត្ថិភាព និង បំពេញតួនាទីជាកងកិត្តិយសជាប្រយោជន៍ដល់ស្ថាប័នរាជរដ្ឋាភិបាល និង អាជ្ញាធរជាន់ខ្ពស់នៃព្រះរាជាណាចក្រកម្ពុជា ។
- ការពារទីតាំងយោធា
- កិច្ចការប៉ូលិសយោធានៅក្នុង និង ក្រៅទីតាំងកងទ័ព

ក្នុងក្របខ័ណ្ឌនៃភារកិច្ចនេះ កងរាជអាវុធហត្ថអនុវត្តតាមបញ្ជារបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ នាយកសេនាធិការកងយោធពលខេមរភូមិន្ទ និង អាជ្ញាធរយោធាមានសមត្ថកិច្ច ។

ឃ- ផ្តល់កំលាំងទៅជួយក្រសួងនានា ដែលបានស្នើសុំតាមសេចក្តីត្រូវការជាចាំបាច់ ។

មាត្រា ៥: កងរាជអាវុធហត្ថអាចនឹងទទួលបេសកកម្មផ្នែកប៉ូលិស ពិសេសបន្ថែមដោយអនុលោមតាម

អនុក្រឹត្យក្នុងបច្ឆាកាល ។

មាត្រា ៦: រចនាសម្ព័ន្ធទូទៅរបស់កងរាជអាវុធហត្ថមាន ៖

- អធិការដ្ឋានកងរាជអាវុធហត្ថទទួលខុសត្រូវដោយអធិការមួយរូប និង អធិការរងមួយរូប ។
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថទទួលខុសត្រូវដោយមេបញ្ជាការមួយរូប និងមេបញ្ជាការរងមួយរូប

មាត្រា ៧: អធិការដ្ឋានកងរាជអាវុធហត្ថ

អធិការ និង អធិការរងកងរាជអាវុធហត្ថមានភារកិច្ចបំពេញបេសកកម្មត្រួតពិនិត្យ សិក្សា និង ផ្តល់គតិ មាន ។

អធិការ និង អធិការរងកងរាជអាវុធហត្ថត្រូវស្ថិតនៅក្រោមបញ្ជានាយករដ្ឋមន្ត្រីផ្ទាល់ ដែលជាអ្នកកំណត់បេសកកម្ម ។

អធិការ និង អធិការរងកងរាជអាវុធហត្ថជាទីប្រឹក្សាពិសេសរបស់នាយករដ្ឋមន្ត្រី ។ ក្នុងករណីនេះ អធិការកងរាជអាវុធហត្ថ ត្រូវផ្តល់យោបល់ដល់នាយករដ្ឋមន្ត្រី នូវ ការងារស្តីពីអនាគតផ្នែករចនា សម្ព័ន្ធ និង អង្គការរបស់កងរាជអាវុធហត្ថ ។ អធិការកងរាជអាវុធហត្ថ តែងតែតាមពិនិត្យមើល ដោយផ្ទាល់នូវកិច្ចប្រតិបត្តិ ការងារ និង ការប្រើប្រាស់បុគ្គលិកកងរាជអាវុធហត្ថអោយសមស្រប តាមច្បាប់ ។

មាត្រា ៨: បញ្ជាការដ្ឋានកងរាជអាវុធហត្ថ

បញ្ជាការដ្ឋានកងរាជអាវុធហត្ថ ដឹកនាំដោយមេបញ្ជាការថ្នាក់ឧត្តមសេនីយ៍ និងមេបញ្ជាការរងមួយរូបមានភារកិច្ច ៖

- ចងក្រងបទបញ្ញត្តិការងារទូទៅ និងតាមពិនិត្យការអនុវត្តដោយមានទំនាក់ទំនងជាមួយក្រសួងពាក់ព័ន្ធជា ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ និង ក្រសួងយុត្តិធម៌ ។
- ផ្តល់ព័ត៌មានដល់នាយករដ្ឋមន្ត្រី អំពីមធ្យោបាយគ្រប់បែបយ៉ាងដែលមានភាពបំពេញការងារបាន ។
- [illegible]ស្រាយដែលសំរួលចំពោះបញ្ហាទាក់ទងក្នុងការរៀបចំផ្នែករដ្ឋបាល និង ដំណើរការប្រព្រឹត្តទៅរបស់កងរាជអាវុធហត្ថ ។

[illegible]ស្ថិតនៅក្រោមបញ្ជារបស់មេបញ្ជាការ និង មេបញ្ជាការរងកងរាជអាវុធហត្ថមាន ៖

- [illegible]កងរាជអាវុធហត្ថ

- កងរាជអាវុធហត្ថផ្ទៃប្រទេស
- កងរាជអាវុធហត្ថចល័ត
- ឆត្រយោធា

មាត្រា ៩: សាលាហ្វឹកហ្វឺនកងរាជអាវុធហត្ថ :

សាលាហ្វឹកហ្វឺនកងរាជអាវុធហត្ថត្រូវទទួលបន្ទុក ÷

- រៀបចំកម្មវិធីបង្រៀន
- ហ្វឹកហ្វឺនបុគ្គលិក
- ត្រួតពិនិត្យការហ្វឹកហ្វឺន
- រៀបរៀង និង ចងក្រងឯកសារសំរាប់បង្រៀន
- ធ្វើសំណើទៅបញ្ជាការដ្ឋានកងរាជអាវុធហត្ថ នូវ សំភារៈចាំបាច់សំរាប់ដំណើរការសិក្សាអោយមានប្រសិទ្ធភាព ។

មាត្រា១០: កងរាជអាវុធហត្ថផ្ទៃប្រទេស :

កងរាជអាវុធហត្ថផ្ទៃប្រទេស ដែលដាក់អោយអនុវត្តការងារនៅពេញផ្ទៃព្រះរាជាណាចក្រកម្ពុជា រហូតទៅដល់ថ្នាក់ឃុំ ត្រូវទទួលបន្ទុកបំពេញបេសកកម្មរបស់កងរាជអាវុធហត្ថដែលមានចែងក្នុងមាត្រា ៤ នៃ អនុក្រឹត្យនេះ ។

សមត្ថកិច្ចនៃកងរាជអាវុធហត្ថផ្ទៃប្រទេសអនុវត្តទៅលើពលរដ្ឋស៊ីវិល និង យោធា ។

មាត្រា១១: កងរាជអាវុធហត្ថចល័ត :

កងរាជអាវុធហត្ថចល័ត ជាកងកំលាំងសំរាប់ធានាអោយមានសណ្តាប់ធ្នាប់ និង ប្រយុទ្ធ ប្រឆាំងនឹងក្រុមប្រដាប់អាវុធខុសច្បាប់ ។ កងរាជអាវុធហត្ថចល័តអនុវត្តការងារពេញផ្ទៃប្រទេសតាមការស្នើសុំពីកងរាជអាវុធហត្ថផ្ទៃប្រទេស ឬ តាមសំបុត្រកំណែនពីអាជ្ញាធរមានសមត្ថកិច្ចផ្នែករដ្ឋបាល ឬ តុលាការ ។ កងរាជអាវុធហត្ថចល័តត្រូវត្រៀមខ្លួនជានិច្ចសំរាប់ចេញកំលាំងក្នុងពេលខ្លីបំផុតទៅជួយកងឯកភាពនៃកងរាជអាវុធហត្ថផ្ទៃប្រទេស ។

មាត្រា១២: ឆត្រយោធា :

ឆត្រយោធា គឺជាកងកំលាំងមួយនៃកងរាជអាវុធហត្ថ ដែលមានភារកិច្ចចុះបោះ [illegible] ការផ្គាប់ជាមួយនឹងកងទ័ពទាំងបីប្រភេទ នៃ កងយោធពលខេមរភូមិន្ទ ។ ឆត្រយោធាបំពេញបេសកកម្ម [illegible] ដូចមានចែងក្នុងវគ្គ « គ » នៃមាត្រា ៤ នៃអនុក្រឹត្យនេះ ។

មាត្រា១៣: អធិការ ឬ មេបញ្ជាការកងរាជអាវុធហត្ថអាចស្នើបង្កើត នូវអង្គភាពឯកទេសផ្សេង ៗទៀតដើម្បី

ប្រសិទ្ធភាពការងារក្នុងកាលៈទេសៈចាំបាច់ ។

មាត្រា១៤: នាយករដ្ឋមន្ត្រីសម្រេចកំណត់ភារកិច្ចចំនួនជាក់ស្តែង និង ការតែងតាំងក្នុងការរៀបចំស្ថាប័ន លើសំណើពីមេបញ្ជាការ និង អធិការកងរាជអាវុធហត្ថដែលបានពិភាក្សាឬ យោបល់ជាមួយ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អគ្គសេនាធិការកងយោធពលខេមរភូមិន្ទ ។

មាត្រា១៥: អនុក្រឹត្យលេខ ២៥ អនក្រ ចុះថ្ងៃទី ១៥ មិថុនា ១៩៩៤ ព្រមទាំងបទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា១៦: សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ នាយអគ្គសេនាធិការកងយោធពលខេមរភូមិន្ទ និង គ្រប់ក្រសួងពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ដែលចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែ... ឆ្នាំ ១៩៩៤

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

នរោត្តម រណឫទ្ធិ ហ៊ុន សែន

កន្លែងផ្ញើ:

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី ១
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី ២
- ដូចមាត្រា ១៦ « ដើម្បីអនុវត្ត »
- ឯកសារ - កាលប្បវត្តិ

# អនុក្រឹត្យលេខ១៣៦
# ស្តីពីការបង្កើត
# ស្នងការដ្ឋានដាក់ចំណុះ
# បញ្ជាការដ្ឋាន
# កងរាជអាវុធហត្ថ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...១៣២...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតស្នងការដ្ឋានដាក់ចំណុះបញ្ជាការដ្ឋាន

## កងរាជអាវុធហត្ថ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ស្តីពីភារកិច្ច និងរចនាសម្ព័ន្ធទូទៅនៃកងរាជអាវុធហត្ថ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

**ស ម្រេ ច**

មាត្រា ១ : ត្រូវបានបង្កើតស្នងការដ្ឋានចំនួន ០៥ ដាក់ចំណុះបញ្ជាការដ្ឋានកងរាជអាវុធហត្ថ ដូចខាងក្រោម :

១- ស្នងការដ្ឋានព័ត៌មាន និងសន្តិសុខ

២-ស្នងការដ្ឋានផែនការប្រតិបត្តិការ

៣-ស្នងការដ្ឋានស្រាវជ្រាវ និងយុត្តិធម៌

៤-ស្នងការដ្ឋានប្រភពកម្លាំង

៥-ស្នងការដ្ឋានភស្តុភារ និងបច្ចេកទេស

មាត្រា ២ : ស្នងការដ្ឋានខាងលើមានឋានៈស្មើនាយកដ្ឋាន ។

មាត្រា ៣ : តួនាទី ភារកិច្ច រចនាសម្ព័ន្ធ និងក្របខ័ណ្ឌចាត់តាំងរបស់ស្នងការដ្ឋាន អាស្រ័យដោយក្រសួងការពារជាតិកំណត់ ។

មាត្រា ៤ : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៥ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានឃើញសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី

នៃព្រះរាជាណាចក្រកម្ពុជា សូមមេត្តាចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ បាញ់**

**កន្លែងទទួល**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា ៥

-ឯកសារ-កាលប្បវត្តិ

# រចនាសម្ព័ន្ធចាត់តាំង
# កងរាជអាវុធហត្ថ

សច្ចាប័ន : ថ្ងៃទី ២៥ ខែ ៧ ឆ្នាំ២០០៥
បានឃើញ និងឯកភាព
លើរចនាសម្ព័ន្ធចាត់តាំងកងរាជអាវុធហត្ថ
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

# រចនាសម្ព័ន្ធចាត់តាំងកងរាជអាវុធហត្ថ

**មេបញ្ជាការ ១**

**មេបញ្ជាការរង ៣**

**នាយសេនាធិការ**

- ស្នងការព័ត៌មាននិងសន្តិសុខ
- ស្នងការផែនការប្រតិបត្តិការ
- ស្នងការស្រាវជ្រាវនិងយុត្តិធម៌
- ស្នងការបុគ្គលិកកម្លាំង
- ស្នងការភស្តុភារនិងបច្ចេកទេស

បានឃើញសេចក្តីជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
នៃព្រះរាជាណាចក្រកម្ពុជា សូមមេត្តាចុះហត្ថលេខា
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ បាញ់**

# អនុក្រឹត្យលេខ១៥៩
# ស្តីពីការកែសម្រួលរៀបចំ
# ឡើងវិញ
# រចនាសម្ព័ន្ធក្របខ័ណ្ឌ
# ចាត់តាំងបញ្ជាការដ្ឋាន
# កងរាជអាវុធហត្ថ
# លើផ្ទៃប្រទេស

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៥៩. អនក្រ. បក

# អនុក្រឹត្យ
# ស្តីពី
# ការកែសម្រួលរៀបចំឡើងវិញរចនាសម្ព័ន្ធ ក្របខ័ណ្ឌចាត់តាំង បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០២/នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខេកក្កដាឆ្នាំ២០០១ ស្តីពីការកែសម្រួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ ចុះថ្ងៃទី២១ខែធ្នូ ឆ្នាំ១៩៩៤ ស្តីពីភារកិច្ច និងរចនាសម្ព័ន្ធទូទៅនៃកងរាជអាវុធហត្ថ
- បានឃើញអនុក្រឹត្យលេខ ១៣៦ អនក្រ.បក ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៩ ស្តីពីការបង្កើតស្នងការដ្ឋាន ដាក់ចំណុះបញ្ជាការដ្ឋានកងរាជអាវុធហត្ថ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា ១.-** ត្រូវបានកែសម្រួលរៀបចំឡើងវិញរចនាសម្ព័ន្ធ ក្របខ័ណ្ឌចាត់តាំងបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេសដូចខាងក្រោម៖

១-សេនាធិការដ្ឋាន
២-ស្នងការដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
៣-ស្នងការដ្ឋានយុត្តិធម៌
៤-ស្នងការដ្ឋានបច្ចេកទេសសន្តិសុខ
៥-ស្នងការដ្ឋានភស្តុភារ
៦-ស្នងការដ្ឋានសម្ភារៈបច្ចេកទេស

**មាត្រា ២.-** សេនាធិការដ្ឋាន និងបណ្ណាស្នងការដ្ឋានខាងលើមានឋានៈស្មើនាយកដ្ឋាន។

**មាត្រា ៣.-** តួនាទីភារកិច្ច របនាសម្ព័ន្ធនិងក្របខ័ណ្ឌចាត់តាំងរបស់សេនាធិការដ្ឋាន និងស្នងការដ្ឋានចំណុះបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស អាស្រ័យដោយក្រសួងការពារជាតិកំណត់។

**មាត្រា ៤.-** ត្រូវបាននិរាករណ៍ អនុក្រឹត្យលេខ ១៣៦ អនក្រ.បក ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៩ ស្តីពីការបង្កើតស្នងការដ្ឋានដាក់ចំណុះបញ្ជាការដ្ឋានកងរាជអាវុធហត្ថ។

**មាត្រា ៥.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ និងស្ថាប័ន កងឯកភាពដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែមេសា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីសុំសេចក្តីសម្រេចដ៏ខ្ពង់ខ្ពស់

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ ៣ ឆ្នាំ២០១៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ បាញ់**

**កន្លែងទទួល**

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា ៥
- -ឯកសារ-កាលប្បវត្តិ

# រចនាសម្ព័ន្ធ
# ចាត់តាំងបញ្ជាការដ្ឋាន
# កងរាជអាវុធហត្ថ
# លើផ្ទៃប្រទេស

សច្ចាប័នៈ ថ្ងៃទី ០១ ខែមេសា. ឆ្នាំ២០១៤

**បានឃើញ និងឯកភាព**

លើរចនាសម្ព័ន្ធចាត់តាំង

បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**រចនាសម្ព័ន្ធចាត់តាំង**

**បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស**




បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីសុំសេចក្តីសម្រេចដ៏ខ្ពង់ខ្ពស់

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ បាញ់**

សច្ចាប័នៈរាជធានីភ្នំពេញថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ២០១៩
បានឃើញ និងឯកភាព
លើរចនាសម្ព័ន្ធចាត់តាំងបញ្ជាការដ្ឋានកងរាជអាវុធហត្ថ លើផ្ទៃប្រទេស
រដ្ឋមន្ត្រីក្រសួងការពារជាតិ

នាយឧត្តមសេនីយ៍ ផ្កាយមាស៤ ទៀ បាញ់

# រចនាសម្ព័ន្ធចាត់តាំង
# បញ្ជាការដ្ឋាន កងរាជអាវុធហត្ថ លើផ្ទៃប្រទេស




បានយកសេចក្ដីជម្រាបជូន
ឯកឧត្តម នាយឧត្តមសេនីយ៍ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ
អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ

នាយឧត្តមសេនីយ៍ ម៉ុល សារឿន

សច្ចាប័នៈរាជធានីភ្នំពេញថ្ងៃទី ១៧ ខែ កុម្ភ ឆ្នាំ២០១៥
បានឃើញ និងឯកភាព
លើរចនាសម្ព័ន្ធចាត់តាំង សាលាកងរាជអាវុធហត្ថ
**អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ**

នាយឧត្តមសេនីយ៍ **ប៉ុល សារឿន**

# រចនាសម្ព័ន្ធចាត់តាំង
# សាលាកងរាជអាវុធហត្ថ

## ទីចាត់ការ

- ក្រុមយោធាចារ្យ
- លេខាធិការដ្ឋាន
- **មន្ទីរ កិច្ចការហ្វឹកហ្វឺន**
  - ការិយាល័យ ផែនការ
  - ការិយាល័យ ហ្វឹកហ្វឺន
  - ការិយាល័យ សិក្សាស្រាវជ្រាវ
  - ការិយាល័យ យោធាចារ្យ
  - ការិយាល័យ សម្ភារៈសិក្សា
  - ការិយាល័យ ភាសា ព័ត៌មានវិទ្យា
  - ការិយាល័យ ក្របខ័ណ្ឌ គ្រប់គ្រងសិក្ខាកាម
  - ការិយាល័យ កីឡា
  - ការិយាល័យ បញ្ជូនសារ
  - ទីលានបាញ់ គ្រាប់ពិត
- **មន្ទីរ រដ្ឋបាល និងហិរញ្ញវត្ថុ**
  - ការិយាល័យ ផែនការ
  - ការិយាល័យ បុគ្គលិក
  - ការិយាល័យ ហិរញ្ញវត្ថុ
  - ការិយាល័យ ទំនាក់ទំនង សាធារណៈ
- **មន្ទីរ ភស្តុភារ**
  - ការិយាល័យ ផែនការ
  - ការិយាល័យ ផ្គត់ផ្គង់
  - ការិយាល័យ វិស្វកម្ម
  - ការិយាល័យ សុខាភិបាល
  - គិលានដ្ឋាន
- **មន្ទីរ បច្ចេកទេស**
  - ការិយាល័យ ផែនការ
  - ការិយាល័យ សម្ភារៈ
  - ការិយាល័យ បំពាក់
  - ការិយាល័យ បច្ចេកទេស
  - ឃ្លាំង
- កងអនុសេនាធំ ការពារ

រាជធានីភ្នំពេញថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ២០១៥
**មេបញ្ជាការ**

នាយឧត្តមសេនីយ៍ សៅ សុខា

សម្ងាត់ៈរាជធានីភ្នំពេញថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ២០១៥
បានឃើញ និងឯកភាព
លើរចនាសម្ព័ន្ធចាត់តាំងបញ្ជាការដ្ឋានកងរាជអាវុធហត្ថ រាជធានី-ខេត្ត
**អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ**

នាយឧត្តមសេនីយ៍ **ប៉ុល សារឿន**

# រចនាសម្ព័ន្ធចាត់តាំង
# បញ្ជាការដ្ឋាន កងរាជអាវុធហត្ថ រាជធានី-ខេត្ត




រាជធានីភ្នំពេញថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ២០១៥
**មេបញ្ជាការ**

នាយឧត្តមសេនីយ៍ សៅ សុខា

សច្ចាប័ន:រាជធានីភ្នំពេញថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ២០១៥
បានឃើញ និងឯកភាព
លើរចនាសម្ព័ន្ធចាត់តាំង មូលដ្ឋានកងរាជអាវុធហត្ថ
ខណ្ឌ.ក្រុង.ស្រុក
អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ

នាយឧត្តមសេនីយ៍ ម៉ុល សារឿន

# រចនាសម្ព័ន្ធចាត់តាំង
# មូលដ្ឋានកងរាជអាវុធហត្ថខណ្ឌ.ក្រុង.ស្រុក

**មូលដ្ឋាន**
**កងរាជអាវុធហត្ថ**

- សេនាធិការដ្ឋាន
- អង្គភាព ប្រតិបត្តិការ
- ស្នាក់ការសន្តិសុខ

រាជធានីភ្នំពេញថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ២០១៥
មេបញ្ជាការ

នាយឧត្តមសេនីយ៍ សៅ សុខា

# បទបញ្ជាផ្ទៃក្នុង
# មេបញ្ជាការ
# កងរាជអាវុធហត្ថ
# លើផ្ទៃប្រទេស

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

កងយោធពលខេមរភូមិន្ទ

ការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

លេខ : ០៩៤/០៩ ឋ.ង

ភ្នំពេញ,ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០០៩

# បទបញ្ជាផ្ទៃក្នុង

## មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស

- យោងព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- យោងព្រះរាជក្រមលេខ ០១៦/០៦/០៥ នស/រកម ចុះថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ
- យោងអនុក្រឹត្យលេខ ៧៧ អនក្រ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ស្តីពីភារកិច្ចនិងរចនាសម្ព័ន្ធទូទៅនៃកងរាជអាវុធហត្ថ
- យោងអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការកំណត់រយៈពេលបម្រើការងារប្រចាំសប្តាហ៍របស់មន្ត្រីរាជការស៊ីវិលក្នុងព្រះរាជាណាចក្រកម្ពុជា
- យោងអនុក្រឹត្យលេខ ២៦ អនក្រ ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៩៨ ស្តីពីឯកសណ្ឋាននិងស្លាកសញ្ញាកងរាជអាវុធហត្ថ
- យោងអនុក្រឹត្យលេខ ២៩ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០០២ ស្តីពីបទវិន័យទូទៅសម្រាប់កងយោធពលខេមរភូមិន្ទ
- យោងអនុក្រឹត្យលេខ ១៣៦ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០០៩ ស្តីពីការបង្កើតស្នងការដ្ឋានដាក់ចំណុះបញ្ជាការដ្ឋានកងរាជអាវុធហត្ថ
- ដើម្បីលើកកម្ពស់ស្មារតីទទួលខុសត្រូវ ក្នុងការដឹកនាំបញ្ជាតាមឋានានុក្រម ពង្រឹងវិន័យ សីលធម៌ វិជ្ជាជីវៈ និងសណ្តាប់ធ្នាប់របៀបរបបធ្វើការងាររបស់កងរាជអាវុធហត្ថ

ចេញបទបញ្ជាដូចខាងក្រោម ៖

**របៀបរបបធ្វើការងារ៖**

**១.១.របបកំណត់ផ្ទៃក្នុង ៖**

**ក-ពេលម៉ោងធ្វើការ ៖**

ត្រូវគោរពឱ្យបានទៀងទាត់តាមកាលកំណត់ការងាររដ្ឋបាល ៖

- ពេលព្រឹកម៉ោង ៧.០០នាទី ដល់ម៉ោង ១១.៣០នាទី ។
- ពេលល្ងាចម៉ោង ១៤.០០នាទី ដល់ម៉ោង ១៧.៣០នាទី ។
- ថ្ងៃបុណ្យ - ថ្ងៃសៅរ៍ -ថ្ងៃអាទិត្យ ៖សម្រាកតាមការកំណត់របស់រាជរដ្ឋាភិបាល ប៉ុន្តែចំពោះអង្គភាព ឬបុគ្គលដែលមានភារកិច្ច ប្រចាំបញ្ជា ប្រចាំការ-យាមកាម ឬបេសកកម្មត្រូវអនុវត្ត ភារកិច្ចតាមបញ្ជារបស់មេបញ្ជាការអង្គភាពប្រគល់ឱ្យ ។
- ហាមផឹកជាតិស្រវឹងក្នុងម៉ោងធ្វើការ និងពេលធ្វើប្រតិបត្តិការ ។

**ខ-ចាត់តាំងវេនប្រចាំបញ្ជា-ប្រចាំការ ៖**

គ្រប់អង្គភាពត្រូវចាត់តាំង ៖

+ ប្រចាំបញ្ជា ៖

- ត្រូវមានទីកន្លែងនិងបញ្ជីឈ្មោះវេននាយអាវុធហត្ថប្រចាំបញ្ជា ២៤/២៤ម៉ោង ។
- ត្រៀមកម្លាំងអន្តរាគមន៍សម្រាប់ដោះស្រាយសភាពការណ៍ ។

+ ប្រចាំការ ៖

- ត្រូវមានទីកន្លែង និងបញ្ជីឈ្មោះវេននាយអាវុធហត្ថប្រចាំការតាមលំដាប់ថ្នាក់២៤/២៤ម៉ោង សម្រាប់ជួយអង្គភាពក្នុងការគ្រប់គ្រងកម្លាំង មធ្យោបាយ គ្រឿងបំពាក់ សកម្មភាពការងារ និងការគោរពវិន័យប្រចាំថ្ងៃ ។

**គ-ការស្លៀកពាក់ឯកសណ្ឋាន ៖**

- ក្នុងម៉ោងធ្វើការងារ នាយ-ពលអាវុធហត្ថគ្រប់រូបត្រូវស្លៀក ឯកសណ្ឋានឱ្យបានត្រឹមត្រូវសមរម្យតាមការកំណត់ដែលមានចែងក្នុងអនុក្រឹត្យលេខ២៦ ។
- ឯកសណ្ឋានការងារ ពណ៌ប្រផេះ មួកប៉េរ៉េខៀវ សម្រាប់ធ្វើការងារក្នុងការិយាល័យនិងទំនាក់ទំនងស្ថាប័ននានា ។
- ឯកសណ្ឋានប្រតិបត្តិការ ហ្វីកហ្វីន ពណ៌គ្រេអ៊ី ពាក់មួកស្វ៊ីកាសឬប៉េរ៉េខៀវ ។
- ពេលចូលរួមពិធីផ្សេងៗត្រូវស្លៀកពាក់ឯកសណ្ឋានតាមការកំណត់របស់ពិធីនោះ ។
- ក្រៅម៉ោងធ្វើការហាមស្លៀកពាក់ឯកសណ្ឋាន ។

ឃ-គោរពទង់ជាតិ :

- រាល់ព្រឹកថ្ងៃច័ន្ទ ម៉ោង៧.០០នាទី ចាត់តាំងគោរពទង់ជាតិនិងអានពាក្យសច្ចាប្រណិធានរបស់កងយោធពលខេមរភូមិន្ទ ។
- បញ្ជាការដឹកនាំពិធីមានមតិ ពង្រឹងការគោរពវិន័យ លើកចំណុចល្អ ណែនាំចំណុចសេសសល់ចន្លោះប្រហោងក្នុងសប្តាហ៍ និងផ្សព្វផ្សាយការងារសំខាន់ៗដែលត្រូវអនុវត្តបន្ត ។

១_២_របបប្រជុំការងារ :

ក-បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស :

- ប្រជុំរួម ប្រចាំឆ្នាំ ៩ខែ ឆមាស និងត្រីមាស
- ដឹកនាំប្រជុំដោយមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស ។

ខ-កំណត់ពេលវេលាប្រជុំ :

- ប្រចាំឆ្នាំ សប្តាហ៍ទី១ ខែ មករា ឆ្នាំបន្ទាប់ ។
- ប្រចាំឆមាស សប្តាហ៍ទី១ ខែកក្កដា ។
- ប្រចាំត្រីមាសទី១ សប្តាហ៍ទី១ ខែមេសា ។
- ៩ខែ សប្តាហ៍ទី១ ខែតុលា ។

គ-សមាសភាពចូលរួម :

- មេបញ្ជាការរង នាយក នាយករងស្នងការ នាយខុទ្ទកាល័យ នាយការិយាល័យគ្រប់ជំនាញ សាលាកងរាជអាវុធហត្ថ មជ្ឈមណ្ឌលហ្វឹកហ្វឺននាយទាហានរងកងរាជអាវុធហត្ថ មេបញ្ជាការកងរាជអាវុធហត្ថរាជធានី-ខេត្ត។

ឃ-ប្រជុំដឹកនាំការងារប្រចាំខែរបស់បញ្ជាការ :

- ដឹកនាំប្រជុំដោយមេបញ្ជាការ ។
- កំណត់ថ្ងៃប្រជុំសប្តាហ៍ទី១ ខែបន្ទាប់ ។

សមាសភាពចូលរួមប្រជុំ :

- មេបញ្ជាការរង និងនាយខុទ្ទកាល័យ ។

ង-ប្រជុំការងារជំនាញប្រចាំខែ :

- ដឹកនាំការប្រជុំដោយមេបញ្ជាការរង ទទួលបន្ទុកសេនាធិការ ប្រភពកម្លាំង ភស្តុភារនិងបច្ចេកទេស ។
- កំណត់ពេលប្រជុំនៅសប្តាហ៍ចុងខែ ។

សមាសភាពចូលរួម :

- ថ្នាក់នាយក-នាយករងស្នងការ នាយការិយាល័យជំនាញចំណុះស្នងការដ្ឋាន សាលាកងរាជអាវុធហត្ថ

មជ្ឈមណ្ឌលហ្វឹកហ្វឺននាយទាហានរងកងរាជអាវុធហត្ថ ។ មានតែការប្រជុំដែលដឹកនាំដោយមេបញ្ជាការរង ទទួលបន្ទុកសេនាធិការប៉ុណ្ណោះ ដែលមានសមាសភាព មេបញ្ជាការរង និងជានាយសេនាធិការ កងរាជអាវុធហត្ថរាជធានីភ្នំពេញ និងខេត្តកណ្តាលចូលរួម ។

ច-<u>ប្រជុំនាឡិមាស</u> :

- ដឹកនាំប្រជុំដោយនាយកស្នងការ ។
- កំណត់ប្រជុំរាល់ថ្ងៃព្រហស្បតិ៍សប្តាហ៍ទី២ និង~~សប្តាហ៍ទី៤~~ ក្នុងខែនីមួយៗ ។

សមាសភាពចូលរួម :

- នាយករងស្នងការ និងការិយាល័យចំណុះ ។

ឆ-<u>ប្រជុំសប្តាហ៍</u> :

- ដឹកនាំប្រជុំដោយនាយការិយាល័យ ។
- កំណត់ប្រជុំរៀងរាល់ថ្ងៃពុធ ក្នុងសប្តាហ៍ ។

សមាសភាពចូលរួម :

- នាយរងការិយាល័យ និងនាយផ្នែកចំណុះ ។

ជ-<u>ថ្នាក់ការិយាល័យបំប៉នជំនាញ</u> :

- ដឹកនាំបំប៉នជំនាញដោយនាយការិយាល័យ ។
- កំណត់ពេលវេលាបំប៉ន ១ឆ្នាំម្តង ។

សមាសភាពចូលរួម :

- នាយរងការិយាល័យនាយផ្នែកចំណុះការិយាល័យខ្លួន និងនាយការិយាល័យជំនាញខ្សែរយៈបណ្តោយចំណុះមន្ទីរជំនាញនៃកងរាជអាវុអហត្ថរាជធានី-ខេត្ត ។

* <u>ចំណាំ</u> : ក្រៅពីការប្រជុំដែលបានកំណត់ខាងលើក្នុងករណីចាំបាច់ជំនាញនីមួយៗអាចធ្វើការកោះប្រជុំបន្ថែមទៀត ។

ឈ-<u>ថ្នាក់រាជធានី ខេត្ត</u> :

- មេបញ្ជាការកងរាជអាវុធហត្ថរាជធានី-ខេត្ត ដឹកនាំប្រជុំ ០១ខែម្តង ។
- ការប្រជុំនៅអ.ហរាជធានី-ខេត្ត ត្រូវយកលំនាំតាមការកំណត់ខាងលើ ។

* <u>បញ្ជាក់</u>:រាល់អង្គប្រជុំគ្រប់ថ្នាក់ត្រូវធ្វើកំណត់ហេតុរាយការណ៍តាមឋានានុក្រម ។

១.៣.<u>របបរាយការណ៍</u> :

ស្នងការដ្ឋាន ការិយាល័យជំនាញ សាលាកងរាជអាវុធហត្ថ បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានី-ខេត្ត ត្រូវធ្វើរបាយការណ៍ពីលទ្ធផលសកម្មភាពការងារ និងទិសដៅការងារបន្ត ផ្ញើមកខុទ្ទកាល័យ

ឆ្លងតាមឋានានុក្រមជំនាញ តាមការកំណត់ដូចខាងក្រោមៈ

ក-របាយការណ៍ផ្ញើមកឱ្យស្នងការដ្ឋានផែនការប្រតិបត្តិការ ដើម្បីសរុបជូនមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស រួមមាន :

- របាយការណ៍ប្រចាំថ្ងៃ ត្រូវផ្ញើមកមុនម៉ោង ១៦.០០នាទី
- របាយការណ៍ប្រចាំសប្តាហ៍ត្រូវផ្ញើមកមុនថ្ងៃសុក្រ
- របាយការណ៍ប្រចាំខែ ត្រូវផ្ញើមកមុនថ្ងៃទី ១៥ រាល់ខែ
- របាយការណ៍ប្រចាំត្រីមាស ១ ត្រូវផ្ញើមកមុនថ្ងៃទី ១៥ ខែ មិនា
- របាយការណ៍ប្រចាំឆមាស ១ ត្រូវផ្ញើមកមុន ថ្ងៃទី ១៥ ខែ មិថុនា
- របាយការណ៍ត្រីមាសទី៣+៩ខែ ត្រូវផ្ញើមកមុនថ្ងៃទី ១៥ ខែ កញ្ញា
- របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្ញើមកមុនថ្ងៃទី ១៥ ខែ វិច្ឆិកា

ស្នងការដ្ឋានផែនការប្រតិបត្តិការត្រូវបូកសរុប និងធ្វើរបាយការណ៍ទៅតាមគោលដៅដែលបានកំណត់ ។

ខ-របាយការណ៍ផ្ញើមកខុទ្ទកាល័យដើម្បីសរុបជូនមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស រួមមាន :

- របាយការណ៍ប្រចាំខែ ត្រូវផ្ញើមកមុនថ្ងៃទី ២៥ រាល់ខែ
- របាយការណ៍ប្រចាំត្រីមាស ១ ត្រូវផ្ញើមកមុនថ្ងៃទី ២៥ ខែ មិនា
- របាយការណ៍ប្រចាំឆមាស ១ ត្រូវផ្ញើមកមុន ថ្ងៃទី ២៥ ខែ មិថុនា
- របាយការណ៍ត្រីមាសទី៣+៩ខែ ត្រូវផ្ញើមកមុនថ្ងៃទី ២៥ ខែ កញ្ញា
- របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្ញើមកមុនថ្ងៃទី ២៥ ខែ វិច្ឆិកា

នាយខុទ្ទកាល័យត្រូវបូកសរុប និងធ្វើរបាយការណ៍ខាងលើនេះ ទៅតាមគោលដៅបានកំណត់ និងសម្រាប់ការប្រជុំមេបញ្ជាការ ។

## ២.ការចុះបំពេញបេសកកម្មនៅតាមបញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានី-ខេត្តៈ

### ២.១.ថ្នាក់អគ្គបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស :

- មានការជូនដំណឹងជាមុនអំពីពេលវេលា រយៈពេល និងខ្លឹមសារការងារ ។
- រៀបចំបពិសណ្ឋារកិច្ចដោយគងកិត្តិយសអង្គភាពធ្វើវន្ទនកិច្ច ។

សមាសភាពប្រតិភូអមដំណើរ(កំណត់ចំនួនដោយមេបញ្ជាការ )រួមមាន :

- មេបញ្ជាការរងទទួលបន្ទុក នាយកស្នងការ ។
- នាយការិយាល័យជំនាញមួយចំនួនដែលមានការពាក់ព័ន្ធ ។

២.២.ថ្នាក់មេបញ្ជាការរងកុងរាជអាវុធហត្ថលើផ្ទៃប្រទេស ឧទ្ទេលបន្ទុក(សេនាធិការ ប្រតិបត្តិការ និងរដ្ឋបាល_បច្ចេកទេស ):

- មានការជូនដំណឹងជាមុនអំពីពេលវេលា រយៈពេល និងខ្លឹមសារការងារ ។
- រៀបចំបដិសណ្ឋារកិច្ចសមរម្យ ។

សមាសភាពប្រតិភូអមដំណើរ :

- នាយក-នាយករងស្នងការ មិនមែនជាមេបញ្ជាការរង នាយការិយាល័យជំនាញរបស់ស្នងការដ្ឋានដែលចំណុះខ្លួន និងអាចមាននាយការិយាល័យជំនាញចំណុះស្នងការដ្ឋានផ្សេងៗទៀតទៅជាមួយ ។

២.៣.ថ្នាក់នាយស្នងការ :

- មានការជូនដំណឹងជាមុនអំពីពេលវេលា រយៈពេល និងខ្លឹមសារការងារ ។
- រៀបចំបដិសណ្ឋារកិច្ចសមរម្យ ។

សមាសភាពប្រតិភូអមដំណើរ :

- នាយការិយាល័យជំនាញចំណុះស្នងការដ្ឋានខ្លួន និងអាចមាននាយរងការិយាល័យជំនាញដែលមានការពាក់ព័ន្ធក្រៅពីស្នងការដ្ឋានរបស់ខ្លួនទៅជាមួយ ។

៣.ភារកិច្ចនិងភាតព្វកិច្ច:

៣.១.ការគោរពតាមឋានានុក្រម :

- នាយ-ពលអាវុធហត្ថ គ្រប់រូបមានកាតព្វកិច្ចទទួលនិងអនុវត្តបទបញ្ជាស្របច្បាប់តាមឋានានុក្រម ។
- យោធិនគ្រប់រូបត្រូវគោរពគ្នាទៅវិញទៅមកតាមឋានន្តរសក្តិ និងឋានានុក្រម ។
- ត្រូវមានភក្តីភាពចំពោះជាតិ សាសនា ព្រះមហាក្សត្រ និងប្តេជ្ញាការពាររាជរដ្ឋាភិបាលស្របច្បាប់ និងរដ្ឋធម្មនុញ្ញ ។
- អាវុធហត្ថគ្រប់រូបត្រូវមានសេចក្តីក្លាហាន ឆន្ទៈមោះមុត ពុះពារគ្រប់ឧបសគ្គ ក្នុងការបម្រើជាតិមាតុភូមិ និងមានភារកិច្ចអភិវឌ្ឍន៍ខ្លួន ទាំងផ្នែករាងកាយ ស្មារតី និងចំណេះដឹង ។
- ប្រធានអង្គភាពនីមួយៗមានភារកិច្ចដឹកនាំអង្គភាពឱ្យមានការអភិវឌ្ឍ ជាសុខភាព សាមគ្គីភាពផ្ទៃក្នុង ។ ដឹកនាំនាយ-ពលអាវុធហត្ថអោយគោរពម៉ឺងម៉ាត់នូវវិន័យកងទ័ព មានសីលធម៌ថ្លៃថ្នូរ និងមានការស្រឡាញ់ ទុកចិត្ត ជឿជាក់ពីប្រជាពលរដ្ឋ ។

៣.២.ការរក្សាសម្ងាត់ :

- ត្រូវរក្សាការសម្ងាត់រាល់ឯកសារផ្សេងៗរបស់កងរាជអាវុធហត្ថនិងកងទ័ព ។
- នាយអាវុធហត្ថ ត្រូវរក្សាទុកឯកសារនៅក្នុងអង្គភាព ដោយមានការរៀបចំទុកដាក់ឱ្យបានត្រឹមត្រូវ។
- មិនអនុញ្ញាតដាច់ខាត យកឯកសារទៅទុកនៅតាមផ្ទះឯកជន ។

- អាវុធហត្ថគ្រប់រូបមិនអនុញ្ញាតឱ្យធ្វើសន្និសីទសារព័ត៌មាន ឬផ្តល់ព័ត៌មានឱ្យដល់អ្នកយកព័ត៌មាន ស្តីអំពីសកម្មភាព ឯកសាររបស់កងរាជអាវុធហត្ថ និងឯកសារកងយោធពលខេមរភូមិន្ទ ដោយគ្មានការយល់ព្រមពីមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស ។
- កងរាជអាវុធហត្ថគ្រប់រូប មិនអាចបញ្ចេញមតិ យោបល់ជាសាធារណៈ ស្តីអំពីនយោបាយ សាសនា មនោគមវិជ្ជា ឬជាតិសាសន៍ដោយគ្មានការយល់ព្រមពីមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស។
- អ្នកនាំពាក្យរបស់កងរាជអាវុធហត្ថលើផ្ទៃប្រទេស ត្រូវបានចាត់តាំងដើម្បីធ្វើការឆ្លើយឆ្លង ទំនាក់ទំនងមជ្ឈដ្ឋានខាងក្រៅ ដូចជា :សារព័ត៌មាន ស្ថានទូត អង្គការជាតិ និងអន្តរជាតិ ។

៣-៣-ការប្រើប្រាស់ឯកសណ្ឋានសម្ភារៈគ្រឿងបំពាក់ :

នាយ-ពលអាវុធគ្រប់រូប :

- ត្រូវមានស្មារតីទទួលខុសត្រូវ ការពារ ថែរក្សាទុកដាក់មធ្យោបាយ សម្ភារៈគ្រឿងបំពាក់របស់អង្គភាពឱ្យបានល្អ ដើម្បីប្រើប្រាស់បានយូរអង្វែង ។
- ហាមយកមធ្យោបាយរបស់អង្គភាពទៅប្រើប្រាស់ជាលក្ខណៈឯកជន ។
- ពេលធ្វើដំណើរលើដងផ្លូវសាធារណៈត្រូវគោរពច្បាប់ចរាចរផ្លូវគោកឱ្យបានត្រឹមត្រូវ ។
- ការប្រើប្រាស់អាវុធជាតិផ្ទុះត្រូវអនុវត្តតាមច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ។

-ក្រុមប្រឹក្សាវាយតម្លៃតម្លើងឋានន្តរស័ក្តិ:

៤-១-បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស :

- មេបញ្ជាការ ជាប្រធាន
- មេបញ្ជាការរង ជាអនុប្រធាន
- នាយការិយាល័យបុគ្គលិក ជាសមាជិកអចិន្ត្រៃយ៍

៤-២-បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានី-ខេត្ត :

- មេបញ្ជាការ ជាប្រធាន
- មេបញ្ជាការរង ជាអនុប្រធាន
- នាយការិយាល័យបុគ្គលិក ជាសមាជិកអចិន្ត្រៃយ៍

-ការលើកសរសើរនិងជូនរង្វាន់:

៥-១-ការកំណត់របៀបលើកសរសើរ-ជូនរង្វាន់ :

- នៅបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេសនិងរាជធានី-ខេត្ត ត្រូវចាត់តាំងអនុគណៈកម្មការសរសើរ-ជូនរង្វាន់សម្រាប់អង្គភាពនិងបុគ្គល។

- អនុគណៈកម្មការនេះមានភារកិច្ចតាមដាន ត្រួតពិនិត្យ វាយតម្លៃអង្គភាព និងបុគ្គលដែលមានស្នាដៃល្អឆ្នើមក្នុងការបំពេញភារកិច្ច ។
- កំណត់ពេលប្រជុំ ១ឆ្នាំម្តង រៀងរាល់ឆមាសទី២ ក្នុងករណីចាំបាច់ ប្រធានអនុគណៈកម្មការអាចកោះប្រជុំជាវិសាមញ្ញ

### ៥_២_កំណត់សមាសភាពអនុគណៈកម្មការសរសើរ_ជូនរង្វាន់ :

**ក-ថ្នាក់បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស :**

- មេបញ្ជាការរងទទួលប្រភពកម្លាំង ជាប្រធាន
- នាយកស្នងការប្រភពកម្លាំង ជាអនុប្រធានអចិន្ត្រៃយ៍
- សមាជិក អាស្រ័យដោយប្រធានអនុគណៈកម្មការជាអ្នកកំណត់ ។

**ខ-ថ្នាក់បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានី-ខេត្ត :**

- មេបញ្ជាការ ជាប្រធាន
- ប្រធានមន្ទីរប្រភពកម្លាំង ជាអនុប្រធានអចិន្ត្រៃយ៍
- សមាជិក អាស្រ័យដោយប្រធានអនុគណៈកម្មការជាអ្នកកំណត់ ។

### ៥_៣_រូបភាពសរសើរជូនរង្វាន់ :

- ឥស្សរិយយស ប្រភេទមាតុប្រទេស ។
- ឥស្សរិយយស ប្រភេទការពារជាតិ ។
- ឥស្សរិយយសប្រភេទចម្រុះ (ការងារ ,ស្ថាបនា... ) ។
- បណ្ណសរសើរ លិខិតសរសើរក្រសួងការពារជាតិ និងអគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ ។
- លិខិតសរសើរមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស ។
- លើកសរសើរជាអង្គភាព ឬបុគ្គលគំរូល្អឆ្នើមប្រចាំឆ្នាំ ។ ចំពោះរង្វាន់និងសម្ភារៈអាស្រ័យដោយអង្គភាពនីមួយៗចាត់ចែងតាមលទ្ធភាព ។

## ៦_ការដាក់វិន័យ_ពិន័យ :

### ៦_១_កំណត់អំពីការដាក់វិន័យ_ពិន័យ :

- នាយ-ពលអាវុធហត្ថគ្រប់រូប ពេលប្រព្រឹត្តខុស ត្រូវទទួលវិន័យពិន័យកងទ័ពនិងអាចទទួលទោសតាមច្បាប់ តាមស្ថានទោសជាក់ស្តែង ។
- នៅបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេសនិងកងរាជអាវុធហត្ថរាជធានី-ខេត្ត ត្រូវចាត់តាំងក្រុមប្រឹក្សាវិន័យ-ពិន័យថ្នាក់ខ្លួន ។
- ក្រុមប្រឹក្សានេះមានភារកិច្ចត្រួតពិនិត្យវាយតម្លៃអំពីការអនុវត្តវិន័យ-ពិន័យរបស់នាយ-ពលអាវុធហត្ថ

ក្នុងពេលបំពេញភារកិច្ចប្រចាំថ្ងៃ និងប្រតិបត្តិការ ។

- គ្រប់អង្គភាពត្រូវមានសៀវភៅកត់ត្រាវិន័យ-ទណ្ឌកម្ម ដើម្បីកត់ត្រាបទល្មើសវិន័យ-ទណ្ឌកម្ម ។
- ការប្រជុំត្រួតពិនិត្យវិន័យ-ទណ្ឌកម្ម ត្រូវបានកោះប្រជុំតាមការសម្រេចរបស់ប្រធានក្រុមប្រឹក្សា ។

៦.២.<u>សមាសភាពក្រុមប្រឹក្សាវិន័យ-ទណ្ឌកម្ម</u> :

ក-<u>បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស</u> :

- មេបញ្ជាការ ជាប្រធាន
- មេបញ្ជាការរង ជាអនុប្រធាន
- មេបញ្ជាការរង ទទួលអធិការកិច្ច ជាអនុប្រធានអចិន្ត្រៃយ៍
- សមាជិក អាស្រ័យដោយប្រធានក្រុមប្រឹក្សាជាអ្នកកំណត់ ។

ខ-<u>បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានី-ខេត្ត</u> :

- មេបញ្ជាការ ជាប្រធាន
- មេបញ្ជាការរង ជាអនុប្រធាន
- ប្រធានមន្ទីរប្រេកពកម្លាំង ជាអនុប្រធានអចិន្ត្រៃយ៍
- សមាជិក អាស្រ័យដោយប្រធានក្រុមប្រឹក្សាជាអ្នកកំណត់ ។

៦.៣.<u>រូបភាពអនុវត្តវិន័យ-ទណ្ឌកម្ម</u> :

ក-<u>ការព្រមាន</u> :

- ការព្រមានធ្វើនៅពេលណាបុគ្គលមិនគោរពតាមបទបញ្ជាផ្ទៃក្នុងជាលើកទី១ ធ្វេសប្រហែសក្នុងការងារ ធ្វើឱ្យខូចខាតទ្រព្យសម្បត្តិអង្គភាពដោយអចេតនា ឬបោះបង់ចោលអង្គភាព ៣ថ្ងៃ ។
- ទណ្ឌកម្មកម្រិតស្រាល ហៅមកណែនាំផ្ទាល់ ។

ខ-<u>ការស្តីបន្ទោសផ្ទាល់មាត់</u> :

- អនុវត្តលើបុគ្គលដែលត្រូវបានការព្រមានច្រើនដង ហើយមិនព្រមកែប្រែ ។
- ទណ្ឌកម្មមានកម្រិតធ្ងន់ជាងការព្រមាន ហើយត្រូវចុះក្នុងសៀវភៅវិន័យ-ទណ្ឌកម្មប្រចាំអង្គភាព ។

គ-<u>ការស្តីបន្ទោសជាលាយលក្ខណ៍អក្សរ ឬការផ្អាកមុខតំណែង</u> :

- ជាទណ្ឌកម្មមានកម្រិតធ្ងន់ជាងការស្តីបន្ទោស ។ ទណ្ឌកម្មនេះអនុវត្តចំពោះយោធិនណាដែលមានកំហុសស្តីបន្ទោសផ្ទាល់មាត់ច្រើនដងតែមិនព្រមកែប្រែ ។
- សាមីខ្លួនត្រូវសរសេរស្វ័យត្រួតពិនិត្យកំហុសផ្ទាល់ខ្លួន ដោយលាយលក្ខណ៍អក្សរ និងចុះហត្ថលេខា

រួចផ្ញើជូនក្រុមប្រឹក្សាវិន័យ-ទណ្ឌកម្ម តាមឋានានុក្រមនិងចុះក្នុងសៀវភៅវិន័យ-ទណ្ឌកម្មអង្គភាព ។

ឃ-ការបណ្តេញចេញពីជួរកងរាជអាវុធហត្ថ :

- នៅពេលណាបុគ្គលរំលោភវិន័យធ្ងន់ធ្ងរប៉ះពាល់ដល់កិត្តិយសរបស់កងរាជអាវុធហត្ថ ប្រមាថថ្នាក់ដឹកនាំ ញៀនគ្រឿងញៀនមិនអាចកែប្រែបាន ជាប់ពិរុទ្ធបទល្មើសព្រហ្មទណ្ឌ ។
- មិនគោរពបទបញ្ជារបស់មេបញ្ជាការតាមឋានានុក្រម ប្រើអំពើហិង្សា បង្ករបួសស្នាមធ្ងន់ធ្ងរ លួច ឬបំផ្លាញទ្រព្យសម្បត្តិអង្គភាពដោយចេតនា បោះបង់ចោលអង្គភាពលើសពី ១៥ថ្ងៃឡើងទៅដោយគ្មានមូលហេតុ ។

ទទួលបានបទបញ្ជាផ្ទៃក្នុងនេះ គ្រប់បណ្តាអង្គភាពចំណុះ ត្រូវចាត់តាំងផ្សព្វផ្សាយរៀនសូត្រ និងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ថ្ងៃចុះហត្ថលេខានេះតទៅ ។

មេបញ្ជាការ

ឧត្តមសេនីយ៍ឯក សៅ_សុខា

# នីតិវិធីក្នុងការធ្វើសម្បថ
# និងពាក្យសច្ចាប្រណិធាន

## ឧបសម្ព័ន្ធ
## នីតិវិធីក្នុងការធ្វើសម្បថ

ការធ្វើសច្ចាប្រណិធាន ត្រូវដឹកនាំដោយក្រឡាបញ្ជីមួយរូប ហើយត្រូវធ្វើនៅចំពោះមុខវត្ថុសក្តិសិទ្ធិ នៅទីកន្លែងនៃតុលាការនីមួយៗ ។

មុននឹងចាប់ផ្តើមធ្វើសម្បថ អ្នកស្បថត្រូវអុជទៀន ធូប បូជាចំពោះវត្ថុសក្តិសិទ្ធិដែលខ្លួនត្រូវស្បថនោះ ។ បន្ទាប់មកក្រឡាបញ្ជីត្រូវអានប្រាប់ឮវាចខ្លាំងៗ ច្បាស់ៗ ឱ្យអ្នកស្បថស្តាប់ រួចអាន **ពាក្យសច្ចាប្រណិធាន** ឱ្យអ្នកស្បថថាតាម ។

ក្រោយពីធ្វើសម្បថរួច ក្រឡាបញ្ជីត្រូវធ្វើកំណត់ហេតុដែលបានឱ្យស្បថនោះ បញ្ជាក់ថាបានធ្វើត្រឹមត្រូវហើយ សេចក្តីបានចេញវាចាឱ្យស្បថយ៉ាងណា ត្រូវកត់ក្នុងកំណត់ហេតុយ៉ាងនោះផង ។

### ប្រណិធាន

បពិត្រអស់ទេព្រក្ស អារុក្ខអារក្សអ្នកតា និងបារមីដ៏សក្តិសិទ្ធិ មានព្រះអង្គដងកើរ ព្រះអង្គក្រពុំឈូក ព្រះអង្គស្វេតច្ឆត្រ ព្រះអង្គចេក ព្រះអង្គចម អ្នកតាឃ្លាំងមឿង អ្នកតាក្រហមក លោកតាដំបងដែក លោកតាដំបងក្រញូង លោកយាយទេព ព្រះអង្គវិហារសួគ៌ ព្រះអង្គព្រះជីវវត្តបារាយណ៍ ព្រះអង្គវត្តភ្នំខ្លែង ជាដើម សូមយាងអញ្ជើញមកធ្វើជាអធិបតីក្នុងពិធីសម្បថនេះ ស៊ិតគូក្តីនេះបានឈ្លោះទាស់ទែងគ្នា ហើយអះអាងលើសាក្សីថាជាអ្នកបានដឹង បានឃើញ បានឮ និងបានចាំដោយផ្ទាល់ ហើយច្បាប់តម្រូវឱ្យយកអ្នកទាំងនេះ មកធ្វើជាសាក្សីឱ្យឆ្លើយឱ្យ បានទៀងត្រង់តាមពិត ។

បើអ្នកណាឆ្លើយមិនពិត តាមដែលខ្លួនបានដឹង បានឃើញ បានឮ និងបានចាំទេ សូមអស់ទេព្រក្ស អារុក្ខអារក្សអ្នកតា យាយទេព និងបារមីដ៏សក្តិសិទ្ធិ បំផ្លាញឱ្យលាញ ឱ្យស្លាប់តែហោងយ៉ាងវេទនា ដោយគ្រាប់កាំភ្លើង ខ្សែភ្លើងឆក់ រន្ទះបាញ់ ខ្លាខាំ ពស់ចឹក លុះអនាគតជាតិឱ្យព្រាត់[illegible] បងប្អូន កូនចៅ ឱ្យក្ររហេមរហាម ខ្សត់ទ្រព្យ រងទុក្ខវេទនា អស់ព្រាំរយជាតិ ។

[illegible]ណាឆ្លើយឱ្យការណ៍ដោយពិតត្រង់ មិនវៀចវេរ មិនភូតកុហក មិនលំអៀង ព្រោះជា[illegible] សមគំនិត ព្រោះខ្លាច ព្រោះស្អប់ ព្រោះលាភសក្ការៈ ព្រោះស៊ីសំណូកទេ សូមអស់ទេព្រក្ស អារុក្ខអារក្សអ្នកតា យាយទេព និងបារមីដ៏សក្តិសិទ្ធិ ក្នុងលោកជួយឱ្យគេមាន

អាយុយឺនយូរ មានសុខភាពល្អ មានទ្រព្យសម្បត្តិសម្បូរណ៍ហូរហៀរ មានញាតិផៅគោរពស្រលាញ់រាប់អាន លុះអនាគតជាតិបានជួបតែសេចក្តីល្អ ចម្រុងចម្រើន ថ្កុំថ្កើង រុងរឿង សមដូចសេចក្តីបំណងប៉ងប្រាថ្នា កុំបីអាក់ខានឡើយ ។

## ពាក្យសច្ចាប្រណិធាន

ខ្ញុំសូមឆ្លើយតែការពិត ដែលខ្ញុំបានឃើញ បានឮ បានដឹង និងបានចាំផ្ទាល់ ។

បើខ្ញុំឆ្លើយមិនពិត ដោយប្រការណាមួយ សូមអស់ទេព្រក្ស អារក្សអ្នកតា និងបារមីដ៏សក្តិសិទ្ធិទាំងអស់ បរាមុខខ្ញុំ ឱ្យវិនាសលាញ អន្តរាយទ្រព្យសម្បត្តិ និងស្លាប់តៃហោង យ៉ាងវេទនា តែបើខ្ញុំឆ្លើយពិតត្រង់ សូមទេវតាជួយឱ្យខ្ញុំ មានទ្រព្យសម្បត្តិសម្បូរណ៍ហូរហៀរ និងរស់នៅប្រកបដោយសេចក្តីសុខក្សេមក្សាន្ត ជួបជុំបងប្អូន ញាតិផៅសន្តាន ជារៀងរហូតគ្រប់ជាតិកុំបីអាក់ខានឡើយ ។



# ព្រះរាជក្រឹត្យលេខ ៤៤៦នស និង៤៤៧នស ស្តីពីការបង្កើត កងរាជអាវុធហត្ថ

ព្រះរាជក្រឹត្យ លេខ ៤៤៦ ន.ស ចុះថ្ងៃទី ២៧ ខែកញ្ញា ១៩៥៧

ប្រការ ១.– ក្រុមតម្រួតពាហនខ្មែរ ត្រូវបានឈ្មោះជា « ក្រុមរាជអាវុធហត្ថ ខ្មែរ » ។

ប្រការ ២.– ក្រុមរាជអាវុធហត្ថ ខ្មែរ ជាភាគបូរណភាពមួយរបស់កងយោធពលខេមរភូមិន្ទ ។

ប្រការ៣ - ការទុក និងការរៀបចំ ត្រូវទៅជាបណ្ដោះអាសន្នសិន ដូចមានកំណត់ទុកមកហើយ តាមភាពជាក់លាក់ និងតាមដ្ឋាន ដែលជាពលភាព សំរាប់ក្រុមតម្រួតពាហនខ្មែរ ។

ប្រការ ៦ - ច្រើនជាងនេះទៅទៀត នៃមុខងារ ដែលមានបញ្ញត្តិទុកស្រាប់ សំរាប់ក្រុមតម្រួតពាហនខ្មែរ ក្នុងការណ៍អនុវត្ត និងវិន័យ ហើយនិងការណ៍តុលាការ រង់ចាំពាហន នៃកងកម្លាំង ក្រុមកងការពារជាតិ អាចទទួលពីអំណាចស៊ីវិល ដោយមានកំណត់ ទូទៅសកម្ម ដើម្បីញ៉ាំងរៀបចំ ការគោរពច្បាប់ ហើយនិងបទបញ្ញត្តិ ជាពលភាព ជាមួយនិងក្រុមប៉ូលិស ។

សមត្ថកិច្ច នៃសមាជិក ដែលបានធ្វើសច្ចាប្រណិធានរួចហើយ មានវិសាលភាព ពេញអាណាខេត្ត និងដល់ប្រជាជន ។

ប្រការ ៤. ដោយមានឥស្សរភាព នៃបេសកកម្ម ដែលជាបញ្ហាពាហនបាន ប្រគល់ដោយទុកចិត្ត ចំពោះក្រុមនេះ ដែលត្រូវទទួលបញ្ជាផ្ទាល់ ក្រុមកងការពារជាតិអាច នឹងដាក់តាមផ្លូវនៃកំណើណ្ណ ដោយមានកិច្ចព្រមព្រៀងពីអគ្គសេនាធិការផង ក្រោមបទ បញ្ញត្តិនៃមន្ទីរពេទ្យ ក្រៅតាំងឡាយ ដើម្បីជាប្រយោជន៍ នៃកិច្ចការដែលមានបញ្ជាក់យ៉ាង ច្បាស់លាស់ ហើយដែលមានបូរណភាព ក្នុងក្របខ័ណ្ឌជាប្រក្រតី នៃមុខងារ ។

ការសុំតាក់តែងដល់តំណែណ្ណ ត្រូវបញ្ជូនតាមផ្លូវក្រសួងការបរទេស និងបាន ពេញចិត្តពីអគ្គលេខាធិការ នៃគណៈយោធពលខេមរភូមិន្ទ គឺត្រូវបានសមានៃចំនួនពិត ហើយទៅតាមមធ្យោបាយចាំបាច់ផង ។

ប្រការ ៦.– អត្ថបទជាធម្មការ នៅពេលក្រោយ និងបញ្ជាក់ច្បាប់តំណែណ្ណនៃ អំណាចស៊ីវិល ដែលទទួលខុសត្រូវអំពីការគោរពនៃសេចក្ដីរៀបរយ ហើយនិងសន្តិសុខទូទៅ លើឯកសារនៃក្រុមរាជអាវុធហត្ថ ដែលមានបោះគោលសមានត្រឹមដែន នៃមណ្ឌលវេជ្ជបាល ។

---

ព្រះរាជក្រឹត្យ លេខ ៤៤៧ ន.ស. ចុះថ្ងៃទី ២៧ ខែ កញ្ញា ១៩៥៧

ប្រការ ១ – ក្រុមរាជអាវុធហត្ថខ្មែរ បង្កើតឡើងដោយព្រះរាជក្រឹត្យ លេខ ន.ស. ចុះថ្ងៃទី ខែ គ.ស. ១៩៥៧ មានសារៈសំខាន់ជាកម្មវត្ថុ ដើម្បីញាំងឲ្យមាន ដល់អំពើផ្ទាល់ នៃប៉ូលិសពាហន និងចូលរួមក្នុងការកាន់កាប់ នៃប៉ូលិសវេជ្ជបាលហើយនិងប៉ូលិសតុលាការ ។

ក្រៅពីនេះទៅទៀត ក្រុមនេះមានភារៈដំបំពេញបេសកកម្ម ខាងការពារប្រទេសជាតិ និងផ្ដល់ការជួយដល់អំណាចពាហនវេជ្ជបាលនិងតុលាការ ក្នុងករណីនិងលក្ខខណ្ឌ ដែលមានចែងក្នុងច្បាប់ជាពលការ ។

ប្រការ ២.– បេសកកម្ម នៃប៉ូលិសពាហន មានទម្ងន់ជាចាំបាច់ដល់ក្រុមរាជអាវុធហត្ថ មានជួនកាលជាសេចក្តីបន្ថែម សំរាប់បញ្ហាទំនិញចប់ក្រោម ៖

១.– ក្នុងកម្មសិទ្ធ នៃការបង្ហាញទុក ក្រុមរាជអាវុធហត្ថខ្មែរ ត្រូវចូលរួមការរក្សាទុក នៃវិន័យ ក្នុងកងពាហន ដែលមានភារកិច្ចសាធារណៈក្នុងកងទ័ព ។

ក្នុងក្របខ័ណ្ឌនេះ ក្រុមនេះមានភារៈសំគាល់ទុក ការស្វែងរកអ្នកបាត់ខ្លួនខុសច្បាប់ ការឃ្លាំមើលពាហនដែលបាត់ខ្លួនជារឿយៗពីកងទ័ព ការក្លា ដឹបនកាន់កាប់ទៅដោយកងពល ក្នុងការផ្លាស់ទីកន្លែង ការនាំពាហនពីកន្លែងមួយទៅកន្លែងមួយការក្លា ការគ្រប់គ្រងយន្តពាហន ហើយនិងការក្លាពាហននៃយោធភូមិ ។

២.– ក្នុងកម្មសិទ្ធិ ចប់ក្រោម ក្រុមរាជអាវុធហត្ថខ្មែរ ត្រូវចូលរួមហ៊ានហើសហេតុ នូវការស្វែងរក ការប្រព្រឹត្តល្មើសចាំងអស់ ដែលត្រូវជាសមត្ថកិច្ច របស់និតិកម្ម នៃកម្មាធិការ ដើម្បីនឹងប្រគល់ខ្លួនអ្នកប្រព្រឹត្តល្មើសទាំងនោះ ឲ្យសាលាកាត់ក្តី ដែលមានភារៈដាក់ទណ្ឌកម្ម ។

៣ – ក្នុងពេលសង្គ្រាម កងទ័ពគ្រប់ផ្នែកទាំងអស់ ក្រុមរាជអាវុធហត្ថ មានភារៈកំប៉ុនដល់ការក្លាខ្លួនទៅនៃពាហនការក្លានៃគុណភាពពាហន ការនាំឈ្លើយសង្គ្រាមពីកន្លែងមួយទៅកន្លែងមួយ តាមដីកាតុលាការ កិច្ចការក្នុងពន្ធនាគារ ការក្លាដល់ការគ្រាប់ចរតាមថ្នល់ និងតាមយថាហេតុដល់ការជាពិសេស ការអនុវត្ត ហើយនិងការដឹកនាំឈ្លើយសង្គ្រាម ។

ប្រការ ៣.— បេសកកម្ម នៃប៉ូលិសរដ្ឋបាល ដែលមានក្រុមពលអាវុធហត្ថ ជួយផង ត្រូវបង្ការដល់ចលាចល ដែលប៉ះពាល់ដល់របៀបរៀបរយនៃសាធារណៈ ។

បេសកកម្ម អាចធ្វើឡើងកក់ក្ដៅដែរ ដល់លក្ខណៈទប់ស្កាត់ក្នុងករណីដែលមាន ភាពប្រញាប់ប្រមហាភ័យ ដែលកើតឡើងដល់ភ្លាមៗ ដើម្បីសេចក្ដីសុខ និងសភាព ចំរើន ដល់សុខភាពសាធារណៈ ។

ក្រុមពលអាវុធហត្ថ ត្រូវចូលរួមជាមួយនឹងប៉ូលិសរដ្ឋបាល នៅតាមមធ្យោបាយ ផ្ទាល់របស់ខ្លួន តាមសេចក្ដីសុំពីអំណាចស៊ីវិល ទទួលកិច្ចការរក្សាទុកនូវសេចក្ដី រៀបរយ ហើយនិងសេចក្ដីសន្តិសុខជាសាធារណៈ ។

ប្រការ ៤.— បេសកកម្ម នៃប៉ូលិសតុលាការ មានដាក់នៅនឹងក្រុមពល អាវុធហត្ថ មានការកក់ក្ដៅដល់លក្ខណៈទប់ស្កាត់ និងមានសារៈសំខាន់សំរាប់ការ ស្វែងរកអ្នកបង្កើតបទទុច្ចរិត បទមជ្ឈិម និងបទលហុ ដែលមានប្រមាណនូវច្បាប់ ស្ដីពីបទទុច្ចរិត ។

ប្រការ ៥.- ក្រុមពលអាវុធហត្ថ បង្កើតឡើងជាសេវាការ នៃការទាក់ទង ឧទ្ទេសកងទ័ព និងកងកម្លាំងការពារលើផ្ទៃប្រទេស សំរាប់ជាតំណាងពិនិត្យ នៃអាណាខេត្ត ។

ក្រុមពលអាវុធហត្ថ ចូលរួមដល់ការត្រួតត្រា ការរៀបចំ ការសិក្សា មើល និងការកណ្ដាលការពារបំរុង ។

ប្រការ ៦.– ក្រុមរាជអាវុធហត្ថ បង្កើតឡើងក្នុងសេវាការប្រតិបត្តិ សំរាប់បេសកកម្មច្រើន ដែលជារណបមន្ទីរដ្ឋមន្ត្រីផ្សេងៗ ។

ក្រុមរាជអាវុធហត្ថ បំរើជាប្រចាំ ដើម្បីជួបក្រសួងយុត្តិធម៌ ក្នុងកិច្ចការតុលាការស៊ីវិល និងទាហាន ហើយនិងជួយធ្វើអន្តរាគមន៍ ក្នុងកិច្ចការប្រតិបត្តិ ដើម្បីឲ្យបានសំរេច ដោយយុត្តិធម៌ ។

ប្រការ ៧.– នាយទាហាននិងអ្នកមានបណ្ណស័ក្តិ នៃក្រុមរាជអាវុធហត្ថកាន់កាប់ក្នុងលក្ខណ្ឌ ដែលមានប្រមាណ ដោយបទបញ្ញាជាពលភាពក្នុងកងទ័ព គឺកាបញ្ញាទាហាននៃឋានៈកាត ដែលក្រុមនេះត្រូវនៅក្រោមបង្គាប់ ។

ក្រៅពីនេះនាយទាហាន នៃក្រុមរាជអាវុធហត្ថ ប្រតិបត្តិតាមជាន់ថ្នាក់ផ្សេងៗ តាមលំដាប់ដំណែងនៃអាណាខេត្ត ចាត់ការនិងត្រួតត្រាកិច្ចការ នៃកងពលតូចដែលនៅក្នុងមណ្ឌលរបស់ខ្លួន ។

ប្រការ ៨ – នាយទាហាននៃក្រុមរាជអាវុធហត្ថ ត្រូវជាកាប៉ៃទ្រួយ មេបញ្ជាការនៃកម្លាំងសាធារណៈ ។

អ្នកមានបណ្ណស័ក្តិ និងអាវុធហត្ថ ត្រូវជាកាប៉ៃទ្រួយ ភ្នាក់ងារនៃកម្លាំងសាធារណៈ ។

ក្នុងគុណសម្បត្តិនេះ នាយទាហានអ្នកមានបណ្ណស័ក្តិ និងអាវុធហត្ថទាំងឡាយ:

– អាចហៅឲ្យជួយកិច្ចការខាងប៉ូលិសតុលាការ ការចាប់បង្ក្រាបការស្វែងបទមជ្ឈិម និងការប្រើកម្លាំងពល ។ល។

- ត្រូវប៉ិនប្រសប់ ដល់ការដាក់ឲ្យប្រតិបត្តិ លិខិតប្រគល់សិទ្ធិនៃតុលាការ ។

ប្រការ ៩.- នាយទាហាន អ្នកមានបណ្ណាសក្តិ និងអាវុធហត្ថ នៃក្រុមកងអាវុធហត្ថ ក៏ដូចជាមន្ត្រី ឬភ្នាក់ងារនៃប៉ូលិសរដ្ឋបាលដែរ ។

ក្នុងឋានៈនេះ ត្រូវចូលរួមក្នុងការកាន់កាប់ជាបន្ទាន់ ជាមួយនឹងក្រុមប៉ូលិសរដ្ឋបាលក្នុងទិដ្ឋភាព ទាំងអស់ខាងនៅ ក្នុងទីក្រុង ហើយនិងក្នុងជនបទ ។

ប្រការ ១០.- ទាហានទាំងអស់ នៃក្រុមកងអាវុធហត្ថ មិនថាឋានៈណា ជាឋានៈណា និងបានទៅជាភ្នាក់ងារ នៃប៉ូលិសតុលាការ ។

ត្រូវមានគុណសម្បត្តិ ដើម្បីពិនិត្យពិច័យ តាមកំណត់ហេតុ ដោយយុត្តិធម៌ ចំពោះការល្មើសទាំងអស់ ។

ក្រៅពីនេះ គឺជាជំនួយនៃព្រះរាជអាជ្ញា ដូចជាមន្ត្រី នៃប៉ូលិសតុលាការ ៖

- នាយទាហាន និងអ្នកមានបណ្ណាសក្តិ នៃក្រុមកងអាវុធហត្ថ -

- អាវុធហត្ថបានធ្វើការ យ៉ាងតិច ៣ ឆ្នាំ ក្នុងខេត្តក្រុង និងបានតែងតាំង ក្រោយពេលប្រឡងប្រជែង តាមសេចក្តីសំរេច នៃរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

គុណសម្បត្តិ នៃមន្ត្រីប៉ូលិសតុលាការ ត្រូវពិភាក្សាច្បាប់ពិនិត្យពិច័យការប្រព្រឹត្តល្មើសទាំង៖ មិនសុំកំណែណាមួយដល់កម្លាំងសាធារណៈ ក្នុងការកាន់កាប់នៃមុខងារ ដែលខ្លួនមានទាក់ទង ។

គណសម្ព័ន្ធ របស់អ្នកជំនួយនៃព្រះរាជអាជ្ញា ត្រូវសុំការយកឥទ្ធិពល នៃការបើកបង្គំ និងគន្លឹះការណ៍ នៃបទចម្រៀង ។

នាយទាហាន និងអ្នកមានបណ្ដាសក្ដិ ហើយនិងរាជអាវុធហត្ថ ដែលកាន់កាប់ឋានៈជាមន្ត្រី នៃប៉ូលិសតុលាការ មិនជាអ្នកជំនួយនៃព្រះរាជអាជ្ញា គឺជានាយទាហាន នៃប៉ូលិសតុលាការយោធា ។

ប្រការ ១១.– ក្រុមរាជអាវុធហត្ថ ត្រូវដាក់ក្រោមចំណុះផ្ទាល់ នៃបទបញ្ជាទាហាន ។ ក្រុមរាជអាវុធហត្ថ ត្រូវឡើងទៅកាន់ ក្រៅពីនេះទៅទៀត ៖

– រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីការខាងរដ្ឋបាល –

– រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដើម្បីការខាងតុលាការ –

អំពើនៃបទបញ្ជាទាហាន ត្រូវកាន់កាប់ ៖

– ដោយផ្ទាល់ពីគណៈមេបញ្ជាការ នៃក្រុមរាជអាវុធហត្ថ –

– ដោយអគ្គកម្មន៍ នៃមេបញ្ជាការអាណាខេត្ត ចំពោះការបំបែក នៃអាវុធហត្ថដែលដាក់ឲ្យនៅក្រោមបទបញ្ជា នៃភូមិភាគទាហាន ។

អំពើរបស់ក្រសួងទាំង ២ នឹងប្រតិបត្តិទៅបាន ដោយមានពាក្យសុំ ៖

– ដោយរដ្ឋមន្ត្រីផ្ទាល់ ចំពោះបទបញ្ជាទាហាន –

– ដោយមានអ្នកតំណាងដោយខ្សែក តាមឋានៈ នៃរដ្ឋមន្ត្រីផ្ទាល់ ចំពោះការបំបែកអាណាខេត្ត នៃក្រុមរាជអាវុធហត្ថ ។

# La Gendarmerie nationale, son organisation et son fonctionnement

Par kret n° 574/71-CE du 5 octobre 1971, il est ordonné ce qui suit :

## TITRE—I

### —Généralités—

*Article 1er.*- La Gendarmerie royale khmère instituée et organisée par kret n° s 446.NS. et 447.NS. de 27 septembre 1957 prend l'appellation de «Gendarmerie nationale», à compter de la signature du présent kret.

*Article 2.*— La Gendarmerie nationale est une Arme des forces armées nationales et relève statutairement du haut commandement des Forces armées nationales khmères. Elle a pour mission d'assurer la Police militaire, la Police administrative et la Police judiciaire. Elle porte des insignes distinctifs qui lui sont propres.

*Article 3.*— Dans l'exercice de ses missions de Police administrative et de Police judiciaire civile, la Gendarmerie nationale est placée sous l'autorité directe du ministre de l'Intérieur.

En cette qualité, le ministre de l'Intérieur, responsable du maintien de l'ordre, de la sécurité et de la salubrité publique, reçoit du haut commandement des Forces nationales khmères délégation permanente de pouvoir hiérarchiques ci-après :

— Pouvoir de nomination à des emplois ou des mutations à l'intérieur des services de la Gendarmerie nationale relevant de son autorité.

— pouvoir de renvoi au commandement des Forces armées nationales khmères.

— pouvoir de sanctions (propositions de récompenses et punitions) dans la limite de sa compétence.

— pouvoir d'apprécier et de noter tous les gendarmes, officiers et non-officiers exerçant les fonctions de Police administrative et de Police judiciaire d'après les dispositions prévues par le haut commandement des Forces armées nationales khméres.

## TITRE—II

### Organisation

*Article 4.*— La Gendarmerie nationale est placée sous les ordres d'un commandant de Gendarmerie nationale qui dispose à l'échelon central d'un état-major, d'une inspection et d'une Ecole de Gendarmerie.

*Article 5.*— La Gendarmerie nationale est articulée ainsi qu'il suit :

1.— à l'échelon région administrative ou région militaire, en une légion de la Gendarmerie nationale placée sous les ordres d'un commandant de légion exerçant son commandement par un état-major régional et secondé :

—d'un adjoint territorial

—et d'un adjoint mobile.

2.— à l'échelon khét, anouk-khét et municipalité autres que Phnom-Penh, en une compagnie de Gendarmerie territoriale et un détachement d'intervention de gendarmerie mobile.

3.— à l'échelon srok en une section de gendarmerie territoriale et un détachement de gendarmerie mobile.

4.— à l'échelon sangkat en une brigade et en poste de gendarmerie pour certaines agglomérations importantes.

Les forces de la gendarmerie nationale peuvent disposer de personnels auxiliaires dénommés auxiliaires de la gendarmerie nationale.

*Article 6.*— La ville de Phnom-Penh dispose d'une circonscription de gendarmerie territoriale avec un état-major, articulée en :

—Une ou plusieurs compagnies par sangkat suivant son importance.

—un bataillon d'intervention de gendarmerie mobile.

*Article 7.*— Le commandement de la gendarmerie nationale dispose de réserves de commandement de la gendarmerie nationale stationnée à Phnom-Penh et composées de :

—un bataillon de sécurité et de service,

—deux bataillons d'intervention,

—une compagnie de gendarmerie de l'air,

—une compagnie de gendarmerie maritime,

— des services techniques,

— des unités mobiles adaptées ou affectées aux grandes unités.

( à suivre )

## LA GENDARMERIE NATIONALE SON ORGANISATION ET SON FONCTIONNEMENT ( SUITE ET FIN )

Par Kret n° 574/71. CE du 5 Octobre 1971
il est Ordonné ce qui suit :

TITRE III

ATTRIBUTIONS.—

Article 8 — La Gendarmerie Nationale a pour principales attridutions de faire respecter les Lois et les règlements en vigueur dans le cadre des missions de polices militaires, administrative et judiciaire prévues à l'acticle 2.

I. De la police militaire.—

Article 9 — En matière de police militaire, la Gendarmerie Nationale a le devoir de :

1°) participer au maintien de la dis cipline et de faire observer les règlements militaires dans les différents Corps de l'Armée

2°) exécuter les mandats et commission justice militaire.

3o) assurer la sécurité et la sûreté militaire.

4o) assurer la Police Générale Militaire, la Police Judiciaire Militaire, le transfèrement des prisonniers d'ordre Judiciaire, le service des prisons, la police de la circulation routière et, éventuellement la garde et la conduite des prisonniers de guerre

Article 10.— La Gendarmerie Nationale paticipe à l'Administration à la préparation, à l'instruction des réserves dans le cadre de la mobilisation Générale.

II.— De la police administrative.

Article 11.— En matière de police administrative la Gendarmerie Nationale veille au maintien de l'ordre, à la sécurité et à la salubrité publique sous l'autorité directe des Autorités administratives dont elle dépend.

III — De la police judiciaire civile —

Article 12 — En matière de police judiciaire cicile la Gendarmerie Nationale réprime les infractions qualifiées de crimes, délits et contraventions et en recherche les auteurs pour les déférer devant les tribunaux compétents.

Elle exécute les mandats et commissions de justice émis par les tribunaux répressifs.

Article 13.— Les Officiers de Gendarmerie Nationale ainsi que les sous Officiers exerçant la fonction de Cammandant de Brigade ou chef de poste sont Officiers de police judiciaire.

A Ce titre ils ont qualité de constater les infractions, d'en dresser des procès verbaux et le cas échéant, réquérir toutes fôrces publiques nécessaires à l'accomplissement de Leur fonctions.

Les autres personnels de la Gendarmerie Nationale sont des agents de la force publique et auxiliaires d'officier de police judiciaire.

TITRE IV

— Dispositions particulières

Artilce 14.— Sont abrogées purement et simplement toutes dispositions antérieures au présent Kret.

Article 15.— Le ministre de la Défense Nationale, le Haut Commandenent des Forces Armées Nationales Khmères et le Ministre de l'Intérieur sont chargés, chacun en ce qui le concerne, de l'exécution du présent Kret —

Fait à Phnom Penh le 5 Octobre 1971
Signé : CHÉNG-HÉNG
par le Chef de l'état
Le précident du conseil des
Ministre délégué
Signé : SISOWATH SIRIK MATAK

Présente à la Signature du chef de l'état
par la président du conseil des ministres
délégué
Ministre de la dépense nationale
Signé : SISOWATH SIRIK MATAK

Pour impliation le sécretaire du
Conseil des Ministres
Signé : OUK SUN

Pour copie conforme
Le Lt. Colonel AM. SAEN. Directeur de
Mobilisation et de Recrutement
Signée : AM - SAEN

# កងអាវុធហត្ថជាតិ

## រចនាសម្ព័ន្ធ និងការប្រព្រឹត្តទៅនៃកងអាវុធហត្ថជាតិ

តាមក្រឹត្យលេខ ៥៧៤/៧១-CE ចុះថ្ងៃទី ៥ ខែ តុលា ឆ្នាំ ១៩៧១ ត្រូវបានបង្គាប់អោយប្រើដូចតទៅ :

### មាតិកា_១

### គំនិតទូទៅ

មាត្រា ១ : កងរាជអាវុធហត្ថខ្មែរដែលបានបង្កើតឡើង និងរៀបចំ តាមក្រឹត្យលេខ ៤៤៦.នស និង ៤៤៧ នស ចុះថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ ១៩៥៧ នោះ ត្រូវប្តូរការហៅ ថាជា ( កងអាវុធហត្ថជាតិ ) វិញ ចាប់ពីថ្ងៃចុះហត្ថលេខាលើក្រឹត្យនេះតទៅ ។

មាត្រា ២ : កងអាវុធហត្ថជាតិ ជាស្ថាប័នមួយនៃកងទ័ពជាតិ ហើយដោយត្រូវតាមលក្ខន្តិកៈនោះ ត្រូវឋិតនៅក្រោមអំណាចរបស់អគ្គបញ្ជាការនៃកងទ័ពជាតិខ្មែរ ( កងយោធពលជាតិខ្មែរ ) ។ កងអាវុធហត្ថជាតិមានភារកិច្ចរ៉ាប់រងខាងប៉ូលីសយោធា ( នគរបាលយោធា ) ខាងប៉ូលីសរដ្ឋបាល ( នគរបាលរដ្ឋបាល ) ខាងប៉ូលីសតុលាការ( នគរបាលយុត្តិធម៌ ) ។ កងអាវុធហត្ថជាតិពាក់សញ្ញាសំគាល់ផ្ទាល់របស់ខ្លួន ។

មាត្រា ៣ : នៅក្នុងការអនុវត្តន៍ភារកិច្ចរបស់ខ្លួន ខាងនគរបាលរដ្ឋបាល និងខាងនគរបាលយុត្តិធម៌ស៊ីវិលនោះ កងអាវុធហត្ថជាតិ ត្រូវឋិតនៅក្រោមអំណាចផ្ទាល់របស់ក្រសួងមហាផ្ទៃ ។

ក្នុងឋានៈនេះ ក្រសួងមហាផ្ទៃដែលជាអ្នកទទួលខុសត្រូវខាងការរក្សាសណ្តាប់ធ្នាប់, ខាងការការពារសន្តិសុខ និងសប្បាយភាពសាធារណៈ (វិធានការខាងអនាម័យសាធារណៈ ) នោះ ត្រូវបានទទួលពីអគ្គបញ្ជាការនៃកងយោធពលជាតិខ្មែរ នូវការបែងអំណាចជាអចិន្ត្រៃយ៍ តាមឋានានុក្រមដូចខាងក្រោម :

- អំណាចខាងការតែងតាំងមុខងារ ឬការផ្លាស់ប្តូរ ក្នុងរង្វង់ការងាររបស់កងអាវុធហត្ថជាតិ ដែលឋិតនៅក្រោមអំណាចក្រសួងមហាផ្ទៃ ។

- អំណាចខាងបញ្ជូនត្រឡប់ទៅអគ្គបញ្ជាការកងយោធពលជាតិខ្មែរវិញ ។

- អំណាចខាងការផ្តល់រង្វាន់ ឬការដាក់ទណ្ឌកម្ម ( ការស្នើផ្តល់រង្វាន់ និងដាក់ទណ្ឌកម្ម ) នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

- អំណាចខាងធ្វើមូលវិចារណ៍ និងផ្តល់ពិន្ទុដល់អាវុធហត្ថគ្រប់រូបទាំងអស់ គឺទាំងនាយ និងពលអាវុធហត្ថដែលបំពេញមុខងារជានគរបាលរដ្ឋបាល និងជានគរបាលយុត្តិធម៌ តាមបទបញ្ញត្តិទាំងឡាយដែលចែងដោយអគ្គបញ្ជាការនៃកងយោធពលជាតិខ្មែរ ។

## មាតិកា ២

## រចនាសម្ព័ន្ធ

**ប្រការ ៤ :** កងអាវុធហត្ថជាតិ ត្រូវឋិតនៅក្រោមបញ្ជារបស់មេបញ្ជាការម្នាក់នៃកងអាវុធហត្ថជាតិ ដែលមាន ក្នុងកំរិតទីបញ្ជាការកណ្តាល នូវសេនាធិការមួយ, អធិការដ្ឋានមួយ និងសាលាកងអាវុធហត្ថមួយ ។

**ប្រការ ៥ :** កងអាវុធហត្ថជាតិ ត្រូវបានបែងចែកដូចតទៅ :

១ - ក្នុងកំរិតភូមិភាគរដ្ឋបាល ឬយោធភូមិភាគ មួយភូមិភាគនៃកងអាវុធហត្ថជាតិដែលឋិតនៅក្រោមបញ្ជារបស់មេបញ្ជាការភូមិភាគម្នាក់ ដែលបំពេញមុខងារនៅក្នុងបញ្ជាការដ្ឋានរបស់ខ្លួន ដោយមានសេនាធិការមួយ និងមាន មេបញ្ជាការរងពីរនាក់ : - មេបញ្ជាការរងម្នាក់ទទួលបន្ទុកកងអាវុធហត្ថដែនដី ,

- និងមេបញ្ជាការរងម្នាក់ទទួលបន្ទុកកងអាវុធហត្ថចល័ត ។

២ - ក្នុងកំរិតខេត្ត អនុខេត្ត និងក្រុង ក្រៅពីភ្នំពេញ មួយកងអនុសេនាធំនៃកងអាវុធហត្ថដែនដី និងមួយក្រុមអន្តរាគមន៍នៃកងអាវុធហត្ថចល័ត ។

៣ - ក្នុងកំរិតស្រុក មួយកងអនុសេនាតូចនៃកងអាវុធហត្ថដែនដី និងមួយក្រុមនៃកងអាវុធហត្ថចល័ត ។

៤ - ក្នុងកំរិតសង្កាត់ មួយក្រុមតូច និងប៉ុស្តិ៍កងអាវុធហត្ថសំរាប់ទីប្រជុំជនសំខាន់ ១ ខ្លះ ។

កងកំលាំងនៃកងអាវុធហត្ថជាតិ អាចមានបុគ្គលិកជំនួយបាន ដែលអោយឈ្មោះថាជា **កងជំនួយ**របស់កងអាវុធហត្ថជាតិ ។

**មាត្រា ៦ :** ទីក្រុងភ្នំពេញ មានមណ្ឌលគ្រប់គ្រងមួយនៃកងអាវុធហត្ថដែនដី ដោយមានសេនាធិការមួយ ហើយត្រូវបានបែងចែកជា :

- មួយ ឬច្រើនកងអនុសេនាធំ ក្នុងមួយសង្កាត់ ទៅតាមសារៈសំខាន់របស់សង្កាត់នោះ ។
- មួយកងវរអន្តរាគមន៍ចល័ត ។

**មាត្រា ៧ :** ទីបញ្ជាការកងអាវុធហត្ថជាតិមានអង្គភាពជំនួយសំរាប់ដឹកនាំបញ្ជារបស់កងអាវុធហត្ថជាតិ ដែលមានទីតាំងនៅភ្នំពេញ ហើយដែលមានសមាសភាពដូចតទៅ :

- មួយកងវរសេនាតូចការពារសន្តិសុខ និងគាំទ្រ ,
- ពីរកងវរសេនាតូចអន្តរាគមន៍ ,
- មួយកងអនុសេនាធំ ជើងអាកាស,
- មួយកងអនុសេនាធំ ជើងទឹក,
- ក្រុមបច្ចេកទេសនានា,
- អង្គភាពចល័តនានា ដែលតម្រូវតាមស្ថានការណ៍ ឬផ្លាស់ទៅកាន់អង្គភាពសំខាន់ ១ ។

## មាតិកា ៣

## ភារកិច្ច

មាត្រា ៨ : កងអាវុធហត្ថជាតិមានភារកិច្ចសំខាន់ ៗ ដើម្បីធ្វើអោយគេគោរពច្បាប់ និងបទបញ្ជាទាំងឡាយដែលឋិតនៅជាធរមាន ក្នុងក្របខ័ណ្ឌនៃបេសកកម្មរបស់ប៉ូលីសយោធា, ប៉ូលីសរដ្ឋបាល និងប៉ូលីសតុលាការ ដែលមានចែងនៅក្នុង មាត្រា ២ ។

**I- អំពីប៉ូលីសយោធា :**

**មាត្រា ៩ :** ក្នុងការងារប៉ូលីសយោធា កងអាវុធហត្ថជាតិ មានករណីយកិច្ចដើម្បី :

១- ចូលរួមក្នុងការរក្សាវិន័យ និងធ្វើអោយគេគោរពបទបញ្ជាយោធា នៅក្នុងអង្គភាពទាំងឡាយ ។

២- អនុវត្តដីកាទាំងឡាយ និងដីកាចាត់អោយស៊ើបសួររបស់តុលាការយោធា ។

៣- ធានារ៉ាប់រងខាងសន្តិសុខ និងនិរន្តរាយផ្នែកយោធា ។

៤- ធានារ៉ាប់រងខាងប៉ូលីសទូទៅផ្នែកយោធា ខាងប៉ូលីសតុលាការយោធា ខាងផ្ទេរអ្នកទោសតាមបញ្ជាតុលាការ, ខាងក្រុមការងារពន្ធនាគារ ខាងប៉ូលីសចរាចរ ខាងការរក្សា និងដឹកនាំក្រុមឈ្លើយសឹក ។

**មាត្រា ១០ :** កងអាវុធហត្ថជាតិត្រូវចូលរួមក្នុងអភិបាលកិច្ច,ក្នុងការរៀបចំ,ក្នុងការហ្វឹកហ្វឺនកងកំលាំងជំនួយ នៅក្នុងក្របខ័ណ្ឌនៃកំណែនទូទៅ ។

**II- អំពីប៉ូលីសរដ្ឋបាល :**

**មាត្រា ១១ :** ក្នុងការងារប៉ូលីសរដ្ឋបាល កងអាវុធហត្ថជាតិត្រូវយកចិត្តទុកដាក់ក្នុងការរក្សាសណ្តាប់ធ្នាប់ ក្នុងការការពារសន្តិសុខ និងសប្បាយភាពសាធារណៈក្រោមអំណាចផ្ទាល់របស់អាជ្ញាធររដ្ឋបាលដែលខ្លួនចំណុះនោះ ។

**III – អំពីប៉ូលីសតុលាការស៊ីវិល :**

**មាត្រា ១២ :** ក្នុងការងារប៉ូលីសតុលាការស៊ីវិល កងអាវុធហត្ថជាតិត្រូវបង្ក្រាបបទល្មើសទាំងឡាយ ដែលមានលក្ខណៈជាបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ ហើយត្រូវស្រាវជ្រាវរកជនល្មើសទាំងឡាយ ដើម្បីបញ្ជូនពួកគេទៅអោយតុលាការសមត្ថកិច្ចជំនុំជំរះ ។

កងអាវុធហត្ថជាតិ ត្រូវអនុវត្តដីកាទាំងឡាយ និងដីកាចាត់អោយស៊ើបសួររបស់តុលាការព្រហ្មទណ្ឌ ។

**មាត្រា ១៣ :** នាយទាហាននៃកងអាវុធហត្ថជាតិ ព្រមទាំងនាយទាហានរង ដែលបំពេញមុខងារជាមេបញ្ជាការក្រុមតូច ឬជានាយប៉ុស្តិ៍នោះ សុទ្ធតែជាមន្ត្រីប៉ូលីសតុលាការ ។

ក្នុងឋានៈនេះ មន្ត្រីទាំងនោះមានតួនាទីពិនិត្យកត់ត្រានូវបទល្មើសទាំងឡាយ រៀបចំកំណត់ហេតុ ហើយបើសិនជាត្រូវធ្វើ ត្រូវស្នើសុំកំលាំងសាធារណៈទាំងអស់ដែលចាំបាច់ក្នុងការបំពេញមុខងាររបស់ខ្លួន ។

បុគ្គលិកដទៃទៀតរបស់កងអាវុធហត្ថជាតិ ជាភ្នាក់ងារនៃកំលាំងសាធារណៈ និងជាកំលាំងជំនួយរបស់មន្ត្រីប៉ូលិសតុលាការ ។

## មាតិកា ៤

## បទបញ្ញត្តិដោយឡែក

**មាត្រា ១៤ :** ត្រូវបានចាត់ទុកជានិរាករណ៍ទាំងស្រុងព្រមទាំងគ្មានល័ក្ខខ័ណ្ឌ នូវបទបញ្ញត្តិទាំងឡាយពីមុនក្រឹត្យនេះ ។

**មាត្រា ១៥ :** រដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គបញ្ជាការកងយោធពលជាតិខ្មែរ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវទទួលបន្ទុកអនុវត្តក្រឹត្យនេះរៀងខ្លួន ចំពោះរឿងអ្វីដែលពាក់ព័ន្ធ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ៩ ខែ តុលា ឆ្នាំ ១៩៧១

ហត្ថលេខា : **ចេង ហេង**

ប្រមុខរដ្ឋ

នាយករដ្ឋមន្ត្រីប្រតិភូ

ហត្ថលេខា : **ស៊ីសុវត្ថិ សិរីមតៈ**

ដាក់ជូនសុំហត្ថលេខាប្រមុខរដ្ឋ

ដោយនាយករដ្ឋមន្ត្រីប្រតិភូ

រដ្ឋមន្ត្រីក្រសួងការពារជាតិ

ហត្ថលេខា : **ស៊ីសុវត្ថិ សិរីមតៈ**

ចម្លងចែក

លេខាធិការក្រុមប្រឹក្សារដ្ឋមន្ត្រី

ហត្ថលេខា : **អ៊ុក ស៊ុន**

ចម្លងត្រឹមត្រូវតាមច្បាប់ដើម

វរសេនីយ៍ទោ **អាំ សាអេន**

នាយកកំណែន និងជ្រើសរើស

ហត្ថលេខា : **អាំ សាអេន**

# ប្រវត្តិកងរាជអាវុធហត្ថ

# La Gendarmerie nationale, son organisation et son fonctionnement

Par kret n° 574/71-CE du 5 octobre 1971, il est ordonné ce qui suit :

## TITRE—I

## —Généralités—

*Article 1er*.- La Gendarmerie royale khmère instituée et organisée par kret n° s 446.NS. et 447.NS. de 27 septembre 1957 prend l'appellation de «Gendarmerie nationale», à compter de la signature du présent kret.

*Article 2*.— La Gendarmerie nationale est une Arme des forces armées nationales et relève statutairement du haut commandement des Forces armées nationales khmères. Elle a pour mission d'assurer la Police militaire, la Police administrative et la Police judiciaire. Elle porte des insignes distinctifs qui lui sont propres.

darmerie nationale qui dispose à l'échelon central d'un état-major, d'une inspection et d'une Ecole de Gendarmerie.

*Article 5*.— La Gendarmerie nationale est articulée ainsi qu'il suit :

1.— à l'échelon région administrative ou région militaire, en une légion de la Gendarmerie nationale placée sous les ordres d'un commandant de légion exerçant son commandement par un état-major régional et secondé :

—d'un adjoint territorial

—et d'un adjoint mobile.

2.— à l'échelon khèt, anouk-khèt et municipalité autres que Phnom-Penh, en une compagnie de Gendarmerie territoriale et un détachement d'intervention de gendarmerie mobile.

3.— à l'échelon srok en une section de gen-

# កាសែតតម្រួតយោធា

— ប្រចាំខែ —

ផ្សាយចេញរាល់ថ្ងៃទី ១ ពីសេនាធិការដ្ឋានតម្រួតយោធា [ក៥]

វិថី ១៨ មិនា ១៩៧០ ភ្នំពេញ – ទូរស័ព្ទលេខ ២.២២៩៣

# GAZETTE DU PREVOT

DIFFUSEE PAR L'ETAT - MAJOR DE LA P.M. (5°B)

*Vithei 18 Mars 1970 Phnom-Penh Téléphone: 2.2293*



ឆ្នាំទី ២ លេខ ១២ ខែវិច្ឆិកា ឆ្នាំ ១៩៧១

ARCHIVES NATIONALES
REGIE